# កឋិនក្ខន្ធកៈ

រៀបរៀងដោយ

ព្រះគ្រូវិរិយមុនីវិសុទ្ធិញាណ អ៊ុច_ទស់

អាចារ្យបង្រៀនបាលីនៅសាលាបាលីជាន់ខ្ពស់

ក្រុងភ្នំពេញ

<u>ចម្លងដោយៈ</u>

បណ្ណាគារ[illegible]

លេខ១៣៦ វិថី[illegible]មរតូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៥៤០ គ.ស ១៩៩៧

ផ្សាយចេញពី

**www.haotrai.com**

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

AnAnA
Computer
Trusted Service & Quality

# កឋិនក្ខន្ធកៈ

រៀបរៀងដោយ

ព្រះគ្រូវិរិយមុនីវិសុទ្ធិញាណ អ៊ុច-រស់

អាចារ្យបង្រៀនបាលីនៅសាលាបាលីជាន់ខ្ពស់

ក្រុងភ្នំពេញ

សាន-ភារ៉េត

ចម្លងដោយ:

បណ្ណាគារត្រៃរតន៍

លេខ១៣៦ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៥៤០ គ.ស ១៩៩៧



## កឋិនក្ខន្ធកៈ

សាន-ភារ៉េត

### កឋិនុប្បត្តិកថា

ខាងដើមនេះ នឹងពណ៌នាអំពីដំណើរហេតុដែលនាំឱ្យកើតមានកឋិនឡើងក្នុងព្រះពុទ្ធសាសនាជាដំបូង តាមលំអានដែលមានមកក្នុងគម្ពីរមហាវគ្គផ្នែកវិនយបិដកដោយត្រង់ៗ ។

សេចក្តីដំណាលផ្សេងថា: ព្រះបរមសាស្តានៃយើងទាំងឡាយ ទ្រង់បានត្រាស់ដឹងឡើងក្នុងលោករាប់បាន ចំនួន ៤៥ ព្រះវស្សា ព្រះអង្គបានជំរះពុទ្ធកិច្ចសព្វគ្រប់ហើយ ក៏ទ្រង់បរិនិព្វានទៅ ។ ក៏ក្នុងរវាង៤៥ព្រះវស្សាដែលព្រះអង្គទ្រង់បានត្រាស់នោះ បើចែកចេញជាកាលមាន ៣ គឺរាប់អំពីវស្សាទី ១ ដល់វស្សាទី ១៥ ចាត់ជាកាលទី ១ ឈ្មោះបឋមពោធិកាល អំពីវស្សាទី ១៦ ដល់វស្សាទី ៣០ ចាត់ជាកាលទី ២ ឈ្មោះមជ្ឈិមពោធិកាល អំពីវស្សាទី ៣១ ដល់វស្សាទី ៤៥ ដែលព្រះអង្គទ្រង់បរិនិព្វាននោះ ចាត់ជាកាលទី ៣ ឈ្មោះបច្ឆិមពោធិកាល ។

សម័យមួយនោះ នៅក្នុងរវាងមជ្ឈិមពោធិកាល ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវិហារជេតពន ដែលអនាថបិណ្ឌិកសេដ្ឋីសាងថ្វាយ ទៀបក្រុងសាវត្ថី។ គ្រានោះមានភិក្ខុ ៣០ អង្គ[១] នៅក្នុងដែនបាវេយ្យ[២] ជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ប្រព្រឹត្តដើរបិណ្ឌបាត ប្រព្រឹត្តប្រើសំពត់បង្សុកូល ប្រព្រឹត្តប្រើតែចីវរ៣ទាំង

អស់អង្គ[៣] នាំគ្នាចេញអំពីទីនោះមកកាន់ក្រុងសាវត្ថី ដើម្បីគាល់បំរើព្រះដ៏មានព្រះភាគ ទើបតែមកដល់ពាក់កណ្ដាលផ្លូវគាប់ជួនជាដល់ថ្ងៃចូលវស្សានឹងស្រូតមកទៀតមិនទាន់ក៏នាំគ្នាស្វែងរកទីសេនាសនៈនៅចាំវស្សា ទៀបក្រុងសាកេត នាពាក់កណ្ដាលផ្លូវនោះទៅ ។ ដល់ក្នុងរវាងវស្សា ភិក្ខុទាំងនោះមានសេចក្ដីអផ្សុកជាខ្លាំង ដោយគិតឃើញថា ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងទីជិតចម្ងាយតែ៦យោជន៍ទៀត សោះមិនសមបើយើងទាំងឡាយស្ទុនដំណើរមិនបាន ទៅគាល់បំរើព្រះអង្គ ។ លុះដល់ថ្ងៃចេញវស្សា បវារណាហើយស្រេចលោកក៏នាំគ្នាស្រូតចេញអំពីទីនោះមកទៀត ទទួលរដូវនោះនៅមានភ្លៀងរលឹមជោកជាំនៅឡើយ តាមផ្លូវដែលទៅមកសឹងដំពោរពាសដោយទឹកនឹងភក់រអិលប្រប៉ិចប្រប៉ាច់ លោកទាំងនោះក៏មានត្រៃចីវរទទឹកស្រគុក បានសេចក្ដីលំបាកតាមផ្លូវជាខ្លាំងលុះបានដល់មកក្រុងសាវត្ថីហើយ

១-អដ្ឋកថាប្រាប់ថា: ភិក្ខុទាំង ៣០ អង្គនេះគឺជាព្រះភទ្ទវគ្គិយត្ថេរទាំង ៣០ អង្គដែលជាបងប្អូនបង្កើត រួមបិតាជាមួយ មាតាទីទៃ ជាព្រះរាជបុត្រព្រះចៅកោសលរាជ ដែលបានទទួល ឧបសម្បទជាឯហិភិក្ខុក្នុងសំណាក់ ព្រះសាស្ដា អំពីបឋមពោធិកាល ហើយបាននាទីជាសេក្ខបុគ្គល ទាំងអស់អង្គលោកដែលជាន់ទាបត្រឹម សោតាបន្ន ជាន់ខ្ពស់ ត្រឹមអនាគាមិ ឯបុថុជ្ជននិងព្រះអរហន្តមិនមានក្នុងក្រុមលោកឡើយ ។ ២- អដ្ឋកថាប្រាប់ថា: ដែននេះជាជម្ពូទ់ ១ តាំងនៅក្នុងដែនកោសល បែកខាងបច្ចិមទិសាភាគចម្ងាយពីក្រុងសាវត្ថី១២យោជន៍ ។ គម្ពីរខ្លះថា "បាវេយ្យ" ។ ៣- អដ្ឋកថាប្រាប់ថា: ភិក្ខុទាំង៣០អង្គនេះ សុទ្ធតែសមាទានធុតង្គទាំងអស់អង្គ ។



ក៏ចូលទៅកាន់វិហារព្រះជេតពន ដែលព្រះដ៏មានព្រះភាគទ្រង់គង់នៅ ហើយនាំគ្នាចូលទៅក្រាបថ្វាយបង្គំព្រះអង្គរួចគង់នៅក្នុងទីដ៏សមគួរ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់មានព្រះបន្ទូលរាក់ទាក់ទៅរកភិក្ខុទាំងនោះថា: ម្នាលភិក្ខុទាំងឡាយ សរីរយន្តរបស់អ្នកទាំងឡាយល្មមអត់សង្កត់បានទេឬ? ល្មមឱ្យប្រព្រឹត្តទៅបានទេឬ? អ្នកទាំងឡាយមានសេចក្ដីព្រមព្រៀងស្មោះស្មើឥតមានវិវាទទាស់ទែងគ្នាទេឬ? ទាំងនៅចាំវស្សាសោតស្រួលបួលមិនលំបាកដោយអាហារបិណ្ឌបាតទេឬ[១]? ។ ភិក្ខុទាំងនោះក្រាបបង្គំទូលតាមដំណើរថា: បពិត្រព្រះអង្គដ៏ចំរើន សរីរយន្តរបស់ខ្ញុំព្រះអង្គទាំងអស់គ្នា ល្មមអត់សង្កត់បានទេ, ល្មមឱ្យប្រព្រឹត្តទៅបានទេ, ខ្ញុំព្រះអង្គទាំងអស់គ្នា មានសេចក្ដីព្រមព្រៀងស្មោះស្មើ ឥតមានវិវាទទាស់ទែគ្នាទេ, ទាំងនៅចាំវស្សាសោតក៏ស្រួលបួលដែរ មិនបានលំបាកដោយអាហារបិណ្ឌបាតទេ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលស្នងព្រះពុទ្ធដីកាដូច្នេះរួចហើយក៏ក្រាបបង្គំទូលអំពីសេចក្ដីលំបាករបស់ខ្លួន ដែលមកតាមផ្លូវដោយសព្វគ្រប់តាមដំណើរតទៅទៀត ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់សំដែងនូវធម្មីកថាប្រារព្ធអំពីសំសារវដ្តមិនមានទីបំផុត ប្រោសប្រទានភិក្ខុទាំងនោះលុះចប់ហើយ ភិក្ខុទាំងនោះក៏បានលុះព្រះអរហត្តទាំងអស់អង្គ ហើយនាំគ្នាហោះតាមអាកាស

១ ពាក្យនេះ ជាប្រពៃណីព្រះពុទ្ធទ្រង់សួរសុខទុក្ខ ។

ទៅកាន់ទីលំនៅរបស់ខ្លួនអស់ទៅ ។ បន្ទាប់អំពីនោះមកព្រះដ៏មានព្រះភាគទ្រង់ព្រះដម្រិះថាៈ បើប្រសិនជាតថាគតបានតែងតាំងកឋិនត្ថារកិច្ចទុកអំពីគ្រាមុន ម្ល៉េះសមភិក្ខុទាំងនុ៎ះនឹងបានលះចីវរ ១ ទុកនៅទីកន្លែងជាប់មកតែស្បង់និងចីពរប៉ុណ្ណោះ នឹងមានអត្តភាពស្រាលមិនបានលំបាកយ៉ាងនេះសោះឡើយ ហើយកឋិនត្ថារកិច្ចនេះសោតព្រះពុទ្ធទាំងឡាយរាល់ព្រះអង្គ ក៏តែងតែទ្រង់អនុញ្ញាតទុកដល់សាវ័កមិនដែលលះបង់ផង ។ ព្រះអង្គទ្រង់ព្រះដម្រិះយ៉ាងនេះហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកទ្រង់អនុញ្ញាតកឋិនត្ថារកិច្ច ដោយព្រះពុទ្ធដីកាថាៈ **អនុជានាមិ ភិក្ខវេ វស្សំ វុដ្ឋានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ, អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ**[១] ។ ម្នាលភិក្ខុទាំងឡាយ តថាគត អនុញ្ញាតឱ្យភិក្ខុទាំងឡាយដែលបាននៅចាំវស្សារួចហើយ ទទួលក្រាលកឋិន ។ ម្នាលភិក្ខុទាំងឡាយ **កាល**បើភិក្ខុទាំងឡាយបានក្រាលកឋិនរួចហើយនឹងបានសម្រេចអានិសង្ស៥ប្រការដោយពិត ។

ដំណើរដើម ដែលនាំឱ្យកើតមានកឋិនឡើងក្នុងសាសនាដូចន័យដែលបានពណ៌នាមកនេះឯង ។

កឋិនុប្បត្តិកថា ចប់

---

១-គម្ពីរវិនយាលង្ការដីកាកែថាៈ បញ្ចាតិ ឥទានិ វុច្ចមានា អនាមន្តចារាទយោ បញ្ចកិរិយា កប្បិស្សន្តីតិ ភប្បា ភវិស្សន្តិ អនាបត្តិការណា ភវិស្សន្តីតិ អត្ថោ ។



## កឋិនសទ្ទកថា

បន្ទាប់នេះនឹងពណ៌នាអំពី**កឋិនសព្ទ**តាមន័យ ដែលមានមកក្នុង**បាលី** នឹងអដ្ឋកថា-ដីកាទាំងពួងជាលំដាប់គ្នាតទៅ ។

ក៏កឋិនសព្ទនេះ បើពោលឱ្យស្ដែងឡើងក៏ឃើញថា ជាប្រធានលើ**ពាក្យ**ទាំងអស់ក្នុងកឋិនក្ខន្ធកៈទាំងស្រុង ព្រោះថាពាក្យដែលនាំមកថ្លែង**ក្នុង**សៀវភៅកឋិនក្ខន្ធកៈនេះ ទាំងប៉ុន្មានសុទ្ធតែនិយាយអំពីរឿងកឋិន ឬប្រកបមកនឹងរឿងកឋិនទាំងអស់ ហេតុនោះគួរតែដឹងអំពីកឋិនសព្ទនេះឱ្យ**ជាក់**ច្បាស់ជាការប្រពៃ ។

សួរថាៈ អ្វីហៅថា **កឋិន** ។

ឆ្លើយថាៈ តាមគម្ពីរបរិវារលោកកែថាៈ **តេសញ្ញេវ ធម្មានំ សង្គហោ សមវាយោ នាមំ នាមកម្មំ នាមធេយ្យំ និរុត្តិ ព្យញ្ជនំ អភិលាបោ យទិទំ កឋិនំ** ។ (ធម៌ទាំងប៉ុន្មានដែលតាំង**នៅក្នុង**កំឡុងកឋិនត្ថារកិច្ច រាប់តាំងអំពីភិក្ខុដែលបានចូលបុរិមិកវស្សាជា**ដើម** ដរាបដល់ការដែលភិក្ខុក្រាលអនុមោទនាត្រឹមត្រូវប្រកបដោយធម៌**ជាទី**បំផុតជានាមធម៌ខ្លះ ជារូបធម៌ខ្លះ) ការរួបរួម ដំណើរដែលប្រព្រឹត្តទៅ**ស្មើគ្នា** ឈ្មោះ អំពើដែលឱ្យឈ្មោះ ពាក្យដែលហៅតាមឈ្មោះ សំដីនិយាយ**បញ្ចេញ**ឈ្មោះ រូបព្យញ្ជនៈ ពាក្យពោលចំពោះធម៌ទាំងនោះ ទាំងអស់នេះ

ហៅថា កឋិន ។ ក្នុងគម្ពីរបញ្ចមសមន្តបាសាទិកាអដ្ឋកថាលោកកែថា: **យេសុ រូបាទីសុ ធម្មេសុ សតិ កឋិនំ នាម ហោតិ តេសំ សមោធានមិស្សីភាវោ** ។ កាលបើធម៌ទាំងឡាយមានរូបធម៌ជាដើមមាន ភាពដែលធម៌ទាំងនោះប្រជុំចុះព្រម ឬច្រឡំគ្នាព្រមហៅថា កឋិន ។ ក្នុងគម្ពីរដដែលនោះលោកកែតទៅទៀតថា: **កឋិនន្តិ ឥទំ ពហូសុ ធម្មេសុ នាមមត្តំ ន បរមត្ថតោ ឯកោ ធម្មោ អត្ថិ** ។ ពាក្យថា "កឋិន" នេះ គ្រាន់តែជាឈ្មោះធម៌ទាំងឡាយច្រើនពួក មិនមានធម៌ណា ១ ដែលមានមកតាមបរមត្ថឡើយ ។ ក្នុងគម្ពីរវិនយាលង្ការដីកា លោកកែថា: សមូហបញ្ញត្តិ ការដែលលោកប្រជុំធម៌ច្រើនពួកមកតាំងឱ្យឈ្មោះតាមសមគួរដល់ហេតុ ហៅថា កឋិន ។ ពាក្យអធិប្បាយរបស់លោកក្នុងគម្ពីរនោះថា: **បុរិមវស្សំ វុដ្ឋា ភិក្ខូ អនូនបញ្ចវគ្គសង្ឃោ ចីវរមាសោ ធម្មេន សមេន ឧប្បន្នចីវរន្តិ អាទីសុ យេសុ នាមរូបេសុ សមុប្បជ្ជមានេសុ តេសំ នាមរូបធម្មានំ សមូហសមវាយសង្ខាតំ សមូហបញ្ញត្តិមត្តមេវ កឋិនំ** ។ កាលបើនាមធម៌នឹងរូបធម៌ទាំងឡាយ មានភិក្ខុដែលបានចូលបុរិមិកវស្សាសង្ឃបញ្ចវគ្គឥតខ្វះ ខែដែលត្រូវចីវរកើត នឹងចីវរ កើតឡើងស្មោះស្មើប្រកបដោយធម៌ជាដើម កើតឡើងព្រម សំដៅយកត្រង់សមូហបញ្ញត្តិ គឺ



ប្រជុំនាមធម៌និងរូបធម៌ទាំងនោះឬដំណើរដែលនាមធម៌និងរូបធម៌ទាំងនោះប្រព្រឹត្តទៅព្រមគ្នាហៅថា កឋិន ។ (ក្នុងគម្ពីរវិមតិវិនោទនីដីកា ក៏លោកកែសេចក្ដីប្រហែលគ្នានឹងគម្ពីរនេះដែរ) ។

សេចក្ដីបំព្រួញ: ពាក្យថា "កឋិន" នេះមិនមែនជាពាក្យជ្រាលជ្រៅតាមផ្លូវបរមត្ថឡើយ ហើយមិនមែនជាឈ្មោះនៃធម៌តែមួយមុខៗ ទេ គឺលោករួបរួមយកធម៌ច្រើនមុខជានាម ធម៌ខ្លះដូចខែ ដែលចីវរកើតនិងការដែលភិក្ខុក្រាលក្រាបប្រកបដោយធម៌ជាដើម ជារូបធម៌ខ្លះ ដូចភិក្ខុដែលបានចូលបុរិមិកវស្សា សង្ឃបញ្ចវគ្គ នឹងចីវរដែលកើតឡើងប្រកបដោយធម៌ជាដើម មកសន្មតឱ្យឈ្មោះ បើប្រៀបជាឧទាហរណ៍ខាងក្រៅដូចពាក្យថា "សាលា" ឬ "រថ" ជាដើម ។

កឋិនសទ្ទកថា ចប់

---

## កឋិនត្ថកថា

បន្ទាប់នេះនឹងពណ៌នាអំពីអត្ថរបស់កឋិនតទៅ តាមលំអានដែលមានមកក្នុងគម្ពីរផ្សេងៗ ដូចឆ្លើយអាងមកស្រាប់ ។

សួរថា: ដែលលោកឱ្យឈ្មោះថា "កឋិន" ដូច្នេះដោយសេចក្ដីយ៉ាងណា ។

ឆ្លើយថា: តាមគម្ពីរវិនយាលង្ការដីកា លោកកែថា: **ចីវរត្ថេន**

**កឋិនំ** ។ ដែលលោកឱ្យឈ្មោះថា "កឋិន" ដូច្នេះដោយសេចក្តីថាៈ ស្ថិតស្ថេរឬខ្ជាប់ខ្ជួន ។ ពាក្យអធិប្បាយរបស់លោកថាៈ អនាមន្តចារ-អសមាទានចារ-គណភោជន-យាវទត្ថ ចីវរ-តត្ថចីវរុប្បាទសង្ខាតេ បញ្ចានិសំសេ អន្តោករណសមត្ថតាយ ។ បានជាលោកឱ្យឈ្មោះថា "កឋិន" ដូច្នេះព្រោះកឋិននេះ អង់អាចនឹងធ្វើអានិសង្សទាំង ៥ ប្រការគឺៈ អនាមន្តចារ ១ អសមាទានចារ ១ គណភោជន ១ យាវទត្ថចីវរ ១ តត្ថចីវរុប្បាទ ១[១] ឱ្យស្ថិតនៅខ្ជាប់ ខាងក្នុងរវាងខេត្តខ្លួនបាន ។ ក្នុងគម្ពីរសារត្ថទីបនីដីកាវិមតិវិនោទនីដីកានិងវជិរពុទ្ធដីកា កែស្របគ្នាថាៈ **បញ្ច អានិសំសេ អន្តោករណសមត្ថតាយ ថិរន្តិ អត្ថោ** ។ ពាក្យថា "កឋិន" បានសេចក្តីថា ស្ថិតស្ថេរឬខ្ជាប់ខ្ជួន ព្រោះកឋិននេះអង់អាចនឹងធ្វើអានិសង្សទាំង ៥ ឱ្យស្ថិតនៅក្នុងរវាងខេត្តខ្លួនបាន ។ (សេចក្តីនេះត្រូវគ្នានឹងមុន ប្លែកតែមិនបានរាប់ឈ្មោះអានិសង្សទាំង ៥ប៉ុណ្ណោះ) ។ ក្នុងគម្ពីរវិនយាលង្ការដីកាដដែល លោកកែន័យមួយផ្សេងទៀតថាៈ **សង្គណ្ហនតោ កឋិនំ** ។ ដែលលោកឱ្យឈ្មោះថា "កឋិន" ដូច្នេះដោយសេចក្តីថា សង្គ្រោះទុកឬក្រសោបទុក ។ ពាក្យអធិប្បាយរបស់លោកថាៈ **បញ្ច អានិសំសេ អញ្ញត្ថ គន្តុំ អទត្វា សង្គណ្ហាតិ សង្ខិបិត្វា គណ្ហាតិ** ។

១-អានិសង្សទាំង ៥ នេះ នឹងមានអធិប្បាយទៅខាងចុង ។



**កឋិន**នេះរមែងសង្គ្រោះទុកឬក្រសោបទុកនូវអានិសង្សទាំង ៥ មិនឱ្យទៅក្នុងទីដទៃបាន ។ ក្នុងគម្ពីរវិនយត្ថមញ្ជូសា លោកកែថាៈ **បញ្ច អានិសំសេ អញ្ញត្ថ គន្តុំ អទត្វា សង្គណ្ហនតោ កឋិនំ** ។ ដែលលោកឱ្យឈ្មោះថា "កឋិន" ដូច្នេះដោយសេចក្តីថាសង្គ្រោះទុកនូវអានិសង្សទាំង ៥ មិនឱ្យទៅក្នុងទីដទៃបាន ។ លោកចង់វិគ្គហទុកថាៈ **បញ្ច អានិសំសេ អញ្ញត្ថ គន្តុំ អទត្វា កឋតិ សង្គណ្ហាតីតិ កឋិនំ** ។ ធម្មជាតឯណាក្រៀកទុកឬសង្គ្រោះទុកនូវអានិសង្សទាំង៥មិនឱ្យទៅក្នុងទីដទៃបាន ធម្មជាតនោះឈ្មោះថា កឋិន ។ ន័យមួយទៀត ក្នុងគម្ពីរវិនយាលង្ការដីកាលោកចង់វិគ្គហផ្សេងពីនេះ១បែបទៀតថាៈ **កឋតិ កិច្ឆេន ជីវតីតិ កឋិនោ រុក្ខោ ។ តស្ស ឯសោតិ កឋិនោ ថិរភាវោ ។ សោ ឯតស្ស អត្ថីតិ កឋិនំ បញ្ញត្តិជាតំ ។** សភាវៈឯណារស់នៅដោយកម្រ សភាវៈនោះហៅថា កឋិន សំដៅយកឈើ(ស្នឹង) ។ ឈើនុ៎ះរបស់សភាវៈនោះមានសភាវៈនោះហៅថា កឋិន សំដៅយកភាពដែលខ្ជាប់ខ្ជួន ។ ភាពដែលខ្ជាប់ខ្ជួននោះរបស់ធម្មជាតនុ៎ះមាន ធម្មជាតនុ៎ះហៅថា កឋិន សំដៅយកបញ្ញត្តិជាតិគឺពុទ្ធបញ្ញត្តិ ។

សេចក្តីបំព្រួញៈ ពាក្យថា "កឋិន" នេះបើរួបរួមឱ្យខ្លីចុះមកបាន សេចក្តីតែ ១ ម៉ាត់ថា ជាកិច្ច ១ ក្នុងសាសនាកើតឡើងតាមពុទ្ធានុញ្ញាត

សម្រាប់ហ៊ុមទុក ឬក្រៀកទុក នូវអានិសង្សទាំង ៥ ឱ្យសម្រេចដល់ភិក្ខុអ្នកក្រាល អ្នកអនុមោទនាដរាបដល់អស់អំណាចខ្លួនជាទីបំផុត ប្រៀបជាឧទាហរណ៍ខាងក្រៅដូចពាក្យថា "ក្រោល" ឬ "ស្ទឹង" ជាដើម ។

ពណ៌នាមកដោយសង្ខេបអំពីអត្ថរបស់កឋិន ក៏អស់សេចក្តីតែប៉ុណ្ណេះ ។

កឋិនត្ថកថា ចប់

## បញ្ចានិសំសកថា

បន្ទាប់នេះនឹងពណ៌នាអំពីអានិសង្សទាំង ៥ ប្រការតទៅ ។ តាមព្រះពុទ្ធដីកាខាងដើមនុ៎ះថា ភិក្ខុដែលបានក្រាលកឋិនរួចហើយនឹងបានសម្រេចអានិសង្ស ៥ ប្រការ តែថា អានិសង្សទាំងនោះជាយ៉ាងណាខ្លះនៅមិនទាន់បានរៀបរាប់នៅឡើយ ហេតុនោះក្នុងកថានេះនឹងពោលអំពីអានិសង្សទាំងនោះ តាមលំនាំនៃបាលីនិងអដ្ឋកថា-ដីកាតទៅ ។

ក៏អានិសង្សទាំង ៥ ប្រការនោះ តាមលំអានព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គដូច្នេះគឺ: អនាមន្តចារោ ១ អសមាទានចារោ ១ គណភោជនំ ១ យាវទត្ថចីវរំ ១ យោ ច តត្ថចីវរុប្បាទោ សោ នេសំ ភវិស្សតិ ១ ។

អធិប្បាយ: អានិសង្សទី ១ អដ្ឋកថាកែចេញទៅថា: **អនាមន្ត~ចារោតិ យាវ កឋិនំ ន ឧទ្ធរិយតិ តាវ អនាមន្តេត្វា**



**ចរណំ កប្បិស្សតិ ចារិត្តសិក្ខាបទេន អនាបត្តិ ភវិស្សតីតិ អត្ថោ** ។ ពាក្យថា "អនាមន្តចារោ" បានសេចក្តីថា: កឋិននៅមិនទាន់ដោះត្រឹមណា អំពើដែលភិក្ខុមិនបានលាភិក្ខុផងគ្នាសិនហើយត្រាចទៅនឹងគួរ គឺថានឹងមិនមានអាបត្តិក្នុងចារិត្តសិក្ខាបទត្រឹមណោះ ។ ក្នុងគម្ពីរធម្ម-សមុពេវិន័យ កែថា: **អនាមន្តចារោ នាម បញ្ចន្នំ , ភោជនំ អញ្ញតរេន និមន្តិតោ សន្តំ ភិក្ខុំ អនាបុច្ឆា កុលេសុ ចារិត្តាបជ្ជនំ ឧ** អំពើដែលភិក្ខុបានទទួលនិមន្ត ទាយកដោយភោជន ៥ ណាមួយរួចហើយ មិនបានលាភិក្ខុផងគ្នាដែលមាននៅក្នុងវត្តសិន ហើយត្រាចទៅក្នុងត្រកូលទាំងឡាយហៅថា អនាមន្តចារោ ។ ក្នុងគម្ពីរវិនយា-លង្ការដីកាកែថា: **អនាមន្តចារោតិ អនាមន្តេត្វា ចរណំ ឧលឧ សា អាបត្តិ អត្ថតកឋិនស្ស ន ហោតីតិ អត្ថោ** ។ អំពើដែលភិក្ខុមិនបានលាភិក្ខុផងគ្នាហើយត្រាចទៅ ហៅថា អនាមន្តចារោ ។ សេចក្តីថា: មែនពិតភិក្ខុណាមួយ ដែលទាយកទាំងឡាយគេនិមន្តដោយភត្ត នៅប្រកបដោយភត្ត គឺថា នៅជាប់ដោយនិមន្តគេមិនទាន់បានទៅឆាន់របស់គេនោះនៅឡើយ បើមិនបានលាភិក្ខុផងគ្នាដែលមាននៅក្នុងវត្តសិន ហើយត្រាចទៅក្នុងត្រកូលទាំងឡាយ ភិក្ខុនោះនឹងត្រូវអាបត្តិបាចិត្តិយដោយចារិត្តសិក្ខាបទ តែអាបត្តិនោះ មិនមានដល់ភិក្ខុដែលបានក្រាលកឋិន

ឡើយ ។

អានិសង្សទី ២ អដ្ឋកថាកែចេញទៅថា: **អសមាទានចារោតិ តិចីវរំ អសមាទាយ ចរណំ ។ ចីវរវិប្បវាសោ កប្បិស្ស-តីតិ អត្ថោ** ។ អំពើដែលភិក្ខុមិនបាននាំយកចីវរទាំង ៣ គ្រប់ប្រដាប់ឱ្យជាប់ជាមួយនឹងខ្លួនហើយត្រេចទៅហៅថា អសមាទានចារោសេចក្ដីថា: ការដែលនៅប្រាសចាកចីវរនឹងគួរ គឺថានឹងមិនមានអាបត្តិឡើយ ។ ក្នុងគម្ពីរធម្មសមុហវិនយ កែថា: **អសមាទានចារោ នាម អធិដ្ឋិតតស្ស តិចីវរស្ស អសមាទាយ ចរណំ ។ នាមេន អធិដ្ឋិតានំ តិណ្ណំ ចីវរានំ អញ្ញតរំ ចីវរំ យត្ថកត្ថចិ និក្ខិបិត្វា អញ្ញស្មិំ អរុណុ-ឧគ្គមនន្តិ អត្ថោ** ។ អំពើដែលភិក្ខុត្រេចទៅមិនបាច់នាំយកចីវរ ៣ ដែលអធិដ្ឋានហើយជាប់ជា មួយនឹងខ្លួនទៅផង ហៅថា អសមាទានចារោ បានដល់ការដែលភិក្ខុលះ ទុកចីវរទាំង ៣ ដែលបានអធិដ្ឋានតាមឈ្មោះរួចហើយ ចីវរណា ១ ក្នុងទីណា១ ហើយទៅញុំាងអរុណឱ្យរះឡើងក្នុងទីឯទៀត។ ក្នុងគម្ពីរដដែលលោកកែផ្ដាច់ថា: **ចីវរវិប្បវាសោតិ ទុត្តំ ហោតិ** ។ ពាក្យថា "អសមា-ទានចារោ" លោកពោលកាត់យកតែរូបសេចក្ដី សំដៅយកការដែលនៅប្រាសចាកចីវរបាន ។ ក្នុងគម្ពីរវិនយាលង្ការដីកាលោកកែត្រួតមកទៀតថា: **ចីវរវិប្បវាសោតិ តិណ្ណំ ចីវរានំ អញ្ញតរេន វា សព្វេន វា**



**វិនា ហត្ថបាសេ អកត្វា អរុណុដ្ឋាបនំ ឯវំ ករោន្តោបិ ទុតិយកថិនសិក្ខាបទេន អាបត្តិ ន ហោតីតិ អធិប្បាយោ**។ ការដែលភិក្ខុវៀរបង់ចីវរទាំង ៣ ណា ១ ក្ដី ទាំងអស់ក្ដី មិនធ្វើឱ្យនៅក្នុងហត្ថបាសហើយញុំាងអរុណឱ្យរះឡើង ហៅថា នៅប្រាសចាកចីវរ ។ **អធិប្បាយ**ថា: បើទុកជាភិក្ខុធ្វើអំពើយ៉ាងនេះក៏មិនត្រូវអាបត្តិដោយទុតិយកថិនសិក្ខាបទឡើយ ។

អានិសង្សទី ៣ អដ្ឋកថា កែចេញទៅថា: **គណភោជនន្តិ គណភោជនម្បិ កប្បិស្សតិ** ។ ពាក្យថា: "គណភោជនំ" បានសេចក្ដីថា: គណភោជននឹងបែរជាគួរ គឺថានឹងឆាន់គណភោជនបានមិនមានអាបត្តិ ។ ក្នុងមហាវិភង្គលោកកែអំពីគណភោជនថា: **គណភោជនំ នាម យត្ថ ចត្តារោ ភិក្ខូ បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតា ភុញ្ជន្តិ ឯតំ គណភោជនំ នាម ។** ដែលហៅថា "គណភោជន" (នោះ) ដូច្នេះ: ភិក្ខុទាំងឡាយ៤ រូបទាយក គេនិមន្តដោយភោជន ៥ ភោជនណា ១ ទទួលឆាន់ភោជនណាភោជននុ៎ះ ហៅថា គណភោជន។ ក្នុងគម្ពីរធម្មសមុហវិនយកែថា: **គណភោជនន្តិ គណស្ស ភោជនំ គណភោជនំ ខលខ សហ គហណន្តិ អត្ថោ** ។ ភោជនរបស់គណៈ ហៅថា គណភោជន ក្នុងបទថា "គណភោជនំ" ដូច្នេះ ហើយ

ពាក្យថា "គណៈ" ក្នុងទីនេះសំដៅយកភិក្ខុ ៤ រូប ឬច្រើនជាង ៤ រូបឡើងទៅ រួបរួមសេចក្តីមកថា: ការដែលភិក្ខុទាំងនោះទទួលភោជន ៥ មានបាយជាដើម ភោជនណា ១ ជាមួយគ្នា ដោយការសូមខ្លួនឯងក្តី ដោយការនិមន្តរបស់ទាយកក្តីហៅថា គណភោជន ។ ក្នុងគម្ពីរវិនយាលង្ការដីកាលោកកែថា: **តត្ថ គណភោជនំ នាម ចតុន្នំ ឯកតោ-ភុញ្ជនំ** ។ ការដែល ភិក្ខុសូមគេថា "ចូរអ្នកប្រគេនភត្តដល់យើងទាំងឡាយ" ដូច្នេះក្តី ទាយកគេនិមន្តដោយអកប្បិយវោហារថា "សូមលោកទាំងឡាយទទួលភត្តរបស់យើងខ្ញុំ" ដូច្នេះក្តី ហើយភិក្ខុ ៤ រូបឬច្រើនជាង ៤ រូបទៅទទួលភត្តនោះជាមួយគ្នា យកមកឆាន់ជាមួយគ្នា ហៅថាគណភោជន ក្នុងបទនោះ ។ ក្នុងគម្ពីរដដែលនិងគម្ពីរបាឡិមុត្តកវិនយវិនិច្ឆ័យកែថា: **គណភោជនន្តិ គណភោជនសិក្ខាបទេន អនាបត្តិ វុត្តា ច** កាលដែលមិនមានអាបត្តិ ដោយគណភោជនសិក្ខាបទ លោកពោលថា "គណភោជនំ" ដូច្នេះ ។

អានិសង្សទី ៤ អដ្ឋកថាកែចេញទៅថា: **យាវទត្ថចីវរន្តិ យាវតកេន ចីវរេន តាវតកំ អនធិដ្ឋិតំ អវិកប្បិតំ កប្បិស្សតីតិ អត្ថោ** ។ ពាក្យថា "យាវទត្ថចីវរំ" ដូច្នេះបានសេចក្តីថា: សេចក្តីត្រូវការដោយចីវរចំនួនប៉ុន្មាន ចីវរចំនួនប៉ុណ្ណោះទោះបីមិនបានអធិដ្ឋាន មិនបានវិកប្បក៏គួរ គឺថានឹងមិនមានអាបត្តិឡើយ ។ ក្នុងគម្ពីរ



ធម្មសមុហវិនយកែថា: **យាវទត្ថចីវរន្តិ យាវតា ចីវរេន អត្ថោ ហោតិ តាវតកំ អនធិដ្ឋិតអវិកប្បិតចីវរធារណំ ឧស្សាហំ អតិក្កមិត្វា ចីវរឋបនន្តិ អត្ថោ** ។ ពាក្យថា "យាវទត្ថចីវរំ" ដូច្នេះបានសេចក្តីថា: សេចក្តីត្រូវការដោយចីវរចំនួនប៉ុន្មាន ។

ការទ្រទ្រង់ចីវរដែលមិនបានអធិដ្ឋាន មិនបានវិកប្បប៉ុណ្ណោះបាន គឺថា ទុកដាក់ចីវរដែលមិនបានអធិដ្ឋានមិនបានវិកប្បចំនួនប៉ុណ្ណោះឱ្យកន្លង ១០ថ្ងៃបាន ។ ក្នុងគម្ពីរបាឡិមុត្តកវិនយវិនិច្ឆ័យ កែស្របគ្នានឹងអដ្ឋកថា ប្លែកតែរបព្យញ្ជន១ ម៉ាត់ខាងចុងថា "វដ្តតិ" ប៉ុណ្ណោះ ។ ក្នុងគម្ពីរវិនយាលង្ការ-ដីកាអធិប្បាយពាក្យនោះចេញទៅទៀតថា: **អនធិដ្ឋិតំ អវិកប្បិតំ វដ្ដតីតិ បឋមកឋិនសិក្ខាបទេន អាបត្តិ ន ហោតីតិ អធិប្បាយោ** ។ ពាក្យ ថា: "អនធិដ្ឋិតំ អវិកប្បិតំ វដ្តតិ" ដូច្នេះអធិប្បាយថា មិនមានអាបត្តិដោយបឋមកឋិនសិក្ខាបទ ។

អានិសង្សទី ៥ អដ្ឋកថាកែចេញទៅថា: **យោ ច តត្ថ ចីវរុប្បាទោតិ តត្ថ កឋិនត្ថតសីមាយំ មតកចីវរំ វា ហោតុ សង្ឃំ ឧទ្ទិស្ស ទិន្នំ វា សង្ឃិកេន តត្រុប្បាទេន អាភតំ**[១] **វា យេន**

១-ក្នុងគម្ពីរសារត្ថទីបនីដីកា នឹងគម្ពីរធម្មសមុហវិនយកែថា: តត្រុប្បាយទេន អាភតន្តិ [illegible]ការសន្តកេន ខេត្តវត្ថុអាទិនា អានីតំ ។ ក្នុងគម្ពីរវិនយាលង្ការដីកា កែថា:តត្រុប្បាទេនាតិ [illegible]កេន អារាមុយ្យានខេត្តវត្ថុអាទិនា ។

**កេនចិ អាការេន យំ សង្ឃិកំ ចីវរំ ឧប្បជ្ជតិ តំ តេសំ ភវិស្សតីតិ អត្ថោ** ។ ពាក្យថា "យោចតត្ថចីវរុប្បាទោ" ដូច្នេះ បានសេចក្ដីថា: ចីវររបស់ភិក្ខុ-សាមណេរដែលធ្វើមរណកាលក្ដី ចីវរដែលគេប្រគេនចំពោះសង្ឃក្ដី ចីវរដែលគេនាំមកដោយទ្រព្យរបស់សង្ឃដែលកើតឡើងក្នុងឧបចារសីមានោះ មានឈ្នួលឬដីឡៃសួនច្បារស្រែចម្ការសំរាប់វត្តជាដើមក្ដី សង្ឃិកចីវរឯណាកើតឡើងដោយអាការឯណានីមួយ ក្នុងឧបចារសីមាដែលក្រាលកឋិននោះ ចីវរទាំងនោះ នឹងត្រូវបានដល់ភិក្ខុដែលបានក្រាលកឋិនទាំងប៉ុន្មាននោះ ។ ក្នុងគម្ពីរវជិរពុទ្ធដីការ នឹងគម្ពីរធម្មសមុហវិនយ កែវិសេសឡើងទៀតថា: **យំ បន តត្ថ សង្ឃស្ស ឧប្បន្នំ បត្តាទិកំ អញ្ញំ ភណ្ឌំ តំ សព្វេសំ បាបុណាតិ យំ បន តត្រុប្បាទេន តណ្ឌុលាទិនាវត្ថេសុ ចេតាបិតេសុ តេសំ អត្ថតកឋិនានមេវ តានិ វត្ថានិ បាបុណន្តិ វត្ថេហិ បន តណ្ឌុលាទីសុ ចេតាបិតេសុ សព្វេសំ តានិ បាបុណន្តិ** ។ ទោះបិភណ្ឌឯទៀតមានបាត្រជាដើម ដែលកើតឡើងដល់សង្ឃក្នុងឧបចារសីមានោះ ក៏ត្រូវបានដល់ភិក្ខុដែលបានក្រាលកឋិនទាំងអស់អង្គ ទាំងសំពត់ដែលសង្ឃចាត់ ឱ្យគេប្ដូរដោយអង្ករជាដើម ដែលកើតឡើងក្នុងឧបចារសីមានោះ ក៏ត្រូវបានដល់ភិក្ខុដែលបានក្រាលកឋិនទាំងនោះដែរ ឬអង្ករជាដើមដែលសង្ឃចាត់ឱ្យគេប្ដូរដោយសំពត់វិញ ក៏ត្រូវបានដល់ភិក្ខុដែលបានក្រាលកឋិនទាំងអស់អង្គ ។ ក្នុងគម្ពីរវិនយាលង្ការដីកាកែថា: **តតោ អញ្ញំ**



**បិណ្ឌបាតភេសជ្ជាទិកំ អាគតាគតស្ស សង្ឃស្ស សន្តកំ ហោតិ** ។ **វត្ថុដទៃ**អំពីនោះមានបិណ្ឌបាតនិងភេសជ្ជជាដើម ត្រូវបានជារបស់សង្ឃ**ដែលនិ**មន្តមកទាំងប៉ុន្មាន គឺថាត្រូវចែករំលែកប្រើការទូទៅបាន ។

សេចក្ដីបំព្រួញ: អានិសង្សទាំង ៥ ប្រការនេះ ត្រូវដឹងយ៉ាងខ្លីថា**អាចឱ្យ**សម្រេចប្រយោជន៍ដល់ភិក្ខុអ្នកក្រាល និងភិក្ខុអ្នកអនុមោទនា ក្នុង**វេលា**ដែលកឋិនមិនទាន់ដោះដូច្នេះ :

**ទី** ១ ឱ្យរួចចាកអាបត្តិក្នុងចារិត្តសិក្ខាបទទី ៦ ក្នុងអចេលកវគ្គ (**សុទ្ធិក**បាចិត្តិយ) ។

**ទី** ២ ឱ្យរួចចាកអាបត្តិក្នុងទុតិយកឋិនសិក្ខាបទទី ២ ក្នុងចីវរវគ្គ (**និស្សគ្គិយ**បាចិត្តិយ) ។

**ទី** ៣ ឱ្យរួចចាកអាបត្តិ ក្នុងគណភោជនសិក្ខាបទទី ២ ក្នុងភោជនវគ្គ (**សុទ្ធិក**បាចិត្តិយ) ។

**ទី** ៤ ឱ្យរួចចាកអាបត្តិក្នុងបឋមកឋិនសិក្ខាបទទី ១ ក្នុងចីវរវគ្គ (**និស្សគ្គិយ**បាចិត្តិយ) ។

**ទី** ៥ ឱ្យបានចំណែកលាភ ដែលកើតឡើងក្នុងអាវាសនោះ[១] ។

---

**១-ក្នុងគម្ពីរ**និបុណ្ណបទសង្គហស់ដែងថា: បរម្បរភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ល។ **[illegible]** បាចិត្តិយ បាទ្បិ ។ តស្មា បរម្បរភោជនសិក្ខាបទេន សទ្ធឹ ឆ កឋិនានិសំសា ហោន្តិ ។

ពណ៌នាមកអំពីអានិសង្ស ៥ ប្រការអស់សេចក្តីតែប៉ុណ្ណោះ ។

បញ្ចានិសំសកថា ចប់

---

អថ កស្មា ភគវតា មហាវគ្គេ បញ្ច កប្បិស្សន្តីតិ វុត្តំ ។ តំ វីមំសិតព្វំ មយំ បន បញ្ចានិសំសា ភគវតា មហាវគ្គេ បឋមំ បញ្ញត្តា បរម្បរភោជនសិក្ខាបទំ បាចិត្តិយបាលិយំ បច្ឆា បញ្ញត្តំ តស្មា តេន សទ្ធឹ ឆ កឋិនានិសំសា ហោន្តីតិ ចិន្តេម ឥតរថា បរម្បរភោជនសិក្ខាបទេ បញ្ញត្តោ កឋិនានិសំសោ អនត្ថិកោ ភវេយ្យ សចេ តំ បិណ្ឌតានំ រុច្ចតិ គហេតព្វំ យុត្តតរំ គវេសិតព្វន្តិ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយៈ ព្រោះឆាន់បរម្បរភោជន (ភោជនដទៃរបស់ទាយកដទៃ គឺ ភិក្ខុទទួលនិមន្តទាយកដោយភោជន ៥ ណា ១ រួចហើយមិនទៅឆាន់ភោជននោះរបស់ទាយកនោះ បែរជាទៅឆាន់ភោជន ៥ ណា ១ ដទៃរបស់ទាយកដទៃ) លើកលែងតែមានសម័យ ។ សម័យគួរឆាន់បរម្បរភោជននោះបានដូច្នេះគឺ: គិលានសម័យ ១ ចីវរទានសម័យ១ ចីវរកាលសម័យ ១ នេះជាសម័យគួរឆាន់បរម្បរភោជននោះបាន ។ ដែលហៅថា "ចីវរទានសម័យ" ដូច្នេះ: កាលបើភិក្ខុមិនបានក្រាលកឋិន ចីវរទានមានតែ ១ ខែ គឺខែ ១ ជាខាងចុងនៃវស្សានរដូវ កាលបើបានក្រាលកឋិនមានដល់ ៥ ខែ សម័យប៉ុណ្ណោះគួរភិក្ខុឆាន់បរម្បរភោជនបាន ដូច្នេះជាបាចិត្តិយបាឡិ ។ ព្រោះហេតុនោះ អានិសង្សរបស់កឋិនមានដល់ ៦ ព្រមទាំងបរម្បរភោជនសិក្ខាបទផង ។ (សួរថាៈ) កាលបើយ៉ាងនេះព្រោះហេតុអ្វី ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកក្នុងគម្ពីរមហាវគ្គថា "បញ្ច កប្បិស្សន្តិ" ដូច្នេះ ។ (ឆ្លើយថាៈ) សេចក្តីនោះ ត្រូវពិចារណាមើលផងចុះ ចំណែកយើងទាំងឡាយគិតឃើញថា "អានិសង្ស ៥ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តក្នុងគម្ពីរមហាវគ្គលើកមុន ឯបរម្បរភោជនសិក្ខាបទ ព្រះអង្គទ្រង់បញ្ញត្តក្នុងបាចិត្តិយ-ភោជនសិក្ខាបទនោះផង" បើខុសពីនេះទេ មានតែអានិសង្សរបស់កឋិនដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តក្នុងបរម្បរភោជនសិក្ខាបទទៅជាឥតប្រយោជន៍ សេចក្តីនោះបើគាប់ចិត្តដល់បណ្ឌិតទាំងឡាយគប្បីកាន់យកចុះ ឬត្រូវស្វែងរកមើលតទៅទៀតក៏ជាការគួរដែរ ។



# កឋិនត្ថារវិធានកថា

បន្ទាប់នេះនឹងពណ៌នាអំពីវិធីក្រាលកឋិនតទៅ តាមលំអាននៃពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គថា: **ឯវញ្ច បន ភិក្ខវេ កឋិនំ អត្ថរិតព្វំ** ។ ម្នាលភិក្ខុទាំងឡាយត្រូវភិក្ខុក្រាលកឋិនបែបនេះ ។

ក៏ក្នុងកថានេះ មានពាក្យក្នុងអដ្ឋកថា-ដីកា ព្រមទាំងបករណវិសេសឯទៀតៗ ដែលលោកពោលបន្ថែមមកជាអធិកហើយសុទ្ធតែជាពាក្យបានការគ្រប់អន្លើ ហេតុនោះខាងដើមនេះនឹងស្រង់យកពាក្យទាំងនោះមកពណ៌នាតាមការគួរ ។

សួរថា: បុគ្គលពួកណាទើបទទួលក្រាលកឋិន បុគ្គលពួកណាទទួលក្រាលមិនបាន ។

ឆ្លើយថា: តាមអដ្ឋកថាលោកកែថា: **គណនវសេន តាវ បច្ឆិមកោដិយា បញ្ច ជនា លភន្តិ ឧទ្ធំ សតសហស្សម្បិ បញ្ចន្នំ ហេដ្ឋា ន លភន្តិ ។ វុត្ថវស្សវសេន បុរិមិកាយ វស្សំ ឧបគន្ត្វា បឋមបវារណាយ បវារិតា លភន្តិ ឆិន្នវស្សា វា បច្ឆិមិកាយ ឧបគតា វា ន លភន្តិ អញ្ញស្មឹ វិហារេ វុត្ថវស្សាបិ ន លភន្តិ** ។ បើនិយាយដោយ ចំនួនកំណត់យ៉ាងចុងបំផុតឱ្យបានត្រឹមជន ៥ រូប គឺភិក្ខុ៥អង្គ ទើបទទួល

ក្រាលកឋិនបាន ខាងលើទៅសូម្បីដល់ ១ សែនអង្គក៏បាន កុំតែថយតិច ជាង ៥ អង្គចុះមកទទួលក្រាលមិនបានឡើយ ។ បើនិយាយដោយដំណើរ ចូលវស្សាវិញ ភិក្ខុដែលបានចូលបុរិមិកវស្សា បានបវារណាក្នុងថ្ងៃបឋម-បវារណា ( ១៥ កើត ខែអស្សុជ) ទើបទទួលក្រាលបាន ។ ភិក្ខុដែលដាច់វស្សាក្តី ដែលចូលបច្ឆិមិកវស្សាក្តី ទទួលក្រាលមិនបានឡើយ សូម្បីតែភិក្ខុដែលនៅចាំវស្សាក្នុងវត្តឯទៀត ក៏ទទួលក្រាលមិនបានដែរ ។

ត្រង់ដែលនិយាយពីចំនួន ក្នុងគម្ពីរវិនយាលង្ការដីកានិងគម្ពីរធម្ម-សមុហវិនយត្រូវគ្នាកែថា: **បញ្ច ជនា លភន្តិ បញ្ច ជនា សាធេន្តិ កឋិនទុស្សស្ស នាយកា បច្ឆិមកោដិយា ចត្តារោ ហោន្តិ ឯកោ បដិគ្គាហកោតិ** ។ ពាក្យថា "ជន ៥ រូប ទើបទទួលក្រាលកឋិនបាន" បានសេចក្តីថា: ជន ៥ រូបគឺភិក្ខុ ៥ អង្គទើបញុំាងកឋិនត្ថារកិច្ចឱ្យសម្រេចបាន ចាត់ ៤ អង្គឱ្យជាសង្ឃអ្នកប្រគល់សំពត់កឋិន ១ អង្គឱ្យជាអ្នកទទួលក្រាលត្រង់ដែលនិយាយពីចូលវស្សា និងបវារណា ក្នុងគម្ពីរដដែលលោកកែថា: **បឋមបវារណាយ បវារិតាតិ ឥទំ វស្សច្ឆេទំ អកត្វា វស្សំ វុដ្ឋភាវសន្ទស្សនត្ថំ វុត្តំ អន្តរាយេន អបវារិតានម្បិ វុដ្ឋវស្សានំ កឋិនត្ថារសម្ភវតោ ។ តេនេវ អប្បវារិតា វាតិ អវត្វា ឆិន្នវស្សា វា បច្ឆិមិកាយ ឧបគតា**



**វា ន លភន្តីតិ ឯត្តកមេវ វុត្តំ** ។ ពាក្យថា "បានបវារណាក្នុងថ្ងៃបឋមបវារណា" ដូច្នេះនេះព្រះអដ្ឋកថាចារ្យពោលទុក ដើម្បីសំដែងឱ្យឃើញដំណើរដែលភិក្ខុនៅចាំវស្សាមិនបានធ្វើឱ្យដាច់វស្សាប៉ុណ្ណោះទេ ព្រោះភិក្ខុដែលបាននៅចាំវស្សាគ្រប់គ្រាន់ហើយ តែមិនបានបវារណាដោយមានអន្តរាយក៏ក្រាលកឋិនបានដែរ ព្រោះហេតុនោះ ទើបលោកមិនបានពោលហាមដល់ភិក្ខុដែលមិនបានបវារណាថា "អប្បវារិតា វា" ដូច្នេះលោកពោលហាមតែភិក្ខុដែលដាច់វស្សានិងភិក្ខុដែលចូលបច្ឆិមិកវស្សា ថា "ឆិន្នវស្សា វា បច្ឆិមិកាយ ឧបគតា វា ន លភន្តិ" ប៉ុណ្ណោះឯង ។ ត្រង់ដែលនិយាយពីភិក្ខុនៅចាំវស្សាក្នុងវត្តឯទៀត ក្នុងគម្ពីរដដែលលោកកែថា: **អញ្ញស្មឹ វិហារេ វុដ្ឋវស្សាបិ ន លភន្តីតិ នានាសីមាយ សីមាយ អញ្ញស្មឹ វិហារេ វុដ្ឋវស្សា ឥមស្មឹ វិហារេ កឋិនត្ថារំ ន លភន្តីតិ អត្ថោ** ។ ពាក្យថា "សូម្បីភិក្ខុដែលនៅចាំវស្សាក្នុងវត្តឯទៀត ក៏ទទួលក្រាលកឋិនមិនបាន" បានសេចក្តីថា: ភិក្ខុដែលនៅចាំវស្សាក្នុងវត្តឯទៀតក្នុងសីមាផ្សេងៗ គ្មានឹងមកទទួលក្រាលកឋិនក្នុងវត្តនេះមិនបានឡើយ ។ ក្នុងគម្ពីរធម្មសមុហវិនយ កែវិសេសបន្តិចឡើងទៀតថា: **ឯកសីមស្មឹ វា នានាសីមស្មឹ វា នានូបចារេ អញ្ញស្មឹ វិហារេ វុដ្ឋវស្សាបិ ន លភន្តិ** ។ ឱ្យតែភិក្ខុដែលនៅចាំវស្សាក្នុងវត្តឯទៀត ដែលមានឧបចារ

ផ្សេងគ្នា ទោះបីមានសីមាជាមួយគ្នាក្តី មានសីមាផ្សេងគ្នាក្តី ក៏ទទួលក្រាលកឋិនខុសវត្តដែលខ្លួននៅចាំវស្សាមិនបានឡើយ ។ ក្នុងអដ្ឋកថា លោកពន្យល់ថា: **បុរិមិកាយ ឧបគតានម្បន សព្វេ បច្ឆិមិកា គណបូរកា ហោន្តិ អានិសំសំ ន លភន្តិ អានិសំសោ ឥតរេសំ យេវ ហោតិ** ។ បច្ឆិមិកភិក្ខុទាំងអស់អង្គ បើយកជាគណបូរកបញ្ចូលទៅនឹងភិក្ខុដែលបានចូលបុរិមិកវស្សាឱ្យគ្រប់ជាគណសង្ឃ ៥ អង្គបាន តែមិនត្រូវបានអានិសង្សទេ ឯអានិសង្សត្រូវបានតែភិក្ខុក្រៅពីនេះដែលបានចូលបុរិមិកវស្សាក្នុងទីវត្តនោះ ហើយមិនបានធ្វើឱ្យដាច់វស្សាផង ។ ក្នុងគម្ពីរវិនយាលង្ការដីកា កែចេញពីអដ្ឋកថាត្រង់ "សព្វេ" តទៅទៀតថា: **សព្វេតិ ឆិន្នវស្សានយោ អនុបគតាបិ ឯត្ថេវ សង្គហិតា** ។ ពាក្យ ដែលព្រះអដ្ឋកថាចារ្យពោលថា "សព្វេ" ដែលប្រែមកថា "ទាំងអស់អង្គ" ដូច្នេះស្រូបទាំងភិក្ខុប៉ុន្មានពួកដែលហាមខាងដើម មានភិក្ខុដែលដាច់វស្សាជាដើមចូលមកផង ទាំងភិក្ខុដែលមិនបានចូលវស្សាសោះ ក៏សង្គ្រោះចូលក្នុងពាក្យនុ៎ះដែរ ។ ក្នុងគម្ពីរដដែលលោកពន្យល់មួយកន្លែងទៀតថា: **តេ ឆិន្នវស្សានយោ បញ្ចានិសំស-ហេតុភូតំ កឋិនត្ថារំ ន លភន្តិ ញត្តិទុតិយកម្មេ បន ចតុវគ្គ សង្ឃបូរកភាវំ លភន្តិ ។ តេ ឯវ· ឆិន្នវស្សានយោ**



**គណបូរកេ កត្វា ញត្តិទុតិយកម្មវាចាយ កឋិនទុស្សំ ទាបេត្វា បុរិមិកាយ ឧបគតេហិបិ កឋិនស្ស អត្ថារិតព្វភាវតោ** ។ ភិក្ខុដែលដាច់វស្សាជាដើមទាំងអម្បាលនោះមិនត្រូវបានក្រាលកឋិន ដែលជាហេតុនឹងឱ្យបាននូវអានិសង្សទាំង ៥ ទេ តែបើយកមកបង្គ្រប់ជាសង្ឃចតុវគ្គក្នុងវិធីសូត្រញត្តិទុតិយកម្មវាចាបាន ។ ព្រោះកឋិនត្រូវតែភិក្ខុដែលចូលបុរិមិកវស្សា យកភិក្ខុដែលដាច់វស្សាជាដើមទាំងអម្បាលនោះឯង មកធ្វើជាគណបូរកឱ្យសូត្រប្រគល់សំពត់កឋិនដោយញត្តិទុតិយកម្មវាចាឱ្យសិនសឹមក្រាល (បើភិក្ខុដែលចូលបុរិមិកវស្សានោះមិនគ្រប់៥អង្គ) ។ ហេតុនោះភិក្ខុពួកណាក៏យកធ្វើជាគណបូរកបានដូចគ្នា កុំតែទាមយកចំណែកចីវរជាដើម ។ ត្រង់ពាក្យក្នុងអដ្ឋកថា ថា "អានិសំសំ" ដែលប្រែមកថា "អានិសង្ស" ដូច្នេះក្នុងគម្ពីរដដែលនោះលោកកែថា: **អានិសំសន្តិ កឋិនានិសំសចីវរំ ។ ឯកំ អត្ថតចីវរំ យេវ ហិ កឋិនចីវរំ នាម ហោតិ អវសេសានិ ចីវរានិ វា សាដកា វា កឋិនានិសំសា យេវ នាម ។** ពាក្យថា "អានិសង្ស" សំដៅយកចីវរដែលជាអានិសង្សរបស់កឋិន ។ សេចក្តីថា: ដែលហៅថា "កឋិនចីវរ" ចំពោះតែ ចីវរ ១ ដែលភិក្ខុក្រាលកឋិនប៉ុណ្ណោះ ចីវរសល់ពីនោះទាំងប៉ុន្មានក្តី សំពត់សាដកទាំងប៉ុន្មានក្តី ហៅថា អានិសង្សរបស់កឋិនទាំងអស់ ។ ក្នុងអដ្ឋកថាលោកពោលប្រាប់វិធីបញ្ចូលគណបូរកដូច្នេះថា: **សចេ បុរិមិកាយ**

ផ្សេងគ្នា ទោះបីមានសីមាជាមួយគ្នាក្តី មានសីមាផ្សេងគ្នាក្តី ក៏ទទួលក្រាលកឋិនខុសវត្តដែលខ្លួននៅចាំវស្សាមិនបានឡើយ ។ ក្នុងអដ្ឋកថា លោកពន្យល់ថា: **បុរិមិកាយ ឧបគតានម្បន សព្វេ បច្ឆិមិកា គណបូរកា ហោន្តិ អានិសំសំ ន លភន្តិ អានិសំសោ ឥតរេសំ យេវ ហោតិ** ។ បច្ឆិមិកភិក្ខុទាំងអស់អង្គ បើយកជាគណបូរកបញ្ចូលទៅនឹងភិក្ខុដែលបានចូលបុរិមិកវស្សាឱ្យគ្រប់ជាគណសង្ឃ ៥ អង្គបាន តែមិនត្រូវបានអានិសង្សទេ ឯអានិសង្សត្រូវបានតែភិក្ខុក្រៅពីនេះដែលបានចូលបុរិមិកវស្សាក្នុងទីវត្តនោះ ហើយមិនបានធ្វើឱ្យដាច់វស្សាផង ។ ក្នុងគម្ពីរវិនយាលង្ការដីកា កែចេញពីអដ្ឋកថាត្រង់ "សព្វេ" តទៅទៀតថា: **សព្វេតិ ឆិន្នវស្សាទយោ អនុបគតាបិ ឯត្ថេវ សង្គហិតា** ។ ពាក្យ ដែលព្រះអដ្ឋកថាចារ្យពោលថា "សព្វេ" ដែលប្រែមកថា "ទាំងអស់អង្គ" ដូច្នេះស្រូបទាំងភិក្ខុប៉ុន្មានពួកដែលហាមខាងដើមមានភិក្ខុដែលដាច់វស្សាជាដើមចូលមកផង ទាំងភិក្ខុដែលមិនបានចូលវស្សាសោះ ក៏សង្គ្រោះចូលក្នុងពាក្យនុ៎ះដែរ ។ ក្នុងគម្ពីរដដែលលោកពន្យល់មួយកន្លែងទៀតថា: **តេ ឆិន្នវស្សាទយោ បញ្ចានិសំស- ហេតុភូតំ កឋិនត្ថារំ ន លភន្តិ ញត្តិទុតិយកម្មេ បន ចតុវគ្គ សង្ឃបូរកភាវំ លភន្តិ ។ តេ ឯវ ឆិន្នវស្សាទយោ**



**គណបូរកេ កត្វា ញត្តិទុតិយកម្មវាចាយ កឋិនទុស្សំ ទាបេត្វា បុរិមិកាយ ឧបគតេហិបិ កឋិនស្ស អត្ថារិតត្តាភាវតោ** ។ ភិក្ខុដែលដាច់វស្សាជាដើមទាំងអម្បាល្មោះមិនត្រូវបានក្រាលកឋិន ដែលជាហេតុនឹងឱ្យបាននូវអានិសង្សទាំង ៥ ទេ តែបើយកមកបង្គ្រប់ជាសង្ឃចតុវគ្គក្នុងវិធីសូត្រញត្តិទុតិយកម្មវាចាបាន ។ ព្រោះកឋិនត្រូវតែភិក្ខុដែលចូលបុរិមិកវស្សា យកភិក្ខុដែលដាច់វស្សាជាដើមទាំងអម្បាល្មោះឯង មកធ្វើជាគណបូរកឱ្យសូត្រប្រគល់សំពត់កឋិនដោយញត្តិទុតិយកម្មវាចាឱ្យសិនសឹមក្រាល (បើភិក្ខុដែលចូលបុរិមិកវស្សានោះមិនគ្រប់៥អង្គ) ។ ហេតុនោះភិក្ខុពួកណាក៏យកធ្វើជាគណបូរកបានដូចគ្នា កុំតែទាមយកចំណែកចីវរជាដើម ។ ត្រង់ពាក្យក្នុងអដ្ឋកថា ថា "អានិសំសំ" ដែលប្រែមកថា "អានិសង្ស" ដូច្នេះក្នុងគម្ពីរដដែលនោះលោកកែថា: **អានិសំសន្តិ កឋិនានិសំសចីវរំ ។ ឯកំ អត្ថតចីវរំ យេវ ហិ កឋិនចីវរំ នាម ហោតិ អវសេសានិ ចីវរានិ វា សាដកា វា កឋិ- នានិសំសា យេវ នាម ។** ពាក្យថា "អានិសង្ស" សំដៅយកចីវរដែលជាអានិសង្សរបស់កឋិន ។ សេចក្តីថា: ដែលហៅថា "កឋិនចីវរ" ចំពោះតែ ចីវរ ១ ដែលភិក្ខុក្រាលកឋិនប៉ុណ្ណោះ ចីវរសល់ពីនោះទាំងប៉ុន្មានក្តី សំពត់សាដកទាំងប៉ុន្មានក្តី ហៅថា អានិសង្សរបស់កឋិនទាំងអស់ ។ ក្នុងអដ្ឋកថាលោកពោលប្រាប់វិធីបញ្ចូលគណបូរកដូច្នេះថា: **សចេ បុរិមិកាយ**

**ឧបគតា ចត្តារោ វា ហោន្តិ តយោ វា ទ្វេ វា ឯកោ វា ឥតរេ គណបូរកេ កត្វា កឋិនំ អត្ថរិតព្វំ** ។ បើភិក្ខុដែលចូលបុរិមិកវស្សាមានតែត្រឹម ៤ អង្គក្តី ៣ អង្គក្តី ២ អង្គ[(១)] ក្តី ត្រូវយកភិក្ខុក្រៅពីនេះដែលដាច់វស្សាក្តី ចូលបច្ឆិមិកវស្សាក្តី មិនបានចូលវស្សាសោះក្តី ចូលវស្សាក្នុងវត្តឯទៀតក្តី មកធ្វើជាគណបូរកបង្គ្រប់ឱ្យបានជាគណសង្ឃ ៥ អង្គសិនសឹមក្រាលកឋិន[(២)] ។ ក្នុងគម្ពីរវិនយាលង្ការដីកាសំដែងថា: **ឧបចារសីមាយ បរិច្ឆិន្នេ វិហារេ ឯកោ វា ទ្វេ វា តយោ វា ចត្តារោ វា ភិក្ខូ វិហរន្តិ តត្ថ កឋិនចីវរេ ឧប្បន្នេ អញ្ញតោ បរិយេសិត្វា ចតុវគ្គសង្ឃោ ឯកោ បដិ-គ្គាហកោតិ បញ្ចន្នំ ភិក្ខូនំ បូរណេ សតិ កឋិនំ អត្ថរិតុំ លភតិ នាសតិ** ។ បើនៅវត្តដែលកំណត់ដោយឧបចារសីមា មានភិក្ខុនៅតែ ១ អង្គក្តី ២ អង្គក្តី ៣ អង្គក្តី ៤អង្គក្តី កាលបើមានកឋិនចីវរកើតឡើងក្នុងវត្តនោះ ត្រូវស្វែងរកភិក្ខុអំពីវត្តឯទៀតមកបង្គ្រប់ជា ៥ អង្គ ឱ្យបាន ៤ អង្គជាសង្ឃចតុវគ្គសម្រាប់ប្រគល់សំពត់កឋិន ១ អង្គជាអ្នកទទួលក្រាល[(៣)] ធ្វើដូច្នេះទើបក្រាលកឋិនបាន បើមិនធ្វើដូច្នេះទេក្រាលកឋិនមិន

១-តាមទំនងនេះគួរសន្និដ្ឋានសេចក្តីដោយឡែកទៀតថា: កឋិននេះបើមានតែភិក្ខុអ្នកក្រាលមិនចាំបាច់មានភិក្ខុអ្នកអនុមោទនាក៏គង់ឡើងជាកឋិនដែរ ព្រោះភិក្ខុដែលយកមកធ្វើជាគណបូរកទាំងប៉ុន្មានលោកហាមមិនឱ្យអនុមោទនាទេ (មើលទំព័រ៥៦-៥៧-៥៨ទៀត) ។ ២-ពាក្យនេះចំពោះតែត្រង់សូត្រទានកម្មវាចាទេ ។ ៣- ត្រូវឱ្យភិក្ខុអ្នកអាវាសជាអ្នកទទួលក្រាលទើបបាន ។



**បាន**ឡើយ ។ ក្នុងអដ្ឋកថាលោកពន្យល់តទៅទៀតថា: **អថ ចត្តារោ ភិក្ខូ ឧបគតា ឯកោ បរិបុណ្ណវស្សោ សាមណេរោ សោ ចេ បច្ឆិមិកាយ ឧបសម្បជ្ជតិ គណបូរកោ ចេវ ហោតិ អានិសំសញ្ច លភតិ ។** ពុំនោះបើភិក្ខុដែលចូលបុរិមិកវស្សាមានតែ **៤ អង្គ**ហើយមានសាមណេរ ១ អង្គមានឆ្នាំគ្រប់ ២០ បើសាមណេរនោះឧបសម្បទឡើងក្នុងរវាងបច្ឆិមិកវស្សា យកជាគណបូរកបានផង អានិសង្សក៏បានផង ។ ក្នុងគម្ពីរធម្មសមុហវិនយ កែថា: **បច្ឆិមិកាយ ឧបសម្ប-ន្នោ បឋមបវារណាយ បវារេតុំបិ លភតិ អវស្សិកោ ច ហោតិ អានិសំសញ្ច លភតិ** ។ ភិក្ខុដែលទើបឧបសម្បទឡើងពីសាមណេរក្នុងរវាងបច្ឆិមិកវស្សា និងបវារណាក្នុងថ្ងៃ បឋមបវារណាផងក៏បាន ហើយបើទុកជាឧបសម្បទមិនទាន់បាន ១ វស្សាដូច្នេះក៏គួរបានអានិសង្សកឋិនដែរ ។ ក្នុងគម្ពីរវិនយាលង្ការដីកាកែវិសេសជាងនេះតទៅទៀតថា: **ឥមិនា សាមណេរានំ វស្សូបគមនំ អនុញ្ញាតំ ហោតិ ។ សោបិ បុរិមិកាយ វស្សូបគតត្តា អានិសំសំ លភតិ បច្ឆិមិកាយ បន ឧបសម្ប-ជ្ជិតត្តា គណបូរកោ ហោតិ** ។ ដំណើរដែលសាមណេរទាំងឡាយ ត្រូវចូលវស្សាព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតដោយរឿងនេះ ។ មែនពិតភិក្ខុថ្មីនោះបាន

ជាត្រូវបានអានិសង្ស. ព្រោះបានចូលបុរិមិកវស្សាពីសាមណេរមកហើយ ដែលគួរយកធ្វើជាគណបូរកបាន ព្រោះបានឧបសម្បទឡើងជាភិក្ខុក្នុងរវាងបច្ឆិមិកវស្សានោះ ។ វិធីដែលត្រូវឱ្យឧបសម្បទសាមណេរជាភិក្ខុ ហើយបញ្ចូលជាគណបូរកនោះមិនត្រឹមតែ ១ រូបប៉ុណ្ណោះទេ ក្នុងអដ្ឋកថាលោកចាត់ទុកជារបៀបដូច្នេះថា: **តយោ ភិក្ខូ ទ្វេ សាមណេរា ទ្វេ ភិក្ខូ តយោ សាមណេរា ឯកោ ភិក្ខុ ចត្តារោ សាមណេរាតិ ឯត្ថាបិ ឯសេវ នយោ** ។ បើមានភិក្ខុ ៣ អង្គត្រូវបញ្ចូលសាមណេរ ២ អង្គ ភិក្ខុ ២ អង្គ សាមណេរ ៣ អង្គ ភិក្ខុ ១ អង្គ សាមណេរ ៤ អង្គឱ្យតែបានគ្រប់ ៥ អង្គ តែត្រូវរើសរកសាមណេរដែលមានឆ្នាំគ្រប់ ២០ ហើយបានចូលបុរិមិកវស្សាផង មកឱ្យឧបសម្បទក្នុងរវាងបច្ឆិមិកវស្សាដូចជាក្នុងន័យមុននុ៎ះដែរ ។ ក្នុងអដ្ឋកថាដដែល លោកពន្យល់តទៅទៀតថា: **សចេ បុរិមិកាយ ឧបគតា កឋិនត្ថារកុសលា ន ហោន្តិ អត្ថកុសលា ខន្ធកភាណកត្ថេរា បរិយេសិត្វា អានេតព្វា កម្មវាចំ សាវេត្វា កឋិនំ អត្ថរាបេត្វា ទានញ្ច ភុញ្ជិត្វា គមិស្សន្តិ ។ អានិសំសោ បន ឥតរេសំ យេវ ហោតិ** ។ បើភិក្ខុដែលបានចូលបុរិមិកវស្សា ទាំងប៉ុន្មានមិនមានលោកដែលប្រសប់វៀងវៃខាងក្រាលកឋិនសោះ ត្រូវឱ្យស្វែងរក



លោកជាថេរអ្នកចេះចាំខន្ធកដែលជាអ្នកប្រសប់វៀងវៃខាងក្រាលកឋិននាំលោកយកមកឱ្យជួយសូត្រកម្មវាចា បង្ហាញក្រាលកឋិន ត្រាតែបានសម្រេចចុះ តែព្រះថេរដែលនិមន្តមកពីខាងក្រៅទាំងប៉ុន្មាន ត្រូវបរិភោគតែទានហើយត្រឡប់ទៅវិញចុះ មិនត្រូវទាមចំណែកសំពត់ដែលជាអានិសង្សរបស់កឋិនឡើយ ឯសំពត់ដែលជាអានិសង្សរបស់កឋិនត្រូវបានតែភិក្ខុអ្នករវាវាសប៉ុណ្ណោះឯង ។

ក្នុងគម្ពីរវិនយវិនិច្ឆ័យ លោកសំដែងថា: **អដ្ឋធម្មកោវិទោ ភិក្ខុ កឋិនត្ថារមរហតិ** ។ ភិក្ខុដែលជាអ្នកឈ្លៀសវៃក្នុងធមិ៨ប្រការទើបគួរក្រាលកឋិនបាន (បើមិនឈ្លៀសវៃទេមិនគួរក្រាលកឋិនបានឡើយ) ។ រឿងនោះក្នុងគម្ពីរដដែលលោកចងជាគាថាទុកឱ្យងាយទន្ទេញចាំដូច្នេះ :

**អដ្ឋធម្មកោវិទោ ភិក្ខុ កឋិនត្ថារមរហតិ**
**បចឆរាធិដ្ឋាន តារោ បលិពោធោ**
**ច ឧព្ភារោ[១] អានិសំសោ បនដ្ឋិមេ ៕**

ភិក្ខុដែលជាអ្នកឈ្លាសវៃក្នុងធមិ ៨ ប្រការ ទើបគួរក្រាលកឋិនបាន ។ បុព្វករណ ១ បច្ចុទ្ធារ ១ អធិដ្ឋាន ១ អត្ថារ ១ មាតិកា ១ បលិពោធ ១ ឧព្ភារ ១ អានិសង្ស ១ ទាំងនេះជាធមិ៨ប្រការ[២] ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកបង្គាប់ថា: **សយញ្ចេ អដ្ឋធម្មកុសលោ សយមេវ អត្ថរិតព្វំ នោ ចេ អញ្ញោ អដ្ឋធម្មកុសលា**

---

១-ជា "ឧទ្ធារោ" ដូច្នេះក៏មាន ។ ២-ធមិ៨ប្រការនេះមាននិយាយសព្វគ្រប់ទៅខាងចុង ។

**បរិយេសិត្វា អានេតព្វា ឯវំ អកត្វា កឋិនំ អត្ថរិតុំ ន វដ្ដតិ។** បើភិក្ខុអ្នកអាវាសប្រសប់ វៀងវៃក្នុងធម៌៨ ប្រការខ្លួនឯង គប្បីក្រាលកឋិនខ្លួនឯងចុះ បើមិនប្រសប់វៀងវៃទេ ត្រូវស្វែងរកលោកឯទៀតដែលប្រសប់វៀងវៃក្នុងធម៌ទាំង ៨ ប្រការនោះ នាំលោកយកមកឱ្យជួយចាត់ការទើបបាន បើមិនធ្វើយ៉ាងនេះ ទេមិនគួរក្រាលកឋិនបានឡើយ ។ ក្នុងគម្ពីរដដែលនោះ លោកបញ្ញត្តថា: **តេហិ ពាហិរតោ អាគតត្ថេរេហិ សយំ កឋិនំ ន អត្ថរិតព្វំ សព្វំ បុព្វកិច្ចាទិកំ សំវិធហិត្វា តេ បុរិមិកាយ វស្សូបគតា អន្តោសីមដ្ឋភិក្ខូ យេវ អត្ថារាបេតព្វា។** ព្រះថេរទាំងប៉ុន្មានដែល និមន្តមកអំពីខាងក្រៅ មិនត្រូវក្រាលកឋិនខ្លួនឯងទេ ត្រូវតែជួយចាត់ចែង ធ្វើបុព្វកិច្ចជាដើមឱ្យបានសព្វគ្រប់ហើយគប្បីឱ្យភិក្ខុអ្នកនៅក្នុងឧបចាសីមាដែលបានចូលបុរិមិកវស្សាទាំងប៉ុន្មាននោះក្រាលកឋិនចុះ ។

ត្រង់ពាក្យក្នុងអដ្ឋកថាថា: "ទានញ្ច ភុញ្ជិត្វា" ដែលប្រែមកថា "ត្រូវបរិភោគតែទាន" នោះ ក្នុងគម្ពីរវិនយាលង្ការដីកាកែបេញ្ចទៅថា: **ខាទនីយភោជនីយត្ថំ អន្នបានាទិទានំ ភុញ្ជិត្វា ខ ន ហិ តេ វត្ថទានំ លភន្តិ។** ត្រូវឆាន់តែអន្នទាននិងបានទាន ដែលជាខាទនីយនិងភោជនីយ ហើយត្រឡប់ទៅវិញចុះ ព្រោះថាលោកដែលនិមន្តមកអំពីខាងក្រៅទាំងអម្បាល្មោះ មិនត្រូវបានវត្ថទាន គឺសំពត់ដែលជា



**បរិវារ**របស់កឋិនឡើយ ។

សួរថា: សំពត់កឋិន បុគ្គលពួកណាប្រគេនទើបគួរ ។

ឆ្លើយថា: តាមអដ្ឋកថាលោកសំដែងថា: **យេន កេនចិ ទេវេន វា មនុស្សេន វា បញ្ចន្នំ វា សហធម្មិកានំ អញ្ញតរេន ទិន្នំ វដ្ដតិ** ។ បុគ្គលឯណានីមួយ ទោះទេវតាក្តី មនុស្សក្តី សហធម្មិកទាំង ៥ គឺភិក្ខុ ភិក្ខុនី សិក្ខមានា សាមណេរ សាមណេរី សហធម្មិកណា ១ ក្តី គេប្រគេនគួរទាំងអស់ ។ ដោយហេតុតែបុគ្គលពួកណោះប្រគេនសំពត់កឋិនបានដូច្នេះ ទើបព្រះអដ្ឋកថាចារ្យ បង្ហាប់វិធីទុកបង្ការដូច្នេះ: **កឋិនទាយកស្ស វត្តំ អត្ថិ សចេ សោ តំ អជានន្តោ បុច្ឆតិ ភន្តេ កថំ កឋិនំ ទាតព្វន្តិ តស្ស ឯវំ អាចិក្ខិតព្វំ តិណ្ណំ ចីវរានំ អញ្ញតរប្បហោនកំ សុរិយុគ្គមន-សមយេ វត្ថំ កឋិនចីវរំ ទេមាតិ ទាតុំ វដ្ដតិ តស្ស បរិកម្មត្ថំ ឯត្តកា នាម សូចិយោ ឯត្តកំ សុត្តំ ឯត្តកំ រជនំ បរិកម្មំ ករោន្តានំ ឯត្តកានំ ភិក្ខូនំ យាគុភត្តញ្ច ទាតុំ វដ្ដតីតិ ខ** កិច្ចវត្តដែលកឋិនទាយកត្រូវធ្វើចីវរគង់មាន តែបើគេនៅល្ងង់មិនទាន់ដឹងកិច្ចដែលនឹងធ្វើចីវរនោះទេ ហើយគេមកសួរភិក្ខុថា "បពិត្រលោកដ៏ចំរើន កឋិនត្រូវយើងខ្ញុំ ប្រគេនដូចម្តេច?" ត្រូវឱ្យភិក្ខុប្រាប់ទៅគេវិញជាការសម្រាលយ៉ាងនេះថា: ក្នុងចីវរទាំង៣គឺ: សង្ឃាដិ១

ឧត្តរាសង្គ ១ អន្តរវាសក ១ ត្រូវអ្នកនាំយកសំពត់ឱ្យល្មមធ្វើចីវរណា ១ គ្រាន់ មកវេរប្រគេនជំនុំសង្ឃដោយពាក្យថា "កឋិនចីវរំ[១] ទេម) យើងខ្ញុំសូមវេរប្រគេនចីវរកឋិន" ដូច្នេះក្នុងសម័យដែលអរុណទើបរះ រួចហើយត្រូវអ្នកប្រគេនម្ចាស់ចំនួនប៉ុណ្ណោះ ចេសចំនួនប៉ុណ្ណោះគ្រឿងជ្រលក់ចំនួនប៉ុណ្ណោះថែមមក ដើម្បីនឹងបរិកម្មធ្វើចីវរនោះ រួចពីនេះត្រូវអ្នកប្រគេនយាគុនឹងភត្តដល់ភិក្ខុចំនួនប៉ុណ្ណោះអង្គ ដែលកំពុងបរិកម្មចាត់ចែងធ្វើចីវរនោះផងទើបគួរ ។ (ដែលត្រូវប្រាប់ដូច្នេះលុះតែទាយកគេសួរ បើគេមិនសួរទេមិនត្រូវប្រាប់ឡើយ) ។ ក្នុងគម្ពីរធម្មសមុហវិនយ លោកបង្ហាញវិធីវេរសំពត់កឋិនដូច្នេះ: **តេន វស្សំវុដ្ឋវិហារេ និសិន្នស្ស វា ឋិតស្ស វា សង្ឃស្ស ហត្ថបាសេ ឋបិតំ កឋិនចីវរំ ទេមាតិ វាចាភិន្នេន ញាតព្វំ** ។ សំពត់កឋិនត្រូវឱ្យទាយកនោះយកទៅដាក់ក្នុងហត្ថបាសជំនុំសង្ឃដែលគង់ឬឈរក្នុងវត្តដែលនៅចាំវស្សា ហើយវេរប្រគេនដោយបញ្ចេញវាចាថា "(កឋិនចីវរំ ទេម) យើងខ្ញុំសូមវេរប្រគេនចីវរកឋិន" ដូច្នេះ ។ វិធីនេះក្នុងគម្ពីរវិនយាលង្ការដីកាលោកពោលថា: **ឥមស្មិំ កាលេ យេភុយ្យេន បុគ្គលស្សេវ ទិន្នត្តា បុគ្គលិកភូតំ ចីវរំ ញត្តិកម្មវាចារហំ ន ហោតិ សង្ឃិកមេវ ញត្តិកម្ម~**

១-ក្នុងគម្ពីរធម្មសមុហវិនយប្រាប់ថា: បើបញ្ចូលពាក្យថា "សង្ឃស្ស" ត្រង់... មកទៀត



**វាចារហំ ហោតិ តទេវ ច បញ្ចានិសំសការណំ ហោតិ ។** ក្នុងកាលឥឡូវនេះ ទាយកតែងប្រគេនចីវរកឋិនផ្ទាល់បុគ្គល គឺភិក្ខុ ១ រូបដោយច្រើន ហើយចីវរដែលគេប្រគេនផ្ទាល់បុគ្គលបែបនេះ មិនគួរដល់ញត្តិកម្មវាចាទេ ចីវរដែលគេប្រគេនចំពោះសង្ឃទើបគួរដល់ញត្តិកម្មវាចាហើយចំពោះតែចីវរបែបនោះម្យ៉ាង ទើបជាហេតុឱ្យបានអានិសង្ស៥ ។ ក្នុងគម្ពីរដដែលលោកពោលមួយកន្លែងទៀតថា: **យទិ បន ទាយកោបិ បុគ្គលស្សេវ ទេតិ បុគ្គលោបិ សម្បដិច្ឆិត្វា ន បរិច្ចជតិ ឯវំ សន្តេ តំ ចីវរំ បុគ្គលិកំ ហោតិ ន កឋិនកាលមត្តេន វា កឋិនវចនមត្តេន វា សង្ឃិកំ ហោតិ** ។ ប្រសិនបើទាយកគេប្រគេនចីវរផ្ទាល់បុគ្គល ហើយបុគ្គលក៏ទទួលយកទៅ មិនលះបង់ចេញ កាលបើយ៉ាងនេះ ចីវរនោះចាត់ជាចីវររបស់បុគ្គល មិនមែនជាចីវររបស់សង្ឃ ព្រោះតែកាលដែលកឋិនកើតប៉ុណ្ណោះទេ ឬព្រោះតែពោលថាកឋិនៗ ប៉ុណ្ណោះទេ ។

សួរថា: កាលបើទាយកគេវេរប្រគេនសំពត់កឋិនមក តើត្រូវសង្ឃទទួលដូចម្តេច ។

ឆ្លើយថា: តាមគម្ពីរវិនយាលង្ការដីកាលោកកែថា: **បដិគ្គហណកិច្ចំ បនេត្ថ ទាយកេន ចីវរេ ទិន្នេ សង្ឃស្ស ចិត្តេន សម្បដិច្ឆ~**

**នមត្តមេវ បមាណំ ហោតិ** ។ កិច្ចដែលត្រូវទទួលដោយកាយ ឬដោយវាចាមិនមានទេ កាលបើទាយកគេប្រគេនចីវរមកយកតែត្រង់ការទទួលដោយចិត្តរបស់សង្ឃប៉ុណ្ណោះជាប្រមាណ ។ ក្នុងគម្ពីរដដែលលោកពន្យល់ថា: **បដិគ្គហណំ នាម យោ បន ភិក្ខុ ឥធ បាចិត្តិយន្តិ យាវកាលិកាទីសុ អជ្ឈោហរិតព្វេសុ ចតុកាលិក-វត្ថុសុ ភគវតា វុត្តំ ន ចីវរេ**(១) ។ ការទទួលដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់បញ្ញត្តទុកថា "ភិក្ខុណា ១ លេបអាហារ ដែលគេមិនបានប្រគេនឱ្យចូលទៅក្នុងទ្វារមាត់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹកនឹងឈើស្ទន់" ដូច្នេះ ព្រះអង្គទ្រង់ត្រាស់បញ្ញត្តចំពោះតែក្នុងវត្ថុដែលប្រព្រឹត្តទៅ ក្នុងកាល ៤ មានយាវកាលិកជាដើម ដែលភិក្ខុត្រូវឆាន់លេបនោះទេ មិនមែនទ្រង់ត្រាស់បញ្ញត្តចំពោះក្នុងចីវរទេ ។ (កាលបើដូច្នេះត្រូវសង្ឃទទួលតែដោយចិត្ត គឺដោយតុណ្ហីភាពចុះ) ។

ក្នុងអដ្ឋកថា លោកបង្គាប់ថា: **កឋិនត្ថារកេនាបិ ធម្មេន សមេន ឧប្បន្នំ កឋិនំ អត្ថរិតព្វំ ។ អត្ថរន្តេន វត្ថំ ជានិតព្វំ តន្តវាយគេហតោ ហិ អាភតសន្តានេនេវ ខលិមក្ខិតសា-ដកោបិ ន វដ្ដតិ មលិនសាដកោបិ ន វដ្ដតិ តស្មា កឋិន-**

(១) មើលវិន័យបិដកភាគ ៤ ទំព័រ ១៤៤-១៤៧-១៤៨ ។



**ត្ថារសាដកំ លភិត្វា សុដ្ឋុ ធោវិត្វា សូចិអាទីនិ ចីវរកម្មូ-បករណានិ សជ្ជេត្វា ពហូហិ ភិក្ខូហិ សទ្ធឹ តទហេវ សិព្វេត្វា និដ្ឋិតសូចិកម្មំ រជិត្វា កប្បពិន្ទុំ ទត្វា កឋិនំ អត្ថរិតព្វំ** ។ កឋិនដែលកើតឡើងស្មោះត្រង់តាមធម៌ ត្រូវឱ្យភិក្ខុអ្នកក្រាលទទួលក្រាលចុះ តែកាលដែលក្រាលត្រូវដឹងកិច្ចវត្តផង ព្រោះថាសំពត់សាដកដែលនៅប្រឡាក់ដោយបាយ ដម្បាញ ឬ ម្សៅ ដែលជាប់មកអំពីផ្ទះជាងដម្បាញក្តី មិនគួរទេ សំពត់សាដកដែលប្រឡាក់ដោយមន្ទិលផ្សេងៗ ក្តី ក៏មិនគួរដែរ ព្រោះហេតុនោះ កាលបើភិក្ខុបានសំពត់កឋិនដែលនៅជាសំពត់សាដកលាត បែបនេះមក ត្រូវបោកគក់ឱ្យស្អាត ហើយចាត់ចែងគ្រឿងឧបករណ៍សម្រាប់ធ្វើចីវរមានម្ជុលជាដើមបំរុងទុក រួចហើយត្រូវដេរជាមួយនឹងភិក្ខុទាំងឡាយច្រើនអង្គឱ្យហើយតែក្នុងថ្ងៃនោះ ដល់ដេរស្រេចហើយត្រូវជ្រលក់ ធ្វើកប្បពិន្ទុ អធិដ្ឋានក្រាលកឋិនចុះ ។ ក្នុងគម្ពីរសារត្ថទីបនីដីកា និងគម្ពីរវិនយាលង្ការដីកា កែចេញពីអដ្ឋកថាតទៅទៀតថា: **ខលិមក្ខិតសាដកោតិ អហតវត្ថំ ឥធ ឯវំ អករោន្តេ ករណ សន្និធិ ហោតិ** ។ ពាក្យថាសំពត់សាដកដែលនៅប្រឡាក់ដោយបាយដម្បាញ "លោកពោលសំដៅយកសំពត់ថ្មោងសុទ្ធ (សំពត់បែបនេះមិនគួរទេ) ។ ពាក្យថា "ត្រូវបោកគក់ឱ្យស្អាត" លោកប្រាប់ឱ្យធ្វើគ្រប់បុព្វករណ

ទាំងអស់រហូតដល់ក្រាលជាទីបំផុត ។ ពាក្យថា "ត្រូវដេរជ្រលក់ធ្វើកប្បពិន្ទុ" លោកប្រាប់ឱ្យធ្វើទាំងអស់ កាត់ ដានផង ។ ពាក្យថា "ត្រូវចាត់ចែងគ្រឿងឧបករណ៍សម្រាប់ធ្វើចីវរ មានម្ជុលជាដើម ហើយដេរជាមួយនឹងភិក្ខុទាំងឡាយច្រើនអង្គ" លោកសំដែងឱ្យឃើញច្បាស់អំពីការជំនួយ នឹងដេរចីវរបែបនេះបានតែជាមួយនឹងភិក្ខុផងគ្នា ។ ពាក្យថា "ត្រូវដេរឱ្យហើយតែក្នុងថ្ងៃនោះ លោកពោលទុកដើម្បីឱ្យផុតអំពីករណសន្និធិ[១] ព្រោះថាសំពត់សាដកកឋិនត្រូវតែសង្ឃប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលក្នុងថ្ងៃដែលបានអំពីដៃទាយកមក បើសិនប្រគល់ឱ្យយ៉ាងនេះចាត់ជានិចយសន្និធិ[១] ឯភិក្ខុអ្នកក្រាលកឋិនសោតក៏ត្រូវតែក្រាលក្នុងថ្ងៃដែលបានសំពត់អំពីសង្ឃមក បើមិនធ្វើយ៉ាងនេះចាត់ជាករណសន្និធិ[១] ។

ក្នុងគម្ពីរកង្ខាវិតរណីអដ្ឋកថា លោកពោលសរសើរថា: **កតបុញ្ញ-ករណមេវ ឧប្បជ្ជតិ សុន្ទរមេវ** ។ បើចីវរដែលទាយកគេធ្វើបុញ្ញករណរួចស្រេចកើតឡើងដោយសង្ឃជាការប្រពៃមែនពិត ។ ក្នុងគម្ពីរវជិរពុទ្ធិដីកា លោកពោលថា: **បរិនិដ្ឋិតបុញ្ញករណមេវ ចេ ទាយកោ សង្ឃស្ស ទេតិ សម្បដិច្ឆិត្វា កម្មវាចាយ ទាតព្វំ ខ តេន ច តស្មឹ យេវ សីមមណ្ឌលេ អធិដ្ឋហិត្វា អត្ថរិត្វា សង្ឃោ អនុមោទាបេតព្វោ កតបុញ្ញករណស្ស បុន កត្តព្វាភាវតោ** ។

១-មានអធិប្បាយទៅក្នុងអនត្ថពាការខាងចុងទៀត ។



បើទាយកគេវេរប្រគេនចីវរដែលមានបុញ្ញករណគេសម្រេចស្រាប់មកតែម្តងដល់សង្ឃ ត្រូវសង្ឃទទួលហើយប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលដោយកម្មវាចាចុះ ឯភិក្ខុអ្នកក្រាលកឋិននោះសោតត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះ រួចហើយត្រូវញុំាងសង្ឃឱ្យអនុមោទនាតែម្តងទៅចុះ ព្រោះមិនមានកិច្ច នឹងត្រូវធ្វើបុញ្ញករណដែលគេធ្វើរួចមកហើយនោះម្តងទៀតទេ ។ ក្នុងគម្ពីរវិនយាលង្ការដីកា លោកពោលថា: **ឯវំ ទិន្នេ បន កឋិនេ បច្ចុទ្ធរិតព្វា អធិដ្ឋាតព្វា វាចា ភិន្ទិតព្វា** ។ កាលបើសង្ឃប្រគល់ ចីវរកឋិនដែលសម្រេចស្រាប់មកឱ្យយ៉ាងនេះហើយ (បើភិក្ខុអ្នកក្រាលកឋិនត្រូវការក្រាលដោយសង្ឃាដិ) ត្រូវបច្ចុទ្ធរ៍ដកសង្ឃាដិចាស់ចេញ អធិដ្ឋានសង្ឃាដិថ្មីឡើង រួចហើយត្រូវបញ្ចេញវចីភេទក្រាលចុះ ។

ក្នុងអដ្ឋកថា លោកសំដែងថា: **សចេ តស្មឹ អនត្ថតេ យេវ អញ្ញោ កឋិនសាដកំ អាហរតិ អញ្ញានិ ច ពហូនិ កឋិនានិសំសវត្ថានិ ទេតិ យោ អានិសំសំ ពហុំ ទេតិ តស្ស សន្តកេនេវ អត្ថរិតព្វំ ខ ឥតរោ យថា តថា ឱវទិត្វា សញ្ញាបេតព្វោ** ។ កាលបើកឋិនដែលទាយកគេនាំមកប្រគេនមុននោះ ភិក្ខុមិនទាន់បានក្រាលនៅឡើយ បើមានទាយកដទៃគេនាំកឋិនសាដកមកប្រគេនទៀត ហើយគេប្រគេនសំពត់ដែលជាកឋិនានិសង្សរួច

ទៀត១ ច្រើន ត្រូវឱ្យភិក្ខុក្រាលកឋិនដោយសំពត់របស់ទាយកដែលគេប្រគេនកឋិនានិសង្សច្រើននោះចុះ ឯទាយកម្ខាងត្រូវឱ្យភិក្ខុនិយាយទូន្មានសម្រុះសម្រួលឱ្យសុខចិត្តស្ដាប់បានផង ។ ក្នុងគម្ពីរវិនយាលង្ការដីកា កែចេញពីអដ្ឋកថាតទៅទៀតថា: **អញ្ញានិ ច ពហូនិ កឋិនានិសំស-វត្ថានិ ទេតីតិ ឥមិនា អត្ថរិតព្វសាដកោ យេវ កឋិនសាដកោ នាម តតោ អញ្ញេសាដកា ពហវោបិ កឋិនានិសំសា យេវ នាមាតិ ទស្សេតិ ខ** តាមពាក្យក្នុងអដ្ឋកថាថា "អញ្ញានិ ច ពហូនិ កឋិនានិសំសវត្ថានិ ទេតិ" ដែលប្រែមកថា "គេប្រគេនសំពត់ដែលជាកឋិនានិសង្សឯទៀត១ ច្រើន" ដូច្នេះនេះ លោកសំដែងឱ្យឃើញថា: ដែលហៅថា "កឋិនសាដក" នោះ ចំពោះតែសំពត់សាដក ១ ដែលភិក្ខុត្រូវក្រាលកឋិនប៉ុណ្ណោះ ឯសំពត់សាដកដទៃអំពីនោះទៅ ទោះបីច្រើនដល់ប៉ុន្មានក្ដី ក៏សុទ្ធតែហៅថា "កឋិនានិសង្ស" ទាំងអស់។ ក្នុងគម្ពីរដដែលលោកកែបញ្ជាក់មកទៀតថា: **ឯតេន ច កឋិនានិសំ-សោតិ វត្ថានិ យេវ វុត្តោ ន អគ្ឃាតិ ទីបេតិ** ។ ព្រះដីកាចារ្យសំដែងឱ្យឃើញថា: ដែលហៅថា "កឋិនានិសង្ស" ដូច្នេះ តាមបទដើមនុ៎ះ លោកពោលចំពោះតែ សំពត់ម្យ៉ាងប៉ុណ្ណោះ លោកមិនបានពោល ចំពោះដំឡៃទេ(១) ។ ត្រង់ពាក្យដែលព្រះ

(១)-លោកចំពោះរកតែសំពត់មានចំនួនច្រើននឹងចែកឱ្យបានទូទៅដល់ភិក្ខុ-សាមណេរឯទៀត១ផង លោកមិនចំពោះរកសំពត់ដែលល្អមានថ្លៃច្រើនឬសង្កត់ត្រៃច្រើននោះទេ ។



អដ្ឋកថាចារ្យ បង្គាប់ឱ្យនិយាយទូន្មានសម្រុះសម្រួលទាយកម្ខាងឱ្យសុខចិត្តនោះ ក្នុងគម្ពីរវិនយាលង្ការដីកាបង្គាប់ឱ្យភិក្ខុនិយាយដើម្បីឱ្យទាយកនោះស្ដាប់បានថា "ទានរបស់ខ្លួនមានផលច្រើន តាំងអំពីកាលដែលវេរប្រគេនដល់សង្ឃម្ល៉េះ ឯការក្រាលនឹងមិនក្រាលជាមុខក្រសួងខាងភិក្ខុទេ" តែពាក្យបង្គាប់របស់លោកនោះជាអនេកពេក ផុតវិស័យដែលនឹងគួរនាំមកដំណាលក្នុងទីនេះឱ្យសព្វគ្រប់បាន តែបើទុកជាដូច្នោះ ក៏មិនហួសអំពីការដែលគេសុខចិត្ត បើគេមិនសុខចិត្ត ពាក្យទាំងនោះ ក៏យកជាប្រមាណមិនបាន ។

សួរថា: កឋិនត្រូវភិក្ខុណាក្រាល ។

ឆ្លើយថា: តាមបង្គាប់ក្នុងអដ្ឋកថាថា: **យស្ស សង្ឃោ កឋិនចីវរំ ទេតិ** ។ សង្ឃប្រគល់កឋិនចីវរឱ្យទៅភិក្ខុណាត្រូវភិក្ខុនោះក្រាល ។

សួរថា: ចុះសង្ឃត្រូវប្រគល់កឋិនចីវរឱ្យទៅភិក្ខុណា ។

ឆ្លើយថា: តាមបង្គាប់ក្នុងអដ្ឋកថាថា: **យោ ជិណ្ណចីវរោ ហោតិ** ។ ភិក្ខុណាមានចីវរចាស់គ្រាំគ្រា សង្ឃត្រូវប្រគល់ឱ្យទៅភិក្ខុនោះ។

ក្នុងប្រស្នានេះ ព្រះអដ្ឋកថាចារ្យកែដោយពិស្ដារតទៅទៀតថា: **សចេ ពហូ ជិណ្ណចីវរា វុឌ្ឍស្ស ទាតព្វំ ខលខ តស្ស ន**

**ទាតព្វំ** ។ បើភិក្ខុដែលមានចីវរចាស់គ្រាំគ្រាមានច្រើនអង្គត្រូវសង្ឃប្រគល់ឱ្យទៅភិក្ខុដែលចាស់ជាងគេ ។ ក្នុងពួកភិក្ខុចាស់ទាំងនោះសោត ត្រូវសង្ឃប្រគល់ឱ្យទៅភិក្ខុ ដែលជាមហាបុរសប្រសប់វៀងវៃក្នុងធម៌ ៨ ប្រការអង់អាចនឹងធ្វើចីវរ បានក្រាលទាន់ក្នុងថ្ងៃនោះ ។ បើភិក្ខុចាស់មិនអង់អាចនឹងធ្វើចីវរបានដូច្នោះទេត្រូវសង្ឃប្រគល់ឱ្យទៅភិក្ខុខ្ចីជាលំដាប់ចុះមកដែលជាអ្នកអង់អាចនឹងធ្វើបាននោះចុះ តែដែលគួរនោះត្រូវតែសង្ឃសង្គ្រោះដល់មហាថេរ ព្រោះហេតុនោះត្រូវសង្ឃបង្ខំលោកឱ្យទទួលថា: "បពិត្រលោកដ៏ចំរើន សូមឱ្យលោកទទួល ចុះសីមយើងទាំងឡាយជួយធ្វើប្រគេន" រួចហើយត្រូវពិនិត្យមើលចីវរប្រក្រតីរបស់លោកទាំង ៣ បើឃើញថាចីវរណាចាស់គ្រាំគ្រាត្រូវសូត្រញត្តិប្រគល់សំពត់កឋិនប្រគេនទៅលោក ឱ្យល្មមតែធ្វើចីវរនោះគ្រាន់ បើចីវរប្រក្រតីរបស់លោកពីរជាន់ ត្រូវប្រគេនឱ្យល្មមពីរជាន់ ឬបើចីវរប្រក្រតីរបស់លោកតែ១ជាន់ទេ តែក្រាស់ហើយសំពត់កឋិនស្តើងក៏ត្រូវប្រគេនឱ្យល្មមពីរជាន់ដែរ ដើម្បីឱ្យសមគួរដល់ចីវរចាស់របស់លោក បើទុកជាលោកប្រកែកថា "បើមិនបានពីរជាន់ តែ ១ ជាន់ក៏ខ្ញុំដណ្តប់ដែរ" ដូច្នេះ ក៏ត្រូវតែប្រគេនទៅលោកឱ្យល្មមពីរជាន់ទើបគួរ តែភិក្ខុណាដែលប្រកបដោយសេចក្តីលោភជាប្រក្រតី សង្ឃមិនត្រូវប្រគល់សំពត់កឋិនឱ្យ



ទៅភិក្ខុនោះទេ ។ ក្នុងអដ្ឋកថាដែលលោកបញ្ញត្តដល់ភិក្ខុអ្នកក្រាលថា: **តេនាបិ កឋិនំ អត្ថរិត្វា បច្ឆា វិសិព្វេត្វា ទ្វេ ចីវរានិ ករិស្សាមីតិ ន គហេតព្វំ ឯ** ចំណែកភិក្ខុអ្នកក្រាលនោះវិញ មិនត្រូវទទួលសំពត់ឱ្យច្រើនហួសប្រមាណដោយតាំងចិត្តថា: "ដល់ក្រាលកឋិនហើយ អញនឹងដេរធ្វើចីវរពីរបង្អើយជាខាងក្រោយ" នោះឡើយ ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកបង្គាប់វិធីក្រើនកឋិនដូច្នេះ: **កឋិនទុស្សេ លទ្ធេ សង្ឃេ សីមាយ សន្និបតិតេ ឯកេន ភិក្ខុនា ភន្តេ សង្ឃស្ស ឥទំ កឋិនទុស្សំ ឧប្បន្នំ សង្ឃោ ឥមំ កឋិនទុស្សំ កឋិនត្ថារស្ស ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុន្តិ វុត្តេ អញ្ញេន យោ ជិណ្ណចីវរោ តស្សាតិ វត្តព្វំ ឯលឯ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ** ។ កាលបើសង្ឃបានសំពត់កឋិនមកហើយគង់ប្រជុំគ្នា (មិនឱ្យដាច់ហត្ថបាស) ក្នុងសីមា (សន្មតភិក្ខុ ២ អង្គ ឱ្យជាអ្នកប្រកាសដំណាងសង្ឃទាំងអស់) កាលបើភិក្ខុ ១ អង្គ (ភិក្ខុទី ១) ពោលឡើងថា "បពិត្រព្រះគម្តែងសង្ឃដ៏ចំរើន សំពត់កឋិននេះ កើតឡើងដល់សង្ឃហើយ សង្ឃគួរឱ្យសំពត់កឋិននេះទៅភិក្ខុឈ្មោះណា ដើម្បីក្រាលកឋិន?" ត្រូវឱ្យភិក្ខុ ១ អង្គទៀត (ភិក្ខុទី ២) ពោលឡើងថា "ភិក្ខុអង្គណាមានចីវរចាស់គ្រាំគ្រា សង្ឃគួរឱ្យទៅភិក្ខុអង្គនោះ" ។ តមក បើភិក្ខុអ្នកប្រកាសមុន (ភិក្ខុទី ១) ពោលតប

មកវិញថា "ភិក្ខុដែលមានចីវរចាស់គ្រាំគ្រាមានច្រើនអង្គ" ឬថា "ក្នុងទីនេះមិនមានភិក្ខុដែលមានចីវរចាស់គ្រាំគ្រាទេ" ត្រូវឱ្យភិក្ខុឯទៀត (ភិក្ខុទី២) ពោលឡើងថា "បើដូច្នោះសង្ឃគួរឱ្យទៅភិក្ខុដែលចាស់វស្សាចុះ" ។ កាលបើភិក្ខុអ្នកប្រកាសមុន (ភិក្ខុទី ១) ពោលបញ្ជាក់មកម្តងទៀតថា "ក្នុងទីនេះភិក្ខុអង្គណាដែលចាស់វស្សា?" ត្រូវឱ្យភិក្ខុក្រៅពីនេះ (ភិក្ខុទី២) ពោលឡើងថា "ភិក្ខុឈ្មោះនេះ[១]" ។ កាលបើភិក្ខុអ្នកប្រកាសមុន (ភិក្ខុទី ១) ពោលបញ្ជាក់មកម្តងទៀតថា "ភិក្ខុអង្គនោះ អង់អាចនឹងធ្វើចីវរបានក្រាលទាន់ក្នុងថ្ងៃនោះឬទេ?" ត្រូវឱ្យភិក្ខុក្រៅពីនេះ (ភិក្ខុទី២) ពោលឡើងថា "លោកអង់អាចនឹងធ្វើបាន" ឬថា "សង្ឃនឹងធ្វើនូវសេចក្តីសង្គ្រោះដល់មហាថេរ" ។ កាលបើភិក្ខុអ្នកប្រកាសមុន (ភិក្ខុ ១) ពោលបញ្ជាក់មកម្តងទៀតថា "ចុះព្រះមហាថេរអង្គនោះប្រកបដោយអង្គ ៨ ប្រការឬទេ?" ត្រូវឱ្យភិក្ខុក្រៅពីនេះ (ភិក្ខុទី២) ពោលឡើងថា "ព្រះករុណាលោកប្រកបហើយ" ។ កាលបើភិក្ខុអ្នកប្រកាសមុន (ភិក្ខុទី ១) យល់ព្រមថា "សាធុ ប្រពៃហើយ សង្ឃគួរឱ្យទៅព្រះមហាថេរអង្គនោះដោយស្រួលចុះ" ត្រូវឱ្យភិក្ខុដែលឈ្លាសប្រតិពលញ៉ាំងសង្ឃឱ្យដឹងតទៅ ។

សួរថា: ជំនុំសង្ឃត្រូវប្រគល់សំពត់កឋិនឱ្យទៅភិក្ខុអ្នកក្រាលដោយវិធីដូចម្តេច ។

---

១-ត្រូវផ្លាស់ដាក់តាមនាមរបស់ភិក្ខុអ្នកក្រាល ។



ឆ្លើយថា: តាមគម្ពីរវិនយាលង្ការដីកា លោកបង្គាប់ថា: **ញត្តិទុតិយកម្មវាចាយ ទាតព្វំ** ។ ត្រូវសង្ឃប្រគល់ឱ្យ ដោយញត្តិទុតិយកម្មវាចា ។

ក៏វិធីដែលត្រូវសូត្រញត្តិទុតិយកម្មវាចា ប្រគល់សំពត់កឋិននោះ តាមពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គថា: ត្រូវឱ្យភិក្ខុដែលប្រតិពលញ៉ាំងជំនុំសង្ឃឱ្យដឹងដូច្នេះ :

**សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស ឥត្ថន្នាមស្ស[១] ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស ។ យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ ឥត្ថន្នាមស្ស[១] ភិក្ខុនោ កឋិនំ អត្ថរិតុំ ។**

---

១-បាលីថា "ឥត្ថន្នាមស្ស" នេះត្រូវផ្លាស់ដាក់តាមនាមរបស់ភិក្ខុអ្នកក្រាលឱ្យរាល់បទ

**ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ បើ (ការនេះ) មានកាលគួរដល់សង្ឃហើយ សង្ឃគួរឱ្យសំពត់កឋិននេះទៅភិក្ខុ (ឈ្មោះនេះ)[១] ដើម្បីក្រាលកឋិន ។ នេះជាពាក្យផ្តៀង ។ បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ (ឥឡូវ) សង្ឃឱ្យសំពត់កឋិននេះទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន ។ ការដែលឱ្យសំពត់កឋិននេះទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សំពត់កឋិននេះ សង្ឃឱ្យទៅភិក្ខុ (ឈ្មោះនេះ) ហើយ ដើម្បីក្រាលកឋិន ។ (ការនេះ) គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំចាំទុកនូវការនេះ ដោយភាពដែលសង្ឃស្ងៀមយ៉ាងនេះ ។

សួរថា: បើសង្ឃប្រគល់សំពត់កឋិនមកឱ្យយ៉ាងនេះហើយត្រូវឱ្យភិក្ខុអ្នកក្រាលប្រតិបត្តិដូចម្តេច ។

ឆ្លើយថា: តាមគម្ពីរបរិវារ លោកបង្គាប់ថា: **តេន កឋិនត្ថារកេន ភិក្ខុនា តទហេវ ធោវិត្វា វិមជ្ជិត្វា វិចារេត្វា ឆិន្ទិត្វា សិព្វេត្វា រជិត្វា កប្បំ កត្វា កឋិនំ អត្ថរិតព្វំ** ។ ត្រូវឱ្យភិក្ខុអ្នក

១- ត្រង់ដែលគូអញ្ញត្តសញ្ញាបែបនេះ ( ... ... ) ត្រូវដាក់នាមរបស់ភិក្ខុអ្នកក្រាល មករាល់បទ ។



ក្រាលកឋិននោះ បោកគក់ ច្របាច់ វាស់ កាត់ដេរ ជ្រលក់ ធ្វើកប្បពិន្ទុឱ្យហើយស្រេចតែក្នុងថ្ងៃនោះ ហើយក្រាលកឋិនទៅចុះ ។

ក្នុងគម្ពីរតតិយសមន្តបាសទិកាអដ្ឋកថា និងគម្ពីរវិនយធរសិក្ខាបទ លោកពន្យល់ថា: **ឯវំ ទិន្នេ បន កឋិនេ សចេ តំ កឋិនទុស្សំ និដ្ឋិតបរិកម្មមេវ ហោតិ ឥច្ចេតំ កុសលំ នោ ចេ និដ្ឋិតបរិកម្មំ ហោតិ អហំ ថេរោតិ វា ពហុស្សុតោតិ វា ឯកេនាបិ អកាតុំ ន លព្ភតិ សព្វេហេវ សន្និបតិត្វា ធោវនសិព្វនរជនានិ និដ្ឋាបេតព្វានិ** ។ កាលបើសង្ឃប្រគល់សំពត់កឋិនមកឱ្យយ៉ាងនេះហើយ បើសំពត់កឋិននោះមានបរិកម្មគេសម្រេចស្រាប់មកហើយ នុ៎ះជាការគាប់ប្រសើរហើយ បើមានបរិកម្មគេមិនទាន់សម្រេចមកនៅឡើយទេ តិចហើយភិក្ខុអង្គណា ១ អាងថាអញជាថេរ ឬអាងថាអញជាពហុស្សូត ហើយមិនជួយធ្វើមិនបានឡើយ ត្រូវតែប្រជុំគ្នាជួយបោកគក់ ដេរ ជ្រលក់ទាំងអស់អង្គ ត្រាតែហើយស្រេចទើបបាន ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកកែចេញតទៅទៀតថា: **សចេ តំ កឋិនទុស្សំ និដ្ឋិតបរិកម្មមេវ ហោតីតិ ឥមិនា កឋិនទុស្សំ នាម ន កេវលំ បកតិសាដកមេវ ហោតិ អថខោ បរិនិ-ដ្ឋិតសត្តវិធបុព្វកិច្ចចីវរំបិ ហោតីតិ ទស្សេតិ ។ តស្មា និដ្ឋិតចីវរស្មឹ ទិន្នេ សត្តវិធបុព្វកិច្ចករណេន អត្ថោ នត្ថិ**

**តេទលំ បច្ចុទ្ធរណាទីនិ កាតព្វានិ ។ សចេ បន កិញ្ចិ អបរិនិដ្ឋិតំ ហោតិ អន្តមសោ កប្បពិន្ទុមត្តំ បិ តំ និដ្ឋបេត្វា សយមេវ បច្ចុទ្ធរណាទីនិ កាតព្វានិ ។** តាមពាក្យដែលព្រះអដ្ឋកថាចារ្យពោលថា "សចេ តំ កឋិនទុស្សំ និដ្ឋិតបរិកម្មមេវ ហោតិ" ដូច្នេះ នេះលោកសំដែងឱ្យឃើញថា: ដែលហៅថា "សំពត់កឋិន" មិនមែនបាន តែសំពត់សាដក លាត ជាប្រក្រតីប៉ុណ្ណោះទេ ទុកណាជាចីវរដែលមាន បុព្វកិច្ចទាំង ៧ ប្រការគេសម្រេចស្រាប់មកហើយ ក៏រឹងរឹតតែបានដោយ ពិត ព្រោះហេតុនោះកាលបើទាយកគេប្រគេនចីវរដែលសម្រេចស្រាប់មក មិនមានត្រូវការអ្វីនឹងធ្វើបុព្វកិច្ចទាំង ៧ ប្រការទៀតទេ ត្រូវធ្វើតែកិច្ច ទាំងឡាយ មានបច្ចុទ្ធរ៍ដកចីវរចាស់ជាដើមប៉ុណ្ណោះ តែបើនៅមិនទាន់ សម្រេចកិច្ចឯណានីមួយ ដោយយ៉ាងហោច សូម្បីត្រឹមតែកប្បពិន្ទុប៉ុណ្ណោះ ក៏ត្រូវតែញុំាងកិច្ចនោះឱ្យសម្រេច ហើយសឹមធ្វើកិច្ចឯទៀតមានបច្ចុទ្ធរ៍ដក ចីវរចាស់ជាដើមនោះចុះ ។ ក្នុងគម្ពីរសារត្ថទីបនីដីកាលោកសំដែងប្រាប់ ទោស ភិក្ខុដែលមិនជួយធ្វើដូច្នេះ **អកាតុំ ន លព្ភតីតិ ឥមិនា អនាទរិយេន អករោន្តស្ស ទុក្កដន្តិ ទីបេតិ ។** តាមពាក្យដែល ព្រះអដ្ឋកថាចារ្យពោលថា "មិនជួយធ្វើមិនបាន" ដូច្នេះនេះ លោកសំដែង ឱ្យឃើញថា: កាលបើភិក្ខុណា ១ មិនអើពើនឹងជួយធ្វើភិក្ខុនោះនឹង ត្រូវអាបត្តិទុក្កដ ។

ក្នុងគម្ពីរតតិយសមន្តបាសាទិកាអដ្ឋកថា លោកបង្គាប់ទុក ១ កន្លែង



ទៀតថា: **កតបរិយោសិតំ បន កឋិនំ គហេត្វា អត្ថារកេន ភិក្ខុនា ។ល។ កឋិនំ អត្ថរិតព្វំ ។** ត្រូវឱ្យភិក្ខុអ្នកក្រាលទទួល យកចីវរកឋិន ដែលធ្វើរួចស្រេចយកទៅក្រាលកឋិនតាម វិធីដែលលោក ពោលទុកក្នុងគម្ពីរបរិវារនោះចុះ[(១)] ។ ក្នុងគម្ពីរវិនយាលង្ការដីកា លោក កែចេញពីអដ្ឋកថាតទៅទៀតថា: **កតបរិយោសិតំ បន កឋិនំ គហេត្វាតិ ធោវនញ្ច វិចារោ ច ឆេទនំ ពន្ធនំបិ ច សិព្វនំ រជនំ កប្បំ បុព្វកិច្ចន្តិ វុច្ចតីតិ វុត្តានិ សត្តវិធបុព្វ-ករណានិ កត្វា បរិយោសាបិតំ កឋិនចីវរំ គហេត្វា អត្ថារកេន ភិក្ខុនា បច្ចុទ្ធរិតព្វា អធិដ្ឋាតព្វា វាចា ភិន្ទិត-ព្វាតិ សម្ពន្ធោ ។** ពាក្យថា "កតបរិយោសិតំ បន កឋិនំ គហេត្វា" ដែល ប្រែមកថា "ត្រូវឱ្យភិក្ខុអ្នកក្រាលទទួលយកចីវរកឋិនដែលធ្វើរួចស្រេច" ដូច្នេះ បានសេចក្តីថា: ត្រូវឱ្យភិក្ខុអ្នកក្រាលទទួលចីវរកឋិនដែលគេធ្វើ បុព្វករណទាំង ៧ ប្រការដូចលោកពោលទុកថា "ការបោកគក់ ១ ចាត់ ថែងវាស់ ១ កាត់ ១ ដាន ១ ដេរ ១ ជ្រលក់ ១ ធ្វើកប្បពិន្ទុ ១ (ទាំង ៧ នេះ) ចាត់ជាកិច្ចត្រូវធ្វើមុន" ដូច្នេះ ឱ្យសម្រេចសព្វគ្រប់ស្រាប់មកហើយ នោះយកទៅក្រាលកឋិនចុះ (បើចង់ក្រាលដោយសង្ឃាដិ) ត្រូវបច្ចុទ្ធរ៍ដក សង្ឃាដិចាស់ចេញ អធិដ្ឋានសង្ឃាដិថ្មីឡើង ហើយគប្បីបញ្ចេញវាចាក្រាល ចុះ (បើចង់ក្រាលដោយឧត្តរាសង្គ ឬអន្តរវាសក ក៏ត្រូវធ្វើដូចគ្នា) ។

---

១-មើលត្រង់ទំព័រ ............................................ ។

សួរថា: ត្រូវភិក្ខុក្រាលកឋិនដូចម្តេច ។

ឆ្លើយថា: តាមគម្ពីរបរិវារ លោកបង្គាប់ទុកថា: បើភិក្ខុចង់ក្រាលដោយសង្ឃាដិ ត្រូវបច្ចុទ្ធរ៍ដកសង្ឃាដិចាស់របស់ខ្លួនចេញអធិដ្ឋានសង្ឃាដិថ្មីឡើង ហើយបញ្ចេញវាចាឱ្យជំនុំសង្ឃបានឮច្បាស់ថា: **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ** ។ ខ្ញុំក្រាលកឋិនដោយសង្ឃាដិនេះ ។ បើចង់ក្រាលដោយឧត្តរាសង្គ: (ចីពរ) ត្រូវបច្ចុទ្ធរ៍ដកឧត្តរាសង្គចាស់របស់ខ្លួនចេញ អធិដ្ឋាន ឧត្តរាសង្គថ្មីឡើង ហើយបញ្ចេញវាចាឱ្យជំនុំសង្ឃបានឮច្បាស់ថា: **ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ** ។ ខ្ញុំក្រាលកឋិនដោយឧត្តរាសង្គនេះ ។ បើចង់ក្រាលដោយអន្តរវាសក (ស្បង់) ត្រូវបច្ចុទ្ធរ៍ដកអន្តរវាសកចាស់របស់ខ្លួនចេញ អធិដ្ឋានអន្តរវាសកថ្មីឡើង ហើយបញ្ចេញវាចាឱ្យជំនុំសង្ឃបានឮច្បាស់ថា: **ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ** ។ ខ្ញុំក្រាលកឋិនដោយអន្តរវាសកនេះ ។

កាលបើភិក្ខុ បានក្រាលកឋិនតាមបែបនេះរួចហើយ[(១)] ត្រូវចូលទៅជិតសង្ឃ ឬគណៈ ឬបុគ្គល គ្រងចីពរស្ពាយឆ្វេងអង្គុយប្រហោង ប្រណម្យអញ្ជលីឡើង ពោលប្រាប់ឱ្យលោកទាំងនោះអនុមោទនាថា: **អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ** ។

១-បើមិនមានភិក្ខុដែលគួរអនុមោទនាបាននោះទេ គ្រាន់តែក្រាលហើយក៏ស្រេចទៅ ។



បពិត្រលោកទាំងឡាយដ៏ចំរើនកឋិនរបស់សង្ឃ ខ្ញុំក្រាលរួចហើយ ការក្រាលកឋិន (នុ៎ះ) ប្រកបដោយធម៌ សូមលោកទាំងឡាយអនុមោទនាចុះ ។

ត្រង់ពាក្យថា "ភន្តេ" បើភិក្ខុអ្នកក្រាលចាស់ជាងភិក្ខុអ្នកអនុមោទនាទាំងអស់អង្គត្រូវផ្លាស់ថា "អាវុសោ" ប្រែថា "ម្នាលលោកទាំងឡាយដ៏មានអាយុ" ដូច្នេះបើមានភិក្ខុអ្នកអនុមោទនាចាស់ជាងភិក្ខុអ្នកក្រាលសូម្បីតែ១អង្គ ត្រូវថា "ភន្តេ" ដដែល តែដល់ពាក្យប្រែ បើភិក្ខុអ្នកអនុមោទនាមានច្រើនអង្គ តាំងពី២អង្គឡើងទៅនៅដូចដើម បើមានតែ១អង្គ ត្រូវថាត្រឹមតែ "លោកដ៏ចំរើន លោកដ៏មានអាយុ" ប៉ុណ្ណោះ ។ ត្រង់ពាក្យថា "អនុមោទថ" បើភិក្ខុអ្នកអនុមោទនាមានច្រើនអង្គនៅដូចដើម ឬមានតែ ១ អង្គទេ តែចាស់ជាងភិក្ខុអ្នកក្រាលត្រូវថា "អនុមោទថ" ដែរ តែដល់ពាក្យប្រែត្រូវថា "សូមលោកអនុមោទនា" ដូច្នេះបើមានតែ ១ អង្គហើយខ្ចីជាងភិក្ខុអ្នកក្រាលផង ត្រូវផ្លាស់ថា "អនុមោទាហិ" ប្រែថា "ចូរលោកអនុមោទនា" ដូច្នេះ ។

ចំណែកភិក្ខុអ្នកអនុមោទនាវិញ ត្រូវគ្រងចីពរស្ពាយឆ្វេងអង្គុយប្រហោងប្រណម្យអញ្ជលីឡើង ពោលអនុមោទនាថា: **អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម** ។ ម្នាលលោកដ៏មានអាយុ កឋិនរបស់សង្ឃលោកក្រាលរួចហើយ ការក្រាលកឋិន

(នុំះ) ប្រកបដោយធមិ យើងសូមអនុមោទនា ។

ត្រង់ពាក្យថា "អាវុសោ" សម្រាប់ប្រើចំពោះតែភិក្ខុអ្នកអនុមោទនាចាស់ជាងភិក្ខុអ្នកក្រាល បើបែរជាខ្ចីជាងវិញត្រូវផ្លាស់ថា "ភន្តេ" ដូច្នេះ ដល់ពាក្យប្រែដូចមុន តែមិនមានពាក្យថា "ទាំងឡាយ" ទេ ព្រោះភិក្ខុអ្នកក្រាលមិនដែលមានច្រើនអង្គ ។

ត្រង់ពាក្យថា "អនុមោទាម" សម្រាប់ប្រើចំពោះតែភិក្ខុអ្នកអនុមោទនាមានច្រើនអង្គតាំងពី ២ អង្គឡើងទៅ បើមានតែ ១ អង្គវិញត្រូវថា "អនុមោទាមិ" ប្រែថា "ខ្ញុំសូមអនុមោទនា" ដូច្នេះ [(១)] ។

ក្នុងអដ្ឋកថាលោកសំដែងថា: **ឯវំ សព្វេសំ អត្ថតំ ហោតិ កឋិនំ** ។ កាលបើភិក្ខុ ១ អង្គជាអ្នកក្រាល ភិក្ខុឯទៀតជាអ្នកអនុមោទនាយ៉ាងនេះ បានឈ្មោះថា បានក្រាលកឋិនទាំងអស់អង្គ ។ រឿងនេះក្នុងគម្ពីរវិនយាលង្ការដីកាលោកវិនិច្ឆ័យទុកដូច្នេះ :

សួរថា: **សហ កឋិនស្ស អត្ថារា បន្នរសធម្មា ជាយន្តិ បរិវារេ អាគតត្ថា កឋិនត្ថារេន សហេវ បញ្ច អានិសំសា អាគតា អថ កស្មា សង្ឃំ អនុមោទាបេតិ** ។ អានិសង្សទាំង ៥ ហូរមកដំណាលគ្នានឹងការក្រាលកឋិនម្ល៉េះ តាមន័យដែលមានមកក្នុងគម្ពីរ

(១)-បើភិក្ខុអ្នកអនុមោទនាមានច្រើនរូប ខ្លះចាស់ជាងភិក្ខុអ្នកក្រាល ខ្លះខ្ចីជាងភិក្ខុអ្នកក្រាល គួរអនុមោទនាជាពីរលើក ពួកភិក្ខុចាស់ ១ លើក ពួកភិក្ខុខ្ចី១លើក ។



បរិវារថា: "ធមិ ១៥ (អានិសង្ស៥មាតិកា៨បលិពោធ២) កើតដំណាលគ្នានឹងការក្រាលកឋិន" កាលបើដូច្នេះតើព្រោះហេតុអ្វីក៏ចាំឱ្យភិក្ខុអ្នកក្រាលញ៉ាំងសង្ឃឱ្យអនុមោទនា ។

ឆ្លើយថា: **កិញ្ចាបិ អត្ថារកស្ស ភិក្ខុនោ បញ្ច អានិសំសា អាគតា សង្ឃស្ស បន អនាគតា តស្មា សង្ឃស្ស ច អាគមនត្ថំ សង្ឃំ អនុមោទាបេតិ សង្ឃោ ច អនុមោទនំ ករោតិ ឯវំ កតេ ឧភិន្នំបិ អានិសំសា អាគតា ហោន្តិ** ។ ដំណើរនុ៎ះពិតមែនហើយ តែអានិសង្សទាំង ៥ ហូរមកដល់តែ ភិក្ខុអ្នកក្រាល ១ អង្គប៉ុណ្ណោះ មិនហូរមកដល់សង្ឃផងឡើយ ព្រោះហេតុនោះទើបចាំឱ្យភិក្ខុអ្នកក្រាលញ៉ាំងសង្ឃឱ្យអនុមោទនា ដើម្បីឱ្យអានិសង្សទាំង ៥ ហូរមកដល់សង្ឃផង រួចសង្ឃក៏ត្រូវតែធ្វើអនុមោទនាតាមកាលបើធ្វើយ៉ាងនេះ អានិសង្សទាំង៥នឹងហូរមកដល់ទាំងពីរពួក គឺទាំងភិក្ខុអ្នកក្រាលទាំងសង្ឃអ្នកអនុមោទនា ។ សមដូចពាក្យដែលលោកអាងទុក ក្នុងគម្ពីរបរិវារថា: **ទ្វិន្នំ បុគ្គលានំ អត្ថតំ ហោតិ កឋិនំ អត្ថារកស្ស ច អនុមោទកស្ស ច** ។ កឋិនដែលបុគ្គលពីរពួកក្រាល គឺបុគ្គលអ្នកក្រាល១ពួកអ្នកអនុមោទនា ១ ពួក ហៅថា ក្រាលដូចគ្នា គឺថា ត្រូវបានអានិសង្ស ៥ ស្មើគ្នា ។

ក្នុងគម្ពីរបរិវារដដែលលោកពោលទុកថា: **ន សង្ឃោ កឋិនំ**

**អត្ថរតិ ន គណោ កឋិនំ អត្ថរតិ បុគ្គលោ កឋិនំ អត្ថរតិ សង្ឃស្ស អនុមោទនាយ គណស្ស អនុមោទនាយ បុគ្គលស្ស អត្ថារា សង្ឃស្ស អត្ថតំ ហោតិ កឋិនំ គណស្ស អត្ថតំ ហោតិ កឋិនំ បុគ្គលស្ស អត្ថតំ ហោតិ កឋិនំ** ។ សង្ឃក្រាលកឋិនមិនបានទេ គណៈក្រាលកឋិនមិនបានទេ បុគ្គលទើបក្រាលកឋិនបាន កឋិនដែលបុគ្គលក្រាល ហើយសង្ឃ ឬ គណៈអនុមោទនា សង្ឃក៏ឈ្មោះថាបានក្រាល គណៈក៏ឈ្មោះថាបានក្រាល បុគ្គលក៏ឈ្មោះថាបានក្រាលដូចគ្នា គឺថាត្រូវបានអានិសង្ស៥ស្មើៗ គ្នា ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកបញ្ញត្តទុកថា: **តេសុ បន សព្វបុគ្គលេសុ យេ តស្មិំ វិហារេ បុរិមិកាយ វស្សំ ឧបគន្ត្វា បឋមបវារណាយ បវារិតា តេ យេវ អនុមោទិតុំ លភន្តិ ២ ឆិន្នវស្សា វា បច្ឆិមិកាយ ឧបគតា វា អញ្ញស្មិំ វិហារេ វុដ្ឋវស្សា វា ន លភន្តិ ។ អនុមោទន្តាបិ អានិសំសំ ន លភន្តិ**។ ក៏ក្នុងក្រុមសង្ឃ គណៈនឹងបុគ្គលទាំងអម្បាលនេះ ភិក្ខុប៉ុន្មានអង្គដែលបានចូលបុរិមិកវស្សា បានបវារណាក្នុងថ្ងៃបឋមបវារណា អនុមោទនាបានតែភិក្ខុប៉ុណ្ណោះអង្គ ឯភិក្ខុដែលដាច់វស្សាក្តី ដែលចូលបច្ឆិមិកវស្សាក្តី ដែលនៅចាំវស្សាក្នុងវត្តឯទៀតក្តី អនុមោទនាមិនបាន



ឡើយ បើទុកជាអនុមោទនា ក៏មិនត្រូវបានអានិសង្សដែរ ។

ក្នុងអដ្ឋកថាលោកសំដែងថា: **ឯវំ អត្ថតេ បន កឋិនេ សចេ បន កឋិនចីវរេន សទ្ធឹ អាភតំ អានិសំសំ ទាយកា យេន អម្ហាកំ កឋិនំ គហិតំ តស្សេវ ទេមាតិ ទេន្តិ ភិក្ខុសង្ឃោ អនិស្សរោ ២ អថ អវិចារេត្វាវ ទត្វា គច្ឆន្តិ ភិក្ខុសង្ឃោ ឥស្សរោ ២លខ គរុភណ្ឌំ ន ភាជេតព្វំ** ។ កាលបើភិក្ខុក្រាលកឋិនរួចយ៉ាងនេះហើយ ទាយកគេវេរប្រគេនចីវរជាអានិសង្ស ដែលគេនាំមកជាមួយនឹងចីវរកឋិន ដោយពាក្យថា: "(យេន អម្ហាកំ កឋិនំ គហិតំ តស្សេវ ទេម) កឋិនរបស់យើងខ្ញុំ លោកអង្គណាទទួល យើងខ្ញុំសូមវេរប្រគេនចំពោះតែលោកអង្គនោះ" ដូច្នេះ ភិក្ខុសង្ឃ មិនបានជាឥស្សរៈឡើយ[១] លុះតែគេមិនបានចាត់ចែងដូច្នោះ គេគ្រាន់តែ លើកប្រគេនៗ ហើយគេទៅអស់ទៅ ទើបភិក្ខុសង្ឃបានជាឥស្សរៈ ព្រោះហេតុនោះ បើចីវរដ៏សេសទាំងប៉ុន្មាន របស់ភិក្ខុអ្នកក្រាលកឋិននោះទុព្វលភាព ហើយសំពត់ជាអានិសង្សរបស់កឋិនមានច្រើន (បើសង្ឃបានជាឥស្សរៈ) ត្រូវសង្ឃអបលោកសំពត់ល្មមធ្វើចីវរទាំងនោះគ្រាន់ប្រគេនថែមទៅលោកទៀត កម្មវាចាសូត្រតែម្តងមុនបានហើយ[១] ឯសំពត់កឋិនានិសង្សដ៏សេសសល់ពីនោះ បើមានច្រើនត្រូវចែកប្រគេនតាមបញ្ជីសំពត់

១-ក្នុងគម្ពីរសារត្ថទីបនីដីកាថា: កម្មវាចា បន ឯកា យេវ វដ្ដតីតិ កឋិនត្ថារសាដកស្ស ទានកាលេ វុត្តា ឯកា យេវ កម្មវាចា វដ្ដតិ ។ បុន តស្ស អញ្ញស្មឹ វត្ថេ ទិយមានេ កម្មវាចាយ ទាតព្វកិច្ចំ នត្ថិ អបលោកនមេវ អលន្តិ អធិប្បាយោ ។

ចំណាំវស្សា បើមិនមានបញ្ជីទេ ឬគ្រប់ចំនួនតាមបញ្ជីហើយ ត្រូវប្រគេនតាំងអំពីអាសនព្រះថេរចុះមក តែគ្រឿងគរុភណ្ឌ មិនត្រូវចែកគ្នាឡើយ ។

ក្នុងគម្ពីរវិនយាលង្ការដីកា លោកកែចេញពីអដ្ឋកថាតទៅទៀតដូច្នេះ

ត្រង់ពាក្យថា: "អានិសំសំ" ដែលប្រែមកថា "ចីវរជាអានិសង្ស" ដូច្នេះ លោកកែថា: **ឯកំ អត្ថតចីវរមេវ កឋិនចីវរំ នាម តតោ អញ្ញំ តេន សទ្ធឹ អាភតំ សព្វំ ចីវរំ កឋិនានិសំសចីវរំ នាម** ។ ដែលហៅថា "កឋិនចីវរ" ចំពោះតែចីវរ១ដែលភិក្ខុក្រាលកឋិនប៉ុណ្ណោះ ចីវរដទៃអំពីនោះ ដែលគេនាំមកជាមួយនឹងចីវរកឋិនទាំងប៉ុន្មាន ហៅថា ចីវរជាអានិសង្សរបស់កឋិនទាំងអស់ ។

ត្រង់ពាក្យថា: "ភិក្ខុសង្ឃោ អនិស្សរោ" ដែលប្រែមកថា "ភិក្ខុសង្ឃមិនបានជាឥស្សរៈ" ដូច្នេះលោកកែថា: **ភិក្ខុសង្ឃោ អនិស្សរោ អត្ថតកឋិនោ ភិក្ខុ យេវ ឥស្សរោ ។ កស្មា ។ ទាយកេហិ វិចារិតត្តា** ។ ភិក្ខុសង្ឃមិនបានជាឥស្សរៈទេ បានជាឥស្សរៈតែភិក្ខុដែលក្រាលកឋិន ១ អង្គឯងប៉ុណ្ណោះ ព្រោះហេតុអ្វី ? -ព្រោះថាចីវរទាំងនោះទាយកទាំងឡាយគេចាត់ចែងរួច ទៅហើយ ។

ត្រង់ពាក្យថា: "ភិក្ខុសង្ឃោ ឥស្សរោ" ដែលប្រែមកថា "ភិក្ខុសង្ឃបានជាឥស្សរៈ" ដូច្នេះ លោកកែថា: **ភិក្ខុសង្ឃោ ឥស្សរោ ។ កស្មា ។**



**ទាយកេហិ អវិចារិតត្តា មូលកឋិនស្ស ច សង្ឃេ និន្នត្តា** ។ ភិក្ខុសង្ឃបានជាឥស្សរៈ ព្រោះហេតុអ្វី? -ព្រោះថាចីវរទាំងនោះ ទាយកទាំងឡាយគេមិនទាន់ចាត់ចែងនៅឡើយ ហើយកឋិនដែលជាមូលដើមគេបានវេរប្រគេនចំពោះសង្ឃរួចហើយ ។

ត្រង់ពាក្យថា: "វស្សាវាសិកដ្ឋិតិកាយ ទាតព្វានិ" ដែលប្រែមកថា "ត្រូវប្រគេនតាមបញ្ជីសំពត់ចំណាំវស្សា" ដូច្នេះលោកកែថា: **យត្តកា ភិក្ខូ វស្សាវាសិកចីវរំ លភឹសុ តេ ឋបេត្វា តេសំ ហេដ្ឋតោ បដ្ឋាយ យថាក្កមំ ទាតព្វានិ** ។ ភិក្ខុប៉ុន្មានរូបដែលបានសំពត់ចំណាំវស្សារួចហើយ ត្រូវលើកទុកភិក្ខុទាំងនោះចេញ ហើយប្រគេនរៀងតាំងអំពីខាងក្រោមភិក្ខុទាំងនោះចុះមក ។

ត្រង់ពាក្យថា: "ថេរាសនតោ បដ្ឋាយ ទាតព្វានិ" ដែលប្រែមកថា "ត្រូវប្រគេនតាំងអំពីអាសនព្រះថេរចុះមក" ដូច្នេះលោកកែថា: **យត្តកា ភិក្ខូ តស្មឹ កឋិនត្ថតសីមាយំ សន្តិ តេសុ ជេដ្ឋកភិក្ខុតោ បដ្ឋាយ ទាតព្វានិ ។ អាសនគ្គហណំ បន យថាវុឌ្ឍំ និសិន្នេ សន្ធាយ កតំ ។ ឯតេន វស្សាវាសិកកឋិនានិសំសានំ សមានគតិកត្តំ ទីបេតិ** ។ បើមិនមានបញ្ជីទេ ត្រូវប្រគេនរៀងតាំងអំពីភិក្ខុដែលជាចំបងលើភិក្ខុទាំងប៉ុន្មាន ដែលមាននៅក្នុងឧបចារសីមា

ដែលក្រាលកឋិននោះ ។ គឺវិធីដែលឱ្យទទួលនូវអាសន លោកចាត់ចំពោះភិក្ខុដែលគង់នៅជាលំដាប់ចាស់ខ្ចី គឺភិក្ខុអង្គណាចាស់ត្រូវឱ្យទទួលមុនឯវិធីចែកសំពត់ចំណាំវស្សា នឹងសំពត់កឋិនានិសង្ស ក៏លោកសំដែងឱ្យឃើញថា មានដំណើរប្រហែលគ្នានឹងវិធីដែលចាត់ឱ្យទទួលអាសននុ៎ះដែរ ។

ត្រង់ពាក្យថាៈ "គរុភណ្ឌំ ន ភាជេតព្វំ" ដែលប្រែមកថា "មិនត្រូវឱ្យចែកគ្រឿងគរុភណ្ឌ" ដូច្នេះ លោកកែថាៈ **កឋិនសាដកេន សទ្ធឹ អាភតេសុ មញ្ចបីឋាទិកំ គរុភណ្ឌំ ន ភាជេតព្វំ ខ សង្ឃិកវសេនេវ បរិភុញ្ជិតព្វន្តិ អត្ថោ** ។ វត្ថុដែលគេនាំមកជាមួយនឹងសំពត់កឋិនទាំងប៉ុន្មាន លើកលែងគ្រឿងគរុភណ្ឌមានគ្រែនឹងតាំងជាដើមមិនត្រូវឱ្យចែកគ្នាឡើយ ត្រូវឱ្យទុកប្រើប្រាស់ជារបស់សង្ឃជាមួយគ្នា ។ ក្នុងគម្ពីរដដែលលោកកែតទៅទៀតថាៈ **ភណ្ឌាគារេ ឋបិតំ បិ អកាលចីវរមេវ សាមណេរានំ ឧបឌ្ឍបដិវិសំ កត្វា ទាតព្វំ ។ វស្សាវាសិកកឋិនានិសំសានិ កាលចីវរំ បន សមកមេវ ទាតព្វំ** ។ មែនពិត អកាលចីវរដែលសង្ឃដកល់ទុកក្នុងឃ្លាំងសម្រាប់ដាក់ចីវរត្រូវសង្ឃបែងចំណែកពាក់កណ្ដាលចែកឱ្យសាមណេរឯសំពត់ចំណាំវស្សា និងសំពត់កឋិនានិសង្សជាដើម ដែលជាកាលចីវរត្រូវសង្ឃចែកឱ្យសាមណេរ ឱ្យស្មើៗ គ្នានឹងភិក្ខុដែរ ។ ន័យមួយ១ទៀតក្នុងគម្ពីរ



ដដែល លោកពន្យល់អំពីវិធីចែកសំពត់កឋិនានិសង្សតាមបញ្ជដោយពិស្ដារតទៅទៀតថាៈ **យេ ភិក្ខូ ឥមស្មឹ វស្សេ វស្សាវាសិកំ លភីសុ ខលខ បុនប្បុនំ គាហេតព្វំ** ។ ភិក្ខុទាំងឡាយឯណាដែលបានសំពត់ចំណាំវស្សាក្នុងវស្សានេះរួចហើយ ត្រូវចែកឱ្យតាំងអំពីខាងក្រោមភិក្ខុទាំងឡាយនោះចុះមក[១] ទោះបី ១ អង្គចីវរ១ក្ដី ១ អង្គសំពត់សាដក ១ ក្ដី ដល់គ្រប់អង្គ ហើយបើមានសល់ចីវរ ឬសំពត់សាដក ត្រូវចែកសារតាំងអំពីអាសនព្រះថេរ ១ លើកទៀតជាចំណែកតំរប់ពីរ បើចីវរឬសំពត់សាដកខ្វះ ត្រូវកំណត់វស្សាជាដើមរបស់ភិក្ខុខាងចុងគេបំផុត ក្នុងពួកភិក្ខុដែលបានចំណែករួច ហើយនោះទុកមួយអន្លើ ។ ព្រោះដែលហៅថាសំពត់កឋិនានិសង្សនោះមិនចំពោះតែសំពត់ដែលគេប្រគេនក្នុងថ្ងៃដែលក្រាលកឋិននោះប៉ុណ្ណោះទេ គិតតាំងពីត្រឹមក្រាលកឋិនហើយ ទៅទល់នឹងកឋិនដោះ ទោះចីវរដែលគេវេរប្រគេនចំពោះសង្ឃទាំងប៉ុន្មានក្ដី ចីវរដែលអារាមិកជនទាំងឡាយនាំមកប្រគេនដោយទ្រព្យសង្ឃដែលកើតឡើង ក្នុងអាវាសនោះទាំងប៉ុន្មានក្ដីក៏សុទ្ធតែហៅថា សំពត់កឋិនានិសង្សទាំងអស់ ។ ព្រោះហេតុនោះ កាលបើចីវរបែបនោះកើតឡើងត្រូវចែកឱ្យបន្តៗ ទៅ តាំងអំពីខាងក្រោមភិក្ខុដែលបានកំណត់វស្សាជាដើមទុកក្នុងគ្រាមុននោះចុះមក ដល់គ្រប់អង្គហើយ

---

១-បើមានគេប្រគេនសំពត់ចំណាំវស្សាដូចកាលឥឡូវនេះ ត្រូវចែកប្រគេនតាំងអំពីអាសនព្រះថេរចុះមកជាដរាប ។

ត្រូវសារអំពីខាងលើ ១០ លើកទៀតត្រាតែផុតកាលកឋិន ។ តែលោកបញ្ញត្តទុកថា: **នេវ អគ្ឃសមត្តំ ភាជេតព្វំ ន កុសឃាតោ ភាជេតព្វោ ។ វុឌ្ឍតរតោ បដ្ឋាយ ឯកស្ស ភិក្ខុស្ស ឯកំ វត្ថំ ទាតព្វំ ។ តេសុ បន ទវេ ទវេ វុឌ្ឍស្ស ទាតព្វំ** ។ វិធីចែកសំពត់កឋិនានិសង្សនេះមិនត្រូវរើសចែកធ្វើឱ្យមានដំឡៃស្មើៗ គ្នាទេ មិនត្រូវធ្វើស្លាកឱ្យចាប់ទេ ។ ត្រូវតែចែកប្រគេនសំពត់ ១ មួយអង្គ ៗ តាំងអំពីភិក្ខុដែលចាស់វស្សាជាងគេរៀងមក ហើយត្រូវរើសរកសំពត់ដែលប្រសើរៗ ប្រគេនទៅភិក្ខុដែលចាស់ៗ ។

ក្នុងអដ្ឋកថាលោកបញ្ញត្តទុកថា: **សចេ បន ឯកសីមាយ ពហូ វិហារា ហោន្តិ សព្វេ ភិក្ខូ សន្និបាតេត្វា ឯកត្ថ កឋិនំ អត្ថរិតព្វំ វិសុំ វិសុំ អត្ថរិតុំ ន វដ្ដតិ** ។ បើក្នុងឧបចារសីមា ១ មានវិហារច្រើន ឬ កុដិច្រើន (ច្រើនក្រុម) ត្រូវប្រមូលភិក្ខុទាំងអស់អង្គមកជួបជុំក្រាលកឋិនតែក្នុងកន្លែង ១ ទើបបាននឹងក្រាលផ្សេងៗ គ្នាមិនបានឡើយ ។

ពណ៌នាមកក្នុងវិធីក្រាលកឋិនក៏អស់សេចក្ដីតែប៉ុណ្ណេះ ។

កឋិនត្ថារវិធានកថា ចប់



# អនត្ថតកឋិនកថា

បន្ទាប់នេះ នឹងពណ៌នាអំពីអាការដែលក្រាលកឋិនឡើង ហៅថា "អត្ថតាការ" នឹងអាការដែលក្រាលកឋិនមិនឡើងហៅថា "អនត្ថតាការ" តទៅ តាមលំអាននៃព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គថា: **ឯវំ ខោ ភិក្ខវេ អត្ថតំ ហោតិ កឋិនំ ឯវំ អនត្ថតំ** ។ ម្នាលភិក្ខុទាំងឡាយ កឋិនដែលភិក្ខុក្រាលឡើងជាកឋិនដោយអាការយ៉ាងនេះ ដែលភិក្ខុក្រាលមិនឡើងជាកឋិនដោយអាការយ៉ាងនេះ ។

តាមលំនាំព្រះពុទ្ធដីកានេះ ហាក់ដូចជាព្រះអង្គទ្រង់សំដែងអំពីអាការដែលក្រាលកឋិនឡើង ដែលហៅថា "អត្ថតាការ" នោះមុន ហើយទ្រង់សំដែងអំពីអាការដែលក្រាលកឋិនមិនឡើង ដែលហៅថា "អនត្ថតាការ" នោះជាខាងក្រោយ តែដល់ព្រះអង្គទ្រង់សំដែងចែករំលែកអាការទាំងនោះទៅ បែរជាឃើញសំដែងអំពីអាការដែលក្រាលកឋិនមិនឡើង ដែលហៅថា "អនត្ថតាការ" នោះជាមុនវិញ ដោយហេតុតែអាការនុ៎ះ មានសេចក្ដីជ្រាលជ្រៅឆ្ងាយទូលាយជាង ។

សួរថា: កឋិនដែលភិក្ខុក្រាលមិនឡើង ដោយអាការយ៉ាងណាខ្លះ ។

ឆ្លើយថា: តាមលំអាននៃព្រះពុទ្ធដីកានោះថា ក្រាលមិនឡើងដោយ

---

១- "ឱវដ្ដិយ" ដូច្នេះ ក៏ថាដែរ ។

អាការៈ២៤ដូច្នេះគឺៈ ឧល្លិខិតមត្តេន ១ ធោវនមត្តេន ១ ចីវរវិចារណមត្តេន ១ ឆេទនមត្តេន ១ ពន្ធនមត្តេន ១ ឱវដ្ដិក(១) ករណមត្តេន ១ កណ្ឌុសករណមត្តេន ១ ទឡ្ហីកម្មករណមត្តេន ១ អនុវាតករណមត្តេន ១ បរិភណ្ឌករណមត្តេន១ ឱវដ្ដេយ្យករណមត្តេន១ កម្ពលមទ្ទនមត្តេន១ និមិត្តកតេន១ បរិកថាកតេន ១ កុក្កុកតេន ១ សន្និធិកតេន ១ និស្សគ្គិយេន ១ អកប្បកតេន ១ អញ្ញត្រ សង្ឃាដិយា ១ អញ្ញត្រ ឧត្តរាសង្គេន ១ អញ្ញត្រ អន្តរវាសកេន ១ អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន ១ អញ្ញត្រ បុគ្គលស្ស អត្ថារា ១ និស្សីមដ្ឋោ អនុមោទតិ ១ រួមត្រូវជា ២៤ ហៅថា អនត្ថតាការៈ ។

អធិប្បាយៈ អាការទី ១ អដ្ឋកថាកែចេញទៅថាៈ **ឧល្លិខិតមត្តេនាតិ ទីឃតោ ច បុថុលតោ ច បមាណគ្គហណមត្តេន ។ បមាណំ ហិ គណ្ហន្តោ ខលខ តំ បមាណគ្គហណំ ឧល្លិខិតមត្តន្តិ វុច្ចតិ ៕** ពាក្យថា "ឧល្លិខិតមត្តេន" បានសេចក្ដីថាៈ ក្រាលដោយសំពត់ដែលគ្រាន់តែកាន់យកនូវប្រមាណខាងបណ្ដោយនិងខាងទទឹង ។ មែនពិត កាលដែលភិក្ខុកាន់យកនូវប្រមាណនៃចីវរគូសក្រិតសំដែងឱ្យឃើញកំណត់ចីវរនោះ ដោយក្រចកជាដើមឬលើកទៅផ្ទប់ត្រង់ថ្ងាសជាដើម ដើម្បីឱ្យតែចំណាំបានត្រង់ប្រទេសនោះៗ ព្រោះហេតុនោះ



ការដែលកាន់យកនូវប្រមាណបែបនេះលោកហៅថា "ឧល្លិខិតមត្ត" ។ (អាការនេះនិយាយពីក្រាលកឋិនដោយសំពត់ដែលមិនទាន់បានធ្វើជាចីវរសោះ ទើបតែនឹងវាស់ស្ទង់បណ្ដោយទទឹងប៉ុណ្ណោះ) ។

អាការទី ២ អដ្ឋកថាកែចេញទៅថាៈ **ធោវនមត្តេនាតិ កថិនទុស្សធោវនមត្តេន** ។ ពាក្យថា "ធោវនមត្តេន បានសេចក្ដីថាៈ ក្រាលដោយសំពត់កឋិនដែលគ្រាន់តែបោកគក់ ។ (អាការនេះ និយាយពីក្រាលកឋិនដោយសំពត់ដែលមិនទាន់ធ្វើជាចីវរនៅឡើយ ទើបតែនឹងបោកគក់ប៉ុណ្ណោះ) ។

អាការទី ៣ អដ្ឋកថាកែចេញទៅថាៈ **ចីវរវិចារណមត្តេនាតិ បញ្ចកំ វា សត្តកំ វា នវកំ វា ឯកាទសកំ វា ហោតូតិ ឯវំ វិចារណមត្តេន** ។ ពាក្យថា "ចីវរវិចារណមត្តេន" បានសេចក្ដីថាៈ ក្រាលដោយសំពត់ដែលគ្រាន់តែចាត់ចែង លៃលក លើកទុកលើកដាក់ជាបែបចីវរយ៉ាងនេះថាៈ "នេះជាចីវរបញ្ចខណ្ឌ (៥ផ្ទាំង) នេះជាចីវរសត្តខណ្ឌ (៧ផ្ទាំង) នវខណ្ឌ (៩ផ្ទាំង) ឬឯកាទសខណ្ឌ (១១ផ្ទាំង)" ។ (អាការនេះនិយាយពីក្រាលកឋិនដោយសំពត់ដែលមិនទាន់ធ្វើជាចីវរនៅឡើយ ទើបតែនឹងលៃលកជារបៀបប៉ុណ្ណោះ ។

អាការទី ៤ អដ្ឋកថាកែចេញទៅថាៈ ឆេទនមត្តេនាតិ យថាវិចារិតស្ស វត្ថស្ស ឆេទនមត្តេន ។ ពាក្យថា "ឆេទនមត្តេន" បានសេចក្ដីថាៈ ក្រាលដោយសំពត់ដែលគ្រាន់តែកាត់តាមបែបដែលបានចាត់ចែងលៃលកទុក ។ (អាការនេះនិយាយពីក្រាលកឋិនដោយសំពត់ដែលមិនទាន់ធ្វើស្រេចជា

ចីវរ ទើបតែនឹងកាត់ប៉ុណ្ណោះ) ។

អាការទី ៥ អដ្ឋកថាកែចេញទៅថា: ពន្ធនមត្តេនាតិ មោឃសុត្តកា-រោបនមត្តេន ។ ពាក្យថា "ពន្ធនមត្តេន" បានសេចក្ដីថា: ក្រាលដោយសំពត់ដែលគ្រាន់តែលើកឡើងនូវចេសឥតអំពើ គឺគ្រាន់តែដាន ។ (អាការនេះ និយាយពីក្រាលកឋិនដោយសំពត់ដែលធ្វើមិនទាន់ហើយស្រេចជាចីវរ ទើបតែនឹងដានផ្ដុំប៉ុណ្ណោះ) ។

អាការទី ៦ អដ្ឋកថាកែចេញទៅថា: ឱវដ្ដិកករណមត្តេនាតិ មោឃសុត្តកានុសារេន ទីឃសិព្វនី[១] មត្តេន ។ ពាក្យថា "ឱវដ្ដិកករណ-មត្តេន" បានសេចក្ដីថា: ក្រាលដោយសំពត់ដែលគ្រាន់តែដេរផ្ទេរវែងៗ ឬរង្វើលៗ តាមផ្លូវជើងចេសដែលដានផ្ដុំ ។ ក្នុងគម្ពីរវជិរពុទ្ធិដីកា លោកកែចេញពីអដ្ឋកថាតទៅទៀតថា: **ទីឃសិព្វនីតិ ច បច្ឆាគតសិព្វនី ឱវដ្ដិត្វា សិព្វនំ វា** ។ ត្រង់ពាក្យថា "ទីឃសិព្វនី" ដែលប្រែមកថា "ដេរផ្ទេរវែងៗ ឬរង្វើលៗ" ដូច្នេះ សំដៅយកផ្ទេរដែលដេរបញ្ជោន់តាមក្រោយ ឬ ដេរដិតឡប់ ។ (អាការនេះ និយាយពីក្រាលកឋិនដោយសំពត់ដែលធ្វើមិនទាន់ហើយស្រេចជាចីវរ ទើបតែនឹងដេរបញ្ជោន់ដិតឡប់ប៉ុណ្ណោះ) ។

អាការទី ៧ អដ្ឋកថាកែចេញទៅថា: កណ្ឌុសករណមត្តេនាតិ មុទ្ទិ-យបដពន្ធនមត្តេន ។ ពាក្យថា "កណ្ឌុសករណមត្តេន" បានសេចក្ដីថា: ក្រាល

១ ច្បាប់ខ្លះថា "ទីឃសិព្វិត" ។



ដោយសំពត់ដែលគ្រាន់តែភ្ជាប់ក្ដុំនឹងក្រវិលក្ដុំ ។ (អាការនេះ និយាយពីក្រាលកឋិនដោយសំពត់ដែលធ្វើមិនទាន់ហើយស្រេចជាចីវរ ទើបតែនឹងដាក់ក្ដុំ ឬក្រវិលក្ដុំប៉ុណ្ណោះ) ។

អាការទី៨ អដ្ឋកថាកែចេញទៅថា: **ទឡ្ហីកម្មករណមត្តេនាតិ ទ្វេ ចិលិ[១] មិកាយោ ឯកតោ កត្វា សិព្វិតមត្តេន ។ អថវា ។ បឋមចិលិ[១] មិកា ឃដេត្វា ឋបិតា ហោតិ កឋិនសាដកំ តស្សា កុច្ឆិស្មឹ[២] ចិលិ[១] មិកំ កត្វា សិព្វិត-មត្តេន** ។ ពាក្យថា "ទឡ្ហីកម្មករណមត្តេន" បានសេចក្ដីថា: ក្រាលដោយសំពត់ដែលគ្រាន់តែដេរត្រួតសំពត់ស្រទាប់ពីរបញ្ចូលគ្នាធ្វើជាមួយ ។ ន័យ ១ ទៀតថា: គ្រាន់តែយកសំពត់ស្រទាប់១ដំបូងមកតគ្នាទុក ហើយយកសំពត់កឋិនមកដេរធ្វើជាស្រទាប់ខាងផ្ទៃសំពត់នោះ ។ ក្នុងគម្ពីរវជិរពុទ្ធិដីកា លោកកែចេញពីអដ្ឋកថាតទៅទៀតថា: **បឋមចិលិមិកា ឃដេត្វា ឋបិតា ហោតីតិ កឋិនទុស្សំ ទុព្វលំ ទិស្វា តំ ពលវតា អត្តនោ បកតិទុស្សេន សទ្ធឹ ឃដេត្វា ទុបដំ កត្វា សិព្វិតុកាមោ កឋិនទុស្សតោ បកតិទុស្សស្ស មហន្តតាយ បឋមំ តប្បមាណានុរូបំ ពន្ធកណ្ឌុសេ ឃដេត្វា វជេកេហិ ពន្ធិត្វា**

១-ច្បាប់ខ្លះថា "វិលិ" ២-ច្បាប់ខ្លះថា "កុច្ឆិ" ។

**កតំ ហោតីតិ អធិប្បាយោ** ។ ពាក្យថា "បឋមចិ-លិមិកា ឃដេត្វា ឋបិតា ហោតិ" ដែលប្រែមកថា "យកសំពត់ស្រទាប់១ដំបូងមកតភ្ជាប់ទុក" ដូច្នេះ អធិប្បាយថា: ភិក្ខុឃើញសំពត់កឋិន ទុព្វលភាព ចង់យកសំពត់កឋិននោះមកដេរត្រួតជាមួយនឹងសំពត់ប្រក្រតីរបស់ខ្លួន ដែលនៅមានកំឡាំង ធ្វើឱ្យទៅជាពីរជាន់ ហើយក៏យកសំពត់ប្រក្រតីរបស់ខ្លួននោះមកដាក់ក្រវិលនឹងកុំធ្វើឱ្យសមគួរដល់ប្រមាណនោះបំរុងទុកជាមុន ព្រោះសំពត់ប្រក្រតីរបស់ខ្លួនធំជាងសំពត់កឋិន ។ សេចក្តីខាងចុងក្នុងគម្ពីរសារត្ថទីបនីដីកាកែចេញតទៅទៀតថា: **កុច្ឆិចិលិមិកំ កត្វា សិព្វិតមត្តេនាតិ ចិរជិណ្ណានំ ចិលិមិកានំ ឯកតោ កត្វា សិព្វិនស្សេតំ អធិវចនំ** ។ ពាក្យថា "កុច្ឆិចិលិមិកំ កត្វា សិព្វិតមត្តេន" ដែលប្រែមកថា "គ្រាន់តែយកសំពត់កឋិនមកដេរធ្វើជាទ្រនាប់ខាងផ្ទៃ" ដូច្នេះជាឈ្មោះនៃសំពត់ស្រទាប់ថ្មីខ្លះចាស់ខ្លះដែលភិក្ខុដេរត្រួតជាមួយគ្នា។ ក្នុងកុរុន្ទអដ្ឋកថាលោកកែថា: បកតិបដពន្ធចីវរំ ទុបដំ កាតុំ កុច្ឆិចិលិមិក-អល្លិយាបនមត្តេន ។ គ្រាន់តែយកសំពត់កឋិនមកប្រពរភ្ជាប់ជាទ្រនាប់ខាងផ្ទៃដើម្បីធ្វើចីវរដែលខ្លួនដានទុកដោយសំពត់ប្រក្រតីឱ្យទៅជាពីរជាន់។ ក្នុងគម្ពីរវជិរពុទ្ធិដីកាលោកពន្យល់ថា: **តថាកតំ ឧបឌ្ឍចីវរំ បកតិ~ចីវរស្ស មហន្តតាយ បកតិចីវរសង្ខមេវ គច្ឆតិ ន កឋិន~**



**ចីវរសង្ខំ** ។ ចីវរពីរជាន់ដែលភិក្ខុធ្វើបែបនោះ រាប់ថាជាចីវរប្រក្រតីវិញ មិនរាប់ថាជាចីវរកឋិនឡើយ ព្រោះចីវរប្រក្រតីធំជាង ។ (អាការនេះនិយាយពីក្រាលកឋិន ដោយចីវរជាប្រក្រតីរបស់ខ្លួន គ្រាន់តែយកសំពត់កឋិនមកដេរត្រួតបញ្ចូលជាមួយប៉ុណ្ណោះ) ។

អាការទី ៩ អដ្ឋកថាកែចេញទៅថា: **អនុវាតករណមត្តេនាតិ បិដ្ឋិអនុវាតារោបនមត្តេន** ។ ពាក្យថា "អនុវាតករណមត្តេន" បានសេចក្តីថា: ក្រាលដោយសំពត់ដែលគ្រាន់តែលើកឡើងនូវអនុវាតខាងខ្នង។ ក្នុងគម្ពីរសារត្ថទីបនីដីកា កែចេញពីអដ្ឋកថាតទៅទៀតថា: **បិដ្ឋិ~អនុវាតារោបនមត្តេនាតិ ទីឃតោអនុវាតស្សារោបនមត្តេន** ។ ពាក្យថា "បិដ្ឋិអនុវាតារោបនមត្តេន" ដែលប្រែមកថា "គ្រាន់តែលើកឡើងនូវអនុវាតខាងបណ្តោយ ។ (អាការនេះនិយាយពីក្រាលកឋិនដោយសំពត់ដែលធ្វើមិនទាន់ហើយស្រេចជាចីវរ ទើបតែនឹងដាក់អនុវាតខាងបណ្តោយប៉ុណ្ណោះ) ។

អាការទី ១០ អដ្ឋកថាកែចេញទៅថា: បរិភណ្ឌ ករណមត្តេនាតិ កុច្ឆិអនុវាតារោបនមត្តេន ។ ពាក្យថា "បរិភណ្ឌ ករណមត្តេន" បានសេចក្តីថា: ក្រាលដោយសំពត់ដែលគ្រាន់តែលើកឡើងនូវអនុវាតខាងផ្ទៃ ។ ក្នុងគម្ពីរសារត្ថទីបនីដីកាកែចេញពីអដ្ឋកថាតទៅទៀតថា: កុច្ឆិអនុវាតារោប-

នមត្តេនាតិ បុថុលតោ អនុវាតស្សារោបនមត្តេន ។ ពាក្យថា "កុច្ឆិអនុវាតារោបនមត្តេន" ដែលប្រែមកថា "គ្រាន់តែលើកឡើងនូវអនុវាតខាងផ្ទៃ" បានសេចក្ដីថា: គ្រាន់តែលើកឡើងនូវអនុវាតខាងទទឹង ។ ( អាការនេះនិយាយពីក្រាលកឋិនដោយសំពត់ដែលមិនទាន់ធ្វើហើយស្រេចជាចីវរ ទើបតែនឹងដាក់អនុវាតខាងទទឹងប៉ុណ្ណោះ ) ។

អាការទី ១១ អដ្ឋកថាកែចេញទៅថា: **ឱវដ្ដេយ្យករណមត្តេនាតិ អាគន្តុកបដារោបនមត្តេន ៗ កឋិនចីវរតោ វា បន គហេត្វា អញ្ញស្មឹ កឋិនចីវរេ បដារោបនមត្តេន** ។ ពាក្យថា "ឱវដ្ដេយ្យករណមត្តេន" បានសេចក្ដីថា: ក្រាលដោយសំពត់ដែលគ្រាន់តែលើកបញ្ចូលផ្ទាំងសំពត់ថ្មី ពុំនោះគ្រាន់តែលើកយកផ្ទាំងសំពត់អំពីកឋិនចីវរ ១ ទៅដាក់បញ្ចូលជាផ្ទាំងក្នុងកឋិនចីវរឯទៀត ។ ក្នុងគម្ពីរវជិរពុទ្ធិដីកាលោកពន្យល់ថា: **ហេដ្ឋិមកោដិយា បញ្ចកស្ស ឥច្ឆិតព្ពត្តា កឋិនទុស្សំ ខណ្ឌាខណ្ឌំ ពហុធា ឆិន្ទិត្វា សិព្វិតុកាមោ កឋិនចីវរតោ បដ្ដំ គហេត្វា អញ្ញស្មឹ កឋិនចីវរេ បដ្ដំ អារោបេតិ ៗ អថវា ៗ ពហូនិ កឋិនទុស្សានិ បំសុកូលានិ ខុទ្ទកានិ ឯកចីវរត្ថាយ មហន្តានញ្ច ខុទ្ទកត្ថាយ ឆិន្នានិ ហោន្តិ តតោ ហិ ភិក្ខុ ឯកច្ចតោ កឋិនចីវរតោ បដ្ដំ គហេត្វា អញ្ញស្មឹ កឋិនចីវរេ បដ្ដំ អារោបេតិ** ។ ភិក្ខុកាត់សំពត់កឋិន ឱ្យជាកំណាត់តូច កំណាត់ធំច្រើនកំណាត់ ព្រោះប្រាថ្នាចង់ដេរធ្វើជាចីវរយ៉ាងជាន់ទាបឱ្យ បានត្រឹមបញ្ចខណ្ឌ ហើយលើកយកផ្ទាំងសំពត់អំពីកឋិនចីវរ ១ ផ្នែកទៅដាក់ជាផ្ទាំងក្នុងកឋិនចីវរ ១ ផ្នែកឯទៀត ។ ពុំនោះសំពត់កឋិនច្រើនសុទ្ធតែជាសំពត់បង្សុកូលយ៉ាងតូចៗ គេប្រគេនមកបំរុងនឹងឱ្យធ្វើជាចីវរកឋិន ១ ផង ជាសំពត់តូចៗ សម្រាប់ភិក្ខុឯទៀតច្រើនអង្គផង ហើយភិក្ខុលើកយកផ្ទាំងសំពត់អំពីកឋិនចីវរ ១ ផ្នែក ទៅដាក់ជាផ្ទាំងក្នុងកឋិនចីវរ ១ ផ្នែកឯទៀតផ្សេង ។ ( អាការនេះនិយាយពីក្រាលកឋិនដោយសំពត់ដែលមិនទាន់ធ្វើស្រេច ជាចីវរ ទើបតែនឹងលើកផ្ទាំងសំពត់ដាក់ផ្សំពីនេះទៅនោះពីនោះមកនេះប៉ុណ្ណោះ ) ។



អាការទី ១២ អដ្ឋកថាកែចេញទៅថា: **កម្ពលមទ្ទនមត្តេនាតិ ឯកវារំ យេវ រជនេ បក្ខិត្តេន គន្ធវណ្ណេន វា បណ្ឌុបលាសវណ្ណេន វា ៗ សចេ បន សកឹ វា ទ្វិក្ខត្តុំ វា រត្តម្បិ សារុប្បំ ហោតិ វដ្ដតិ** ។ ពាក្យថា "កម្ពលមទ្ទនមត្តេន" បានសេចក្ដីថា: ក្រាលដោយសំពត់ ដែលទើបតែនឹងដាក់ចុះទៅក្នុងទឹកជ្រលក់ ១ ដង មានពណ៌ដូចភ្លុកដំរី ឬស្លឹកឈើទុម ( លឿងខ្ចី ) ។ តែបើទុកជាទើបនឹងជ្រលក់បាន ១ ដងក្ដី ២ ដងក្ដី ហើយសំពត់នោះមានពណ៌សមគួរដល់

សមណភេទ[១] ក៏គួរដែរ ។ (អាការនេះនិយាយ ពីក្រាលកឋិនដោយចីវរដែលជ្រលក់ស្មើរមិនទាន់បានពណ៌គួរ) ។

អាការទី ១៣ អដ្ឋកថាកែចេញទៅថា: **និមិត្តកតេនាតិ ឥមិនា ទុស្សេន កឋិនំ អត្ថរិស្សាមីតិ ឯវំ និមិត្តកតេន** ។ ពាក្យថា "និមិត្តកតេន" បានសេចក្តីថា: ក្រាលដោយចីវរដែលកើតឡើងដោយសារធ្វើនិមិត្តកម្មយ៉ាងនេះថា "អាត្មានឹងក្រាលកឋិនដោយសំពត់នេះ" ។ ក្នុងគម្ពីរបរិវារក៏លោកកែប្រហែលគ្នានឹងន័យនេះដែរ ។ ក្នុងអដ្ឋកថាឯទៀតលោកកែថា: អយំ សាដកោ សុន្ទរោ សក្កា ឥមិនា កឋិនំ អត្ថរិតុន្តិ ឯវំ និមិត្តកម្មំ កត្វា លទ្ធេន ។ ក្រាលដោយចីវរដែលបានមកព្រោះតែធ្វើនិមិត្តកម្មយ៉ាងនេះថា "សំពត់សាដកនេះល្អ អាត្មាអាចនឹងក្រាលកឋិនដោយសំពត់សាដកនេះបាន" ។ (អាការនេះនិយាយពីក្រាលកឋិនដោយចីវរ ដែលកើតឡើងដោយសារភិក្ខុនិយាយបញ្ឆិតបញ្ឆៀងឱ្យទាយក ឬ ធ្វើកាយវិការណា ១ ឱ្យទាយក) ។

អាការទី ១៤ អដ្ឋកថាកែចេញទៅថា: **បរិកថាកតេនាតិ កឋិនំ នាម ទាតុំ វដ្ដតិ កឋិនទាយកោ ពហុំ បុញ្ញំ បសវតីតិ**

១-ពណ៌ដែលសមគួរដល់សមណភេទនោះត្រូវមើលក្នុងចីវរក្ខន្ធក តែគួរដឹងបណ្តោះអាសន្នថា: ចីវរដែលជ្រលក់ច្រើនលើកដោយទឹកខ្លីមខ្នុរមានពណ៌យ៉ាងណា ពណ៌យ៉ាងនោះឯងជាពណ៌សមគួរ ព្រោះលោកចង្អុលប្រាប់ថាខ្លីមខ្នុរជាគ្រឿងជ្រលក់ ១ ។



**ឯវំ បរិកថាយ ឧប្បាទិតេន** ។ ពាក្យថា "បរិកថាកតេន" បានសេចក្តីថា: ក្រាលដោយចីវរដែលកើតឡើងដោយសារនិយាយបញ្ចុះបញ្ចូល ទាយក យ៉ាងនេះថា "ការប្រគេនសំពត់កឋិនគួរព្រោះទាយកអ្នកប្រគេនសំពត់កឋិន រមែងតែជួបប្រសពនឹងបុណ្យយ៉ាងធំ" ។ អដ្ឋកថាដដែលលោកពន្យល់ថា: **កឋិនំ នាម អតិឧក្កដ្ឋំ វដ្ដតិ មាតរម្បិ វិញ្ញាបេតុំ ន វដ្ដតិ អាកាសតោ ឱតិណ្ណសទិសមេវ វដ្ដតិ** ។ ធម្មតាកឋិន ទាល់តែឧក្រិដ្ឋណាស់ទើបគួរ សូម្បីតែភិក្ខុនិយាយបញ្ចុះបញ្ចូលមាតារបស់ខ្លួនបានមកក៏មិនគួរដែរ លុះតែសំពត់ដែលឥតមាន**មោះមែ** ប្រាកដ បាក់ដូចជាអណ្តែតត្រសែតមកអំពីអាកាសទើបគួរ ។ (អាការនេះនិយាយពីក្រាលកឋិនដោយចីវរ ដែលកើតឡើងដោយសារភិក្ខុនិយាយបញ្ចុះបញ្ចូលដឹកនាំទាយក[១]) ។

អាការទី ១៥ អដ្ឋកថាកែចេញទៅថា: កុក្កុកតេនាតិ តាវកាលិកេន ។ ពាក្យថា "កុក្កុកតេន" បានសេចក្តីថា: ក្រាលដោយចីវរខ្ចីគេ ។ ក្នុងគម្ពីរបរិវារកែថា: កុក្កុកតេនាតិ អនាទិយទានេន ។ ពាក្យថា "កុក្កុកតេន" បានសេចក្តីថា: ក្រាលដោយចីវរដែលមិនមានទាយកគេនាំយកមកប្រគេន ។ (អាការនេះនិយាយ ពីក្រាលកឋិនដោយចីវរខ្ចីគេ ឬចីវរដែលភិក្ខុស្វែងរកបានមកដោយខ្លួនឯង ឬក្រាលដោយចីវរប្រក្រតីរបស់ខ្លួនស្រាប់) ។

១-បើបញ្ចុះបញ្ចូលឱ្យគេនាំទៅវត្តឯទៀត ឬនាំមកវត្តខ្លួនក៏ដោយតែខ្លួនមិនចូលទៅក្រាលអនុមោទនាផង ក៏មិនជាអ្វី បើចូលក្រាលឬអនុមោទនាផង កឋិននោះមិនឡើងទាំងអស់គ្នា ។

អាការទី ១៦ អដ្ឋកថាកែចេញទៅថា: **សន្និធិកតេនាតិ ឯត្ថ ទុវិធោ សន្និធិ ករណសន្និធិ ច និចយសន្និធិ ច ។ តត្ថ តទហេវ អកត្វា ឋបេត្វា ករណំ ករណសន្និធិ នាម ។ សង្ឃោ អជ្ជ កឋិនទុស្សំ លភិត្វា បុនទិវសេ ទេតិ អយំ និចយសន្និធិនាម ។** ដែលហៅថា សន្និធិ (ការផ្ដាកទុក) ក្នុងបទថា "សន្និធិកតេន" នេះមាន ២ គឺ: ករណសន្និធិ ផ្ដាកទុកដោយការធ្វើ ១ និចយសន្និធិ ផ្ដាកទុកដោយការមិនចាត់ចែង ១។ បណ្ដាសន្និធិទាំង ២ នោះ ការដែលភិក្ខុអ្នកក្រាលដំកល់សំពត់កឋិនទុក មិនធ្វើក្នុងថ្ងៃនោះ ហៅថា ករណសន្និធិ សង្ឃបានសំពត់កឋិនមកក្នុងថ្ងៃនេះថ្ងៃស្អែកឡើង ទើបប្រគល់ឱ្យទៅភិក្ខុអ្នកក្រាល ហៅថា និចយសន្និធិ ។ (អាការនេះ និយាយពីក្រាលកឋិនដោយចីវរដែលផ្ដាកទុកឱ្យរំលងថ្ងៃនៅដៃសង្ឃ ឬនៅដៃភិក្ខុអ្នកក្រាល) ។

អាការទី ១៧ អដ្ឋកថាកែចេញទៅថា: **និស្សគ្គិយេនាតិ រត្តិនិស្សគ្គិយេន** ។ ពាក្យថា "និស្សគ្គិយេន" បានសេចក្ដីថា: ក្រាលដោយចីវរជានិស្សគ្គិយ[១] ព្រោះរាត្រី ។ ក្នុងគម្ពីរសារត្ថទីបនីដីកាលោកកែទៅទៀតថា: រត្តិនិស្សគ្គិយេនាតិ រត្តិ អតិក្កន្តេន ។ ពាក្យថា "រត្តិនិស្សគ្គិយេន" ដែលប្រែមកថា "ក្រាលដោយចីវរជានិស្សគ្គិយព្រោះរាត្រី" នោះបានសេចក្ដីថា:

១-ពាក្យថា "និស្សគ្គិយ:" ក្នុងទីនេះ មិនមែនជាឈ្មោះនៃអាបត្តិនិស្សគ្គិយ:ឡើយ ។



ក្រាលដោយចីវរដែលកន្លងរាត្រី ។ ក្នុងគម្ពីរបរិវារលោកពន្យល់ថា: និស្សគ្គិយំ នាម ករិយមានេ អរុណោ[១] ឧទ្រិយតិ ។ កាលបើភិក្ខុកំពុងតែធ្វើចីវរ ទទួលអរុណរះឡើង (ចីវរនោះ) ចាត់ជានិស្សគ្គិយ ។ ក្នុងគម្ពីរវជិរពុទ្ធិដីកាលោកពន្យល់តទៅទៀតថា: រត្តាតិក្កន្តនិស្សជ្ជិតព្វត្តា និស្សគ្គិយន្តិ វុច្ចតិ ។ ចីវរនោះបានជាលោកចាត់ថាជា "និស្សគ្គិយ" ដូច្នេះ ព្រោះត្រូវលះបង់ចេញដោយហេតុតែកន្លងរាត្រីហើយ ។ (អាការនេះនិយាយពីក្រាលកឋិនដោយចីវរដែលធ្វើឱ្យកន្លងរាត្រី) ។

អាការទី ១៨ អដ្ឋកថាកែចេញទៅថា: **អកប្បកតេនាតិ អនាទិន្នកប្បពិន្ទុនា** ។ ពាក្យថា "អកប្បកតេន" បានសេចក្ដីថា: ក្រាលដោយចីវរដែលមិនបានកាន់យកនូវកប្បពិន្ទុ ។ (អាការនេះនិយាយពីក្រាលកឋិនដោយចីវរដែលមិនបានធ្វើកប្បពិន្ទុ) ។

អាការទី ១៩ ទី ២០ ទី ២១ អដ្ឋកថាកែចេញទៅថា: អញ្ញត្រសង្ឃាដិយាតិ អាទីសុ ឋបេត្វា សង្ឃាដិឧត្តរាសង្គអន្តរវាសកេ អញ្ញេន បច្ចត្ថរណាទិនា អត្ថតំ អនត្ថតំ ហោតិ ។ ពាក្យថា "អញ្ញត្រសង្ឃាដិយា" ដូច្នេះជាដើមបានសេចក្ដីថា: កឋិនដែលភិក្ខុវៀរលែងសង្ឃាដិ ឧត្តរាសង្គ និងអន្តរវាសកចេញ ហើយក្រាលដោយសំពត់ឯទៀតមានសំពត់កម្រាល

១- "អរុណំ" ដូច្នេះក៏មាន ។

ជាដើម មិនបានឡើងជាកឋិនឡើយ ។ (អាការពនេះនិយាយពីក្រាលកឋិនដោយសំពត់ឯទៀត ក្រៅពីសង្ឃាដិ ឧត្តរាសង្គនិងអន្តរវាសគឺក្រាលដោយសំពត់ផ្សេង ខុសពីចីវរទាំង ៣ នុះ ព្រោះថា កឋិននេះត្រូវតែភិក្ខុក្រាលដោយសង្ឃាដិ ឬឧត្តរាសង្គ ឬអន្តរវាសកណា ១ ទើបបាន, តែបើក្រាលគ្រប់ទាំង ៣ តែម្តងក៏មិនបានដែរ) ។

អាការទី ២២ អដ្ឋកថាកែចេញទៅថា: **អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វាតិ បញ្ចកានិ វា អតិរេកបញ្ចកានិ វា ខណ្ឌានិ កត្វា មហាមណ្ឌលអឌ្ឍមណ្ឌលានិ ទស្សេត្វា កតេនេវ វដ្ដតិ ។ ឯវញ្ហិ សមណ្ឌលីកតំ ហោតិ តំ ឋបេត្វា អញ្ញេន អច្ឆិន្នកេន វា ទ្វិត្តិចតុក្ខណ្ឌកេន វា ន វដ្ដតិ** ។ ពាក្យថា "អញ្ញត្រ បញ្ចកេន វា អតិរេកបញ្ចកេន វា" បានសេចក្តីថា: ការក្រាលកឋិន បានតែក្រាលដោយចីវរដែលកាត់ដាច់ជាបញ្ចខណ្ឌ ឬលើសពីបញ្ចខណ្ឌឡើងទៅ (សត្តខណ្ឌ នវខណ្ឌ ឯកាទសខណ្ឌ) ហើយបានធ្វើឱ្យត្រឹមត្រូវ សំដែងមហាមណ្ឌល និងអឌ្ឍមណ្ឌល[១] ឱ្យច្បាស់ប្រាកដផងទើបគួរ ។ មែនពិត ចីវរដែលធ្វើបែបនេះ បានឈ្មោះថាធ្វើឱ្យប្រកបដោយមណ្ឌល បើភិក្ខុលើកលែងចីវរបែបនេះចេញ ហើយ

១-ពាក្យនេះសូមឱ្យមើលក្នុងចីវរក្ខន្ធកៈ ឬមើលសៀវភៅចីវរវិភាគរបស់ម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា (ល្វី ឯម) ក៏បាន ។



ក្រាលដោយចីវរបែបឯទៀតដែលមិនបានកាត់សោះក្តី កាត់តែត្រឹម ២ ខណ្ឌ ៣ ខណ្ឌ ៤ ខណ្ឌក្តី មិនគួរទេ ។ ក្នុងគម្ពីរលោកបញ្ញត្តថា: សព្វន្តិមេន បរិច្ឆេទេន អន្តរវាសកោបិ ឆិន្និត្វាវ កាតព្វោ ។ អញ្ញថា អត្ថារវិបត្តិ ហោតិ តេនេវ អធិដ្ឋាសិព្វិតំ បន កឋិនំ ន វដ្ដតិ ។ ចីវរកឋិន ទុកជាកំណាត់យ៉ាងចុងគេបង្អស់ក៏ត្រូវឱ្យបានកាត់ស្បង់ ១ ដែរ បើធ្វើឱ្យខុសពីនេះទៅលោកចាត់ជាអត្ថារវិបត្តិ ក្រាលខុសមិនបានឡើងជាកឋិនឡើយ ព្រោះហេតុនោះ ចីវរកឋិន បើមិនបានកាត់ដេរ ឱ្យត្រឹមត្រូវមិនគួរទេ ។

ពាក្យថា "តទហេវ សញ្ឆិន្នេន" ក្នុងអដ្ឋកថាមិនឃើញមានកែ តែក្នុងគម្ពីរវជិរពុទ្ធដីកា លោកកែចេញទៅដោយពិស្តារថា: **តទហេវ សញ្ឆិន្នេនាតិ សច្ចេន កថិនត្ថារកស្ស កម្មវាចំ វត្វា ទិន្នេ~នេវ តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន ភវិតព្វំ ។ ឯវំ ទិន្នស្សេវ ហិ បរិវារេ បុព្វករណំ សត្តហិ ធម្មេហិ សង្គហិតន្តិ វុត្តំ ន ទាយកេន និយមានស្ស ។ តស្មា បរិនិដ្ឋិ~តបុព្វករណមេវ ចេ ទាយកោ សង្ឃស្ស ទេតិ សម្បដិច្ឆិត្វា កម្មវាចាយ ទាតព្វំ ។ តេន ច តស្មិំ យេវ សីមមណ្ឌលេ អធិដ្ឋហិត្វា អត្ថរិត្វា សង្ឃោ អនុមោទាបេតព្វោ កតបុព្វករណស្ស បុនកត្តព្វាភាវតោ ។ អត្ថារកស្ស ហត្ថគតមេវ ហិ សន្ធាយ**

**ន ឧល្លិខិតមត្តេនាតិ អាទិ វុត្តំ** ។ ពាក្យថា "តទហេវ សញ្ឆិន្នេន" បានសេចក្ដីថា: សំពត់កឋិនត្រូវតែសង្ឃសូត្រកម្មវាចា ប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ ហើយភិក្ខុអ្នកក្រាល ក៏ត្រូវតែកាត់ធ្វើឱ្យប្រកបដោយមណ្ឌលជាស្រេចក្នុងថ្ងៃនោះដែរ ។ មែនពិត ពាក្យដែលព្រះសង្គាហកត្ថេរទាំងឡាយ ពោលទុកក្នុងគម្ពីរបរិវារថា "បុព្វករណសង្គ្រោះដោយធម៌៧ប្រការ" នោះចំពោះតែសំពត់ដែលសង្ឃប្រគល់ឱ្យមកនៅទាំងលាតយ៉ាងនេះតែម្យ៉ាងទេ មិនមែនចំពោះចីវរស្រេចស្រាប់ដែលទាយកគេវេរប្រគេនមកនោះឡើយ ព្រោះហេតុនោះ បើទាយកគេវេរប្រគេនចីវរដែលគេធ្វើបុព្វករណរួចស្រេចមកហើយ ត្រូវសង្ឃទទួលហើយសូត្រកម្មវាចាប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលចុះ ។ ឯភិក្ខុអ្នកក្រាលនោះសោតត្រូវអធិដ្ឋានក្រាលក្នុងមណ្ឌលសីមានោះ ហើយញ៉ាំងសង្ឃឱ្យអនុមោទនាតែម្ដងទៅចុះ ព្រោះមិនមានកិច្ចនឹងត្រូវធ្វើបុព្វករណដែលគេធ្វើរួចស្រេចមកហើយនោះថែមទៀតទេ ។ មែនពិត វិធីធ្វើចីវរដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ក្រាលកឋិនដោយសំពត់គ្រាន់តែគូសក្រិតទទឹងបណ្ដោយប៉ុណ្ណោះ មិនបានឡើងជាកឋិន" ដូច្នេះជាដើមនោះ ព្រះអង្គទ្រង់ត្រាស់ចំពោះតែសំពត់ដែលបានមកដល់ដៃភិក្ខុអ្នកក្រាលហើយ នៅជាសំពត់លាតនៅឡើយទេតើ ។ ក្នុងគម្ពីរដដែលនោះលោកវិនិច្ឆ័យអំពីរឿងនេះ



ដោយច្បាប់លាស់តទៅទៀតដូច្នេះ :

ពាក្យទំនាស់: **បរិនិដ្ឋិតបុព្វករណំបិ បុន ធោវិត្វា វិសិព្វិត្វា កាតព្វមេវ វចនប្បមាណតោតិ ចេ** ។ បើមានពាក្យទំនាស់ជ្រែកចូលមកថា: ត្រូវតែយកចីវរដែលគេធ្វើបុព្វករណស្រេចមកហើយនោះទៅបោកគក់ ដេរ ធ្វើ ជាថ្មីទៀតទើបបាន ព្រោះយកពាក្យដើមដែលថាត្រូវឱ្យភិក្ខុ បោក គក់ កាត់ ដេរ ជ្រលក់ឱ្យហើយក្នុងថ្ងៃនោះ ឬឱ្យចេះបុព្វករណទាំង ៧ ប្រការនោះជាប្រមាណ ។

ពាក្យបដិសេធ: **ន ឆិន្នស្ស បុនច្ឆេទនាតិ សម្ភវតោ** ។ ធ្វើដូច្នោះមិនកើតទេ ពាក្យដើមមានបង្គាប់ឱ្យកាត់សំពត់ដែលគេកាត់ត្រេរមកហើយនោះម្ដងទៀតឯណា ។

ពាក្យទំនាស់: **អញ្ញស្មឹ ឋានេ ឆិន្ទិតព្វមេវាតិ ចេ** ។ បើមានពាក្យទំនាស់ជ្រៀតចូលមកទៀតថា: ត្រូវកាត់ត្រង់កន្លែងឯទៀតខុសពីកន្លែងចាស់នោះទៅ ។

ពាក្យបដិសេធ: **ន បព្វជ្ជាធិការេ កេសមស្សុំ ឱហារេត្វាតិ វចនប្បមាណតោ មុណ្ឌិ តស្ស ឆិន្នេបិ កេសេ បរិយេសិត្វា សិរស្មឹ ឋបេត្វា បុន ឱហារាបេត្វា បព្វាជេតព្វប្បសង្គតោ** ។ បែបនុ៎ះមិនកើតទេ បើក្នុងរឿងកឋិននេះចង់ធ្វើដូច្នោះ នោះក្នុងរឿងបំបួស

ត្រូវតែស្វែងរកសក់ដែលគេកោររួចហើយ យកមកដាក់បន្ទុបលើក្បាល បព្វជ្ជាបេក្ខកុលបុត្រដែលត្រងោលស្រាប់ ហើយកោរជាថ្មីម្តងទៀតសិន សឹមបំបួសទើបបាន ព្រោះយកពាក្យដើមដែលថាត្រូវឧបជ្ឈាយ៍ កោរសក់ នឹងពុកមាត់ ពុកចង្កាឱ្យជាប្រមាណ ។

ពាក្យកែ: **ន ឥធ នការេន បដិសិទ្ធត្ថាតិ ចេ** ។ បើមានពាក្យកែថា: មិនមែនដូចក្នុងរឿងបំបួសនោះទេ ព្រោះក្នុងរឿងកឋិននេះ លោកសំរេច ដោយអក្សរ (ន) ដែលប្រែថា "មិន" ឬថា "មិនកើត" ។

ពាក្យបញ្ចោះ: **ន អញ្ញត្រ សង្ឃាដិយាតិ នការេន បដិសិទ្ធត្ថា ឧត្តរាសង្គេន អនត្ថតំ ហោតីតិ អនិដ្ឋប្បសង្គតោ** ។ បើដូច្នោះ មិនចូលចិត្តថា: កាលបើភិក្ខុក្រាលកឋិនដោយឧត្តរាសង្គ នឹងមិនបានឡើងជាកឋិនទៅហើយឬ ?-ព្រោះលោកសំរេចដោយអក្សរ (ន) ត្រង់បទថា "ន អញ្ញត្រសង្ឃាដិយា" ដែលប្រែមកថា "ភិក្ខុក្រាលកឋិន ដោយសំពត់ឯទៀត វៀរលែងសង្ឃាដិ មិនកើតជាកឋិនដូច្នេះ ។

ពាក្យសម្រេចសេចក្តី: **តស្មា អតិនិវេសោ ន កាតព្វោ** ។ ព្រោះហេតុនោះ ពុទ្ធសាសនិកជន មិនត្រូវប្រកាន់ឱ្យឈ្លក់គំនិត នាំឱ្យកើត ទិដ្ឋិនឹងឧបាទានឡើយ ។

ក្នុងគម្ពីរធម្មសមុហវិនយ និងគម្ពីរនិបុណ្ណបទសង្គហលោកកែរឿង



នេះពិស្តារណាស់ទៅទៀត លោកមានតាំងទុកជាពាក្យបុច្ឆា-វិស្សជ្ជនាដូច្នេះ

សួរថា: **និដ្ឋិតបរិកម្មចីវរំ សចេ ទាយកោ កឋិនត្ថាយ ទេតិ វដ្តតិ នុខោ ឧទាហុ ន វដ្តតិ** ។ បើទាយកគេប្រគេនចីវរ ដែលមានបរិកម្មសម្រេច ស្រាប់មកដើម្បីឱ្យភិក្ខុក្រាលកឋិន តើគួរ ឬ មិនគួរ ។

ឆ្លើយថា: **ឯកច្ចេ តទហេវ សញ្ឆិន្នេនាតិ វុត្តត្តា ន វដ្តតីតិ វទន្តិ** ។ អាចារ្យពួកខ្លះ ពោលថាមិនគួរ ព្រោះអាងព្រះពុទ្ធដិកា ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "តទហេវ សញ្ឆិន្នេន" ដូច្នេះ ។

ពាក្យបដិសេធ: **តំ អយុត្តំ** ។ ពាក្យដែលអាចារ្យទាំងនោះ ពោលមកនោះមិនគួរទេ ។

សួរតបថា: **កស្មា** ។ បានជាថាពាក្យនោះមិនគួរ ព្រោះហេតុអ្វី ។

ឆ្លើយថា: **តទហេវ សញ្ឆិន្នេនាតិ ឥមស្ស អធិប្បាយំ អជានិត្វា វុត្តត្តា វិនយធរា បន បុព្វាចរិយា វដ្តតីតិ វទន្តិ** ។ បានជាថាពាក្យនោះ មិនគួរ ព្រោះអាចារ្យទាំងប៉ុន្មានដែល ពោលមកនោះ ពោលទាំងមិនដឹង សេចក្តីអធិប្បាយរបស់បទថា "តទហេវ សញ្ឆិន្នេន" នោះទៅទេ ឯបុព្វាចារ្យទាំងឡាយ លោកអ្នកទ្រទ្រង់ព្រះវិន័យ លោកពោលថាគួរ ។ (តអំពីនេះទៅលោកឆ្លើយអាងដល់គម្ពីរកង្ខាវិតរណី

នឹងគម្ពីរវជិរពុទ្ធិដីកា ដូចបានស្រង់មកដំណាលរួចហើយអំពីខាងដើម) ។ (អាការៈនេះ បើរូបបួមឱ្យខ្លីចុះមក ក៏ឃើញថា និយាយពីក្រាលកឋិនដោយចីវរដែលមិនបានកាត់ ឬកាត់ដែរតែមិនត្រូវតាមរបៀបចីវរបញ្ចខណ្ឌ ជាដើម ដែលប្រកបដោយអង្គ ៩ ប្រការ) ។

អាការទី ២៣ អដ្ឋកថាកែចេញទៅថា: **អញ្ញត្រ បុគ្គលស្ស អត្ថារាតិ បុគ្គលស្ស អត្ថារំ ឋបេត្វា ន អញ្ញេន សង្ឃស្ស វា គណស្ស វា អត្ថារេន អត្ថតំ ហោតិ** ។ ពាក្យថា "អញ្ញត្រ បុគ្គលស្ស អត្ថារា" បានសេចក្ដីថា: កឋិនដែលភិក្ខុលើកលែងកិរិយាក្រាលរបស់បុគ្គលចេញ ហើយក្រាលដោយកិរិយាក្រាលឯទៀត ជារបស់សង្ឃក្ដី របស់គណៈក្ដី មិនឡើងជាកឋិនឡើយ ។ (អាការនេះនិយាយពីក្រាលកឋិនច្រើនរូប សង្ឃតាំងពី ៤ អង្គឡើងទៅ ឬគណៈ២អង្គ ៣ អង្គ ក្រាលទាំងអស់គ្នា ។

អាការទី ២៤ អដ្ឋកថាកែចេញទៅថា: និស្សីមដ្ឋោ អនុមោទតីតិ ពហិឧបចារសីមាយ ឋិតោ អនុមោទតិ ។ ពាក្យថា "និស្សីមដ្ឋោ អនុមោទតិ" បានសេចក្ដីថា: ភិក្ខុស្ថិតនៅខាងក្រៅឧបចារសីមាក្រាល-អនុមោទនាកឋិន គឺថាអង្គុយក្រាលអនុមោទនាកឋិនខាងក្រៅឧបចារ-សីមា ។ ក្នុងគម្ពីរវិនយាលង្ការដីកាលោកសំដែងថា: យទិ កឋិនទានកម្ម-



វាចាភណានពទ្ធសីមា វិស្សូបនាយិកក្ខេត្តភូតឧបចារសីមាយ អន្តោ ឋិតា ឯវិ សតិ តស្មិ យេវ សីមមណ្ឌលេ អត្ថរណំ កាតព្វំ ។ ប្រសិនបើមានពទ្ធសីមាសម្រាប់សូត្រទានកម្មវាចា ប្រគល់សំពត់កឋិន តាំងនៅក្នុងឧបចារសីមាដែលជាខេត្តភិក្ខុចូលវស្សា កាលបើមានយ៉ាងនេះ ត្រូវភិក្ខុក្រាលកឋិនក្នុងមណ្ឌលសីមានោះចុះ ។ ក្នុងគម្ពីរដដែលនោះលោកពោលបញ្ជាក់មកទៀតថា: កម្មវាចាភណានសីមា ហិ ពទ្ធ[១] សីមាពទ្ធ[១] សីមាភូតា កឋិនត្ថារសីមា បន ឧបចារសីមាភូតា ឧបចារសីមា ច នាម ពទ្ធ[១] សីមំ អវត្ថិរិត្វាមិគច្ឆតិ ។ តស្មា សា សីមា ពទ្ធ[១] សីមា ច ហោតិ ឧបចារសីមាចាតិ ។ មែនពិត សីមាដែលសម្រាប់សូត្រកម្មវាចានោះ ជាពទ្ធសីមាក៏បាន អពទ្ធសីមាក៏បាន ឯសីមាសម្រាប់ក្រាលកឋិនចំពោះតែឧបចារសីមា[២] តែធម្មតា ឧបចារសីមារមែងតែតាំងនៅស្រោបព័ទ្ធជុំវិញពទ្ធសីមា ព្រោះហេតុនោះ សីមាដែលសម្រាប់ក្រាលកឋិននោះ គង់បានទាំងពទ្ធសីមា ទាំងឧបចារសីមា ។ ក្នុងគម្ពីរដដែលនោះលោកពោលទុក ១ កន្លែងទៀតថា: អន្តោ ឧបចារសីមាយ បន ពទ្ធសីមាយ សតិ តំ ពទ្ធសីមំ អវត្ថិរិត្វាបិ ឧបចារសីមាយគមនតោ សា ពទ្ធសីមា កម្មវាចាភណំនារហា ច ហោតិ កឋិនត្ថារារហា ច ។ កាលបើក្នុង

១-"ពទ្ធ" ដូច្នេះក៏មាន ។ ២- ក្នុងអដ្ឋកថាលោកសំដែងថា: ឧបចារសីមា នាម បរិក្ខិត្តស្ស វិហារស្ស បរិក្ខេបេន អបរិក្ខិត្តស្ស បរិក្ខេបារហដ្ឋានេន បរិច្ឆិន្នា ។ ដែលហៅថា ឧបចារសីមា បើវត្តដែលមានរបងឬព្រាំ កំណត់ត្រឹមរបងឬព្រាំនោះ បើមិនមានទេ កំណត់ត្រឹមទីដែលគួរយកជារបងឬព្រាំបាន គឺចម្ងាយពីរលេណ្ឌុបាត (មើលសៀវភៅសីលនិទ្ទេសទំព័រ ១៥៣) ។

វ៉ា ទ្បឧបចារសីមា មាន ពទ្ធសីមា ពទ្ធសីមានោះឯង គួរសូត្រកម្មវាចាបានផង គួរក្រាល កឋិនបានផង ព្រោះឧបចារសីមាតាំងនៅស្រោបព័ទ្ធ ជុំវិញពទ្ធសីមានោះហើយ ។ ក្នុងគម្ពីរដដែលនោះលោកបញ្ញត្តទុកថា: តេសំ ភិក្ខូនំ វស្សូបនាយិកក្ខេត្តភូតាយ ឯវ ឧបចារសីមាយ កឋិនត្ថារំ កាតុំ លភតិ ន អញ្ញឧបចារសីមាយ ។ ការក្រាលកឋិន ធ្វើបានតែក្នុងឧបចារសីមា ដែលជាខេត្តរបស់ភិក្ខុទាំងនោះចូលវស្សាប៉ុណ្ណោះ និងក្រាលក្នុងឧបចារសីមាឯទៀត ដែលមិនមែនជាខេត្តខ្លួនចូលវស្សា មិនបានឡើយ ។ ក្នុងគម្ពីរដដែលនោះ លោកពន្យល់ថា: **យទិ បន ន ចេវ ពទ្ធសីមវិហារោ ហោតិ ន ច អន្តោ ឧបចារសីមាយំ ពទ្ធសីមា អត្ថិ ឯករុបេ វិហារេ កម្មវាចំ វាចាបេតុំ ន លភតិ អញ្ញំ ពទ្ធសីមំ វា ឧទកុក្ខេបំ វា គន្ត្វា កម្មវាចំ វាចាបេត្វា អត្តនោ វិហារំ អាគន្ត្វា វស្សូបនាយិកក្ខេត្តភូតាយ ឧបចារសីមាយ ឋត្វា កឋិនំ អត្ថរិតព្វំ** ។ បើវត្តដែលមិនមានពទ្ធសីមាទាំងមូលហើយខាងក្នុងឧបចារសីមា ក៏មិនមានពទ្ធសីមាដែរ វត្តបែបនេះសូត្រកម្មវាចាមិនបានទេ ត្រូវចេញទៅរកពទ្ធ សីមាឯទៀត ឬ ឧទកុក្ខេបសីមា(១) សូត្រកម្មវាចារួចត្រឡប់មក កាន់វត្តខ្លួនវិញស្ថិតនៅក្នុងឧបចារសីមា ដែលជាខេត្តខ្លួននៅចាំវស្សានោះ ហើយគប្បីក្រាលកឋិនចុះ ។ ក្នុងគម្ពីរដដែលនោះលោកបង្គាប់ទុកមួយកន្លែងទៀតថា: អន្តោ-ឧបចារសីមាយំ ពទ្ធសីមាយ អវិជ្ជមានាយ ពហិឧបចារសីមាយំ ពទ្ធសីមំ



វា ឧទកុក្ខេបសត្តព្ភន្តរលភមានដ្ឋានំ វា គន្ត្វា ញត្តិទុតិយកម្មេន កឋិនទុស្សំ ទាបេត្វា បុន វិហារំ អាគន្ត្វា អន្តោឧបចារសីមាយមេវ កឋិនត្ថរណំ បុព្វា-ចរិយេហិបិ កតំ តំ សុកតមេវ ហោតីតិ ទដ្ឋព្វំ ។ ការក្រាលកឋិន បើក្នុងឧបចារសីមាមិនមានពទ្ធសីមា ត្រូវទៅកាន់ពទ្ធសីមាខាងក្រៅឧបចារសីមា ឬទីដែល គួរយកជាឧទកុក្ខេបសីមា ឬ សត្តព្ភន្តរសីមា បានសូត្រ ប្រគល់សំពត់កឋិនដោយញត្តិទុតិយវាចារួចត្រឡប់មកកាន់វត្តវិញ ហើយក្រាលក្នុងឧបចារសីមាដដែលចុះ សូម្បីបុព្វាចារ្យទាំងឡាយក៏លោកធ្វើបែបនេះដែរ អំពើដែលលោកធ្វើបែបនោះត្រូវដឹងថាជាអំពើលោកធ្វើត្រឹមត្រូវពិត ។

ក្នុងគម្ពីរដដែលនោះកន្លែងខ្លះ លោកកែផ្សេងទៅវិញថា: **អញ្ញិស្សា សីមាយ ញត្តិ អញ្ញិស្សា អត្ថរណំ ន វាតព្វំ តស្សំ យេវ ឧបចារសីមាយំ កម្មវាចំ សាវេត្វា តស្សំ យេវ អត្ថារោ កាតព្វោ ឧបចារសីមតោ ពហិឋិតំ ពទ្ធសីមំ គន្ត្វា អត្ថរណកិច្ចំ នត្ថិ** ។ មិនត្រូវសូត្រញត្តិក្នុងសីមាដទៃ ក្រាលក្នុងសីមាដទៃទេ ត្រូវតែសូត្រកម្មវាចា ក្នុងឧបចារសីមានោះ ហើយក្រាលក្នុងឧបចារសីមានោះដដែលទើបបាន កិច្ចដែលត្រូវទៅកាន់ពទ្ធសីមាឯទៀតដែលតាំងនៅខាងក្រៅឧបចារសីមាហើយក្រាលកឋិនមិនមានឡើយ ។ ក្នុងគម្ពីរដដែលនោះលោកបញ្ញត្តទុកមួយកន្លែងទៀតថា: តស្មិំ យេវ សីមមណ្ឌលេ កឋិនទានកម្មវាចំ ភណិត្វា តត្ថេវ អត្ថរណំ កាតព្វំ ន យស្មិំ កិស្មិញ្ចិ សីមមណ្ឌលេ កម្មវាចំ ភណិត្វា តត្ថេវ អត្ថរណំ កាតព្វំ ។ ត្រូវតែ

សូត្រកម្មវាចាប្រគល់សំពត់កឋិនក្នុងមណ្ឌលសីមានោះ ហើយក្រាលក៏ក្នុងមណ្ឌលសីមានោះដដែល មិនត្រូវសូត្រកម្មវាចាក្នុងមណ្ឌលសីមាឯណានីមួយផ្សេង ហើយមកក្រាលក្នុងមណ្ឌលសីមានោះវិញទេ ។ ក្នុងគម្ពីរវជិរពុទ្ធិដីកានឹងគម្ពីរធម្មសមុហវិនយ លោកកែត្រូវគ្នានឹងន័យនេះដែរ ។ (រូបរួមមក អាការនេះ និយាយពីភិក្ខុនាំយកសំពត់កឋិនចេញទៅក្រាលខាងក្រៅឧបចារសីមា ដែលខ្លួននៅចាំវស្សា តែបើវត្តនោះមិនមានពទ្ធសីមា គ្រាន់តែចេញទៅសូត្រកម្មវាចា ហើយត្រឡប់មកក្រាលនៅវត្តដែលខ្លួននៅចាំវស្សាវិញបាន[១] ឬគ្រាន់តែចេញទៅធ្វើជាគណបូរកបង្គ្រប់ភិក្ខុវត្តឯទៀតក៏មិនជាអ្វីដែរ) ។

កឋិនដែលភិក្ខុក្រាលប្រកបដោយអនត្ថតាការ ទាំង ២៤ នេះណាមួយ មិនបានឡើងជាកឋិនឡើយ ។

ពណ៌នាមកអំពីអាការក្រាលកឋិនមិនឡើង ក៏អស់សេចក្តីតែប៉ុណ្ណេះ ។

អនត្ថតកឋិនកថា ចប់

១-វិធីនេះក្នុងគម្ពីរវជិរពុទ្ធិដីកា វិនយាលង្ការដីកា នឹងគម្ពីរធម្មសមុហវិនយ លោកកែជាពីរសង្កាត់១ សង្កាត់ដើមថាបាន ១ សង្កាត់ចុងថាមិនបានដូចន័យដែលពោលមកហើយ និបុណ្ណបទសង្គហៈ លោកសំរេចសេចក្តីថាបានតែម្យ៉ាង ។



# អត្ថតកឋិនកថា

អនោះនេះនឹងពណ៌នាអំពីអាការក្រាលកឋិនឡើង ដែលហៅថា "អត្ថតាការ" តទៅ តាមលំអាននៃព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គ ដូចបានស្រង់យកមកដំណាលរួចហើយ ក្នុងខាងដើម ។

សួរថាៈ កឋិនដែលភិក្ខុក្រាលឡើងដោយអាការយ៉ាងណាខ្លះ ?

ឆ្លើយថាៈ តាមព្រះពុទ្ធដីកាខាងដើមនោះថាក្រាលឡើងដោយអាការ១៧ដូច្នេះគឺៈ អហតេន ១ អហតកប្បេន ១ បិលោតិកាយ ១ បំសុកូលេន ១ អហណិតេន ១ អនិមិត្តកតេន ១ អបរិកថាកតេន ១ អកុក្កុកតេន ១ អសន្និធិកតេន ១ អនិស្សគ្គិយេន ១ កប្បកតេន ១ សង្ឃាដិយា ១ ឧត្តរាសង្គេន ១ អន្តរវាសកេន ១ បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលីកតេន ១ បុគ្គលស្ស អត្ថារា ១ សីមដ្ឋោ អនុមោទតិ ១ រួចត្រូវជា ១៧ ។

អធិប្បាយៈ អាការទី ១ អដ្ឋកថាកែចេញទៅថាៈ **អហតេនាតិ អបរិភុត្តេន** ។ ពាក្យថា "អហតេន" បានសេចក្តីថាៈ ក្រាលដោយសំពត់ដែលគេមិនទាន់ប្រើ ។ (ក្រាលដោយចីវរធ្វើពីសំពត់ថ្មីសុទ្ធ) ។

អាការទី ២ អដ្ឋកថាកែចេញទៅថាៈ **អហតកប្បេនាតិ អហតសទិសេន ឯកវារំ វា ទ្វិក្ខត្តុំ វា ធោតេន** ។ ពាក្យថា

"អហតកប្បេន" បានសេចក្តីថា: ក្រាលដោយសំពត់ដែលគេបោកគក់ ១ ដង ២ ហើយ តែនៅប្រាកដស្មើដោយសំពត់ថ្មីសុទ្ធ ។ ( ក្រាលដោយចីវរស្រាប់ គេប្រើប្រាស់ជំនំហើយ ឬចីវរធ្វើពីសំពត់ជំនំ) ។

អាការទី ៣ អដ្ឋកថាកែចេញទៅថា: បិលោតិកាយាតិគតវត្ថេក-សាដកេន ។ ពាក្យថា "បិលោតិកាយ" បានសេចក្តីថា: ក្រាលដោយសំពត់សាដកដែលចាស់ហើយ ។ ( ក្រាលដោយចីវរធ្វើពីសំពត់សាដកចាស់) ។

អាការទី ៤ អដ្ឋកថាកែចេញទៅថា: បំសុកូលេនាតិ តេវីសតិយា ខេត្តេសុ ឧប្បន្នបំសុកូលេន ។ បំសុកូលិយភិក្ខុនា ចោលកភិក្ខុំ អាហិណ្ឌិត្វា លទ្ធចោលកេហិ កតចីវរេន ។ ពាក្យថា "បំសុកូលេន" បានសេចក្តីថា: ក្រាលដោយសំពត់បង្សុកូលដែលកើតឡើងក្នុងខេត្ត២៣ (១) គឺថាក្រាលដោយចីវរធ្វើពីសំពត់ដែលភិក្ខុអ្នកប្រព្រឹត្តទ្រទ្រង់ចីវរបង្សុកូលដើរស្វែងរកសំពត់បានមក។ ( ក្រាលដោយចីវរធ្វើពីសំពត់បង្សុកូល ឬសំពត់បង្សុកូលជាចីវរស្រាប់ដែលភិក្ខុអ្នកប្រព្រឹត្តបង្សុកូលស្វែងរកបាន នាំយកមកប្រគេនជាចីវរកឋិន) ។

អាការទី ៥ អដ្ឋកថាកែចេញទៅថា: អាបណិកេនាតិ អាបណទ្វារេ បតិតបិលោតិកំ គហេត្វា កឋិនត្ថាយ ទេតិ តេនាបិ វដ្ដតិ ។ ពាក្យថា "អាបណិកេន" បានសេចក្តីថា: បុគ្គលណា ១ គេកាន់យកកំណាត់សំពត់

១-មើលសៀវភៅសីលនិទ្ទេស ទំព័រ ១១៤-១៥-១៦ ( សង្កេតសំពត់ទី ១៧-១៨) ។



ចាស់ដែលធ្លាក់ចុះក្បែររានផ្សារ មកប្រគេនដើម្បីជាសំពត់កឋិន បើភិក្ខុក្រាលដោយសំពត់នោះគួរ ។ ( ក្រាលដោយចីវរធ្វើពីសំពត់ដែលធ្លាក់ចុះក្បែររានផ្សារ ដែលទាយកគេរើសយកមកប្រគេនជាចីវរកឋិន) ។

តាំងពីអាការទី ៦ ដល់ទី.១៧ អដ្ឋកថាដីកាទាំងពួងមិនឃើញមានកែថាជាដូចម្តេចតទៅទៀតឡើយ ប្រហែលជាលោកយល់ឃើញថាមានដំណើរដូចគ្នានឹងអនត្ថតាការខាងដើម ហើយគ្រាន់តែផ្ទុយសេចក្តីគ្នាប៉ុណ្ណោះ ហេតុនោះត្រូវដឹងសេចក្តីពិស្តារតាមលំអានដែលបានពោលមកក្នុងអនត្ថតាការឯណោះចុះ ឯក្នុងទីនេះសូមអធិប្បាយបន្តិចៗ តែតាមរូបបាលីដើមប៉ុណ្ណោះ ។

អាការទី ៦ គឺ: **អនិមិត្តកតេន** សេចក្តីថា: ក្រាលដោយចីវរដែលបានមកដោយធម៌ មិនបានធ្វើនិមិត្តកម្មបញ្ជិតបញ្ជៀងឱ្យទាយក ។ ( ផ្ទុយនឹងអនត្ថតាការទី ១៣) ។

អាការទី ៧ គឺ: **អបរិកថាកតេន** សេចក្តីថា: ក្រាលដោយចីវរដែលកើតឡើងដោយធម៌ មិនបាននិយាយបញ្ចុះបញ្ចូលទាយក ។ ( ផ្ទុយនឹងអនត្ថតាការទី ១៤) ។

អាការទី ៨ គឺ: **អកុក្កុកតេន** សេចក្តីថា: ក្រាលដោយចីវរដែល

ទាយកគេនាំយកមកប្រគេន មិនមែនខ្ចីគេយកមកក្រាល ឬ ដើរស្វែងរកខ្លួនឯងយកមកក្រាល) ។ (ផ្ទុយនឹងអនត្ថតាការទី ១៥) ។

អាការទី ៩ គឺ: **អសន្និធិកតេន** សេចក្តីថា: ក្រាលដោយចីវរដែល មិនបានធ្វើឱ្យជាសន្និធិ ។ (ផ្ទុយនឹងអនត្ថតាការទី ១៦) ។

អាការទី ១០ គឺ: **អនិស្សគ្គិយេន** សេចក្តីថា: ក្រាលដោយចីវរដែលមិនមែនជានិស្សគ្គិយ ។ (ផ្ទុយនឹងអនត្ថតាការទី ១៧) ។

អាការទី ១១ គឺ: **កប្បកតេន** សេចក្តីថា: ក្រាលដោយចីវរដែលបានធ្វើកប្បពិន្ទុរួចហើយ ។ (ផ្ទុយនឹងអនត្ថតាការទី ១៨) ។

អាការទី ១២-១៣-១៤គឺ: សង្ឃាដិយា-ឧត្តរាសង្គេន-អន្តរវាសកេន សេចក្តីថា: ក្រាលដោយសង្ឃាដិ-ឧត្តរាសង្គ-អន្តរវាសក គឺថាក្រាលដោយសង្ឃាដិឬឧត្តរាសង្គ ឬ អន្តរវាសក ណា ១ ក៏បាន តែមិនត្រូវក្រាលទាំង ២ ទាំង ៣ តែម្តងឡើយ ។ (ផ្ទុយនឹងអនត្ថតាការទី១៩-២០-២១) ។

អាការទី ១៥ គឺ: បញ្ចកេន វា អតិរេកបញ្ចកេន វា តទហេវសញ្ជិន្នេន សមណ្ឌលីកតេន សេចក្តីថា: ក្រាលដោយចីវរ បញ្ចខណ្ឌ (៥ផ្ទាំង) ឬ លើសជាងបញ្ចខណ្ឌ (៧ ផ្ទាំង៩ផ្ទាំង១១ផ្ទាំង) ដែលសង្ឃប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ ហើយបើចីវរស្រាប់ក៏ហើយទៅ បើនៅជាសំពត់លាតនៅឡើយទេ ភិក្ខុអ្នកក្រាលបានកាត់ធ្វើឱ្យប្រកប



ដោយមណ្ឌលស្រេចតែក្នុងថ្ងៃនោះ មិនបានទុកឱ្យកន្លងរាត្រី ។ (ផ្ទុយនឹងអនត្ថតាការទី ២២) ។

អាការទី ១៦ គឺ: **បុគ្គលស្ស អត្ថារោ** សេចក្តីថា: ក្រាលដោយកិរិយាក្រាលរបស់បុគ្គល. មិនមែនក្រាលដោយកិរិយាក្រាលឯទៀតជារបស់សង្ឃ ឬគណៈ គឺថាបុគ្គលជាអ្នកក្រាល សង្ឃ ឬគណៈជាអ្នកអនុមោទនា មិនមែនសង្ឃ ឬគណៈក្រាលទាំងអស់គ្នាឡើយ ។ (ផ្ទុយនឹងអនត្ថតាការទី ២៣) ។

អាការទី ១៧ គឺ: **សីមដ្ឋោ អនុមោទតិ** សេចក្តីថា: ភិក្ខុស្ថិតនៅក្នុងឧបចារសីមា ក្រាល-អនុមោទនាកឋិន មិនបានចេញទៅក្រាល-អនុមោទនា ខាងក្រៅឧបចារសីមា ដែលជាខេត្តខ្លួននៅចាំវស្សា ។ (ផ្ទុយនឹងអនត្ថតា-ការទី២៤) ។

ក្នុងអាការទាំង ១៧ នេះ ខាងដើមពីត្រឹមទី ១ ដល់ទី ៥ ត្រង់កណ្តាលទី ១២-១៣-១៤ ជាអាការមិនទៀង តាមតែប្រកបបាន ព្រោះមានដំណើរផ្ទុយគ្នា ព្រោះហេតុនោះឱ្យតែប្រកបដោយអាការណា ១ ក៏បាន ពីត្រឹមទី ៦ ដល់ទី ១១ ពីត្រឹមទី ១៥ ដល់ទី ១៧ ជាអាការទៀង ព្រោះមានដំណើរបណ្តោយគ្នា ត្រូវតែប្រកបព្រមទាំងអស់ទើបក្រាលកឋិនឡើង ។

ពណ៌នាមកអំពីអាការក្រាលកឋិនឡើង ១៧ ដែលហៅថា "អត្ថតាការ" អស់សេចក្តីតែប៉ុណ្ណោះ ។

អត្ថតកឋិនកថា ចប់

# ឧព្ភតកឋិនកថា

## មាតិកា

បន្ទាប់នេះនឹងពណ៌នាអំពីដំណើរដែលកឋិនដោះតទៅ តាមលំអាននៃព្រះពុទ្ធដីកាក្នុងគម្ពីរមហាវគ្គថា: **កថញ្ច ភិក្ខវេ ឧព្ភតំ ហោតិ កឋិនំ ។ អដ្ឋិមា ភិក្ខវេ កឋិនស្ស ឧព្ភារាយ ។** ម្នាលភិក្ខុទាំងឡាយ កឋិនដោះដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតិកាទាំង ៨ នេះ ជាហេតុឱ្យកឋិនដោះ ។

បទថា "មាតិកា" អដ្ឋកថាកែចេញទៅថា: **មាតិកាតិ មាតរោ ជនេន្តីយោតិ អត្ថោ ។ កឋិនុព្ភារំ ហិ ឯតា អដ្ឋ ជនេន្តិយោ ។** ពាក្យថា "មាតិកា" បានសេចក្តីថា: មាតា ឬអ្នកបង្កើត ព្រោះហេតុអ្វី? ព្រោះថាមាតិកាទាំង៨នុ៎ះ ញុំាងអាការដែលកឋិនដោះឱ្យកើត ។

មាតិកាទាំង៨នុ៎ះដូច្នេះ

**១-បក្កមនន្តិកា** មាតិកាមានកិរិយាចៀសចេញទៅចាកដែនកឋិនាវាសជាកំណត់ ។

**២-និដ្ឋានន្តិកា** មាតិកាមានកិរិយាសម្រេចនៃចីវរជាកំណត់ ។

**៣-សន្និដ្ឋានន្តិកា** មាតិកាមានសេចក្តីសន្និដ្ឋានចុះចិត្តព្រមជា



កំណត់ ។

**៤-នាសនន្តិកា** មាតិកាមានកិរិយាវិនាសចីវរជាកំណត់ ។

**៥-សវនន្តិកា** មាតិកាមានកិរិយាឮដំណឹងជាកំណត់ ។

**៦-អាសាវច្ឆេទិកា** មាតិកាជាហេតុឱ្យកឋិនដោះដោយដាច់សេចក្តីបំណង ឬ អស់សេចក្តីសង្ឃឹម ។

**៧-សីមាតិក្កន្តិកា** មាតិកាជាហេតុឱ្យកឋិនដោះដោយកន្លងដែនចីវរកាល ។

**៨-សហុព្ភារា** មាតិកាជាហេតុឱ្យកឋិនដោះ ដោយធ្វើការដោះជាមួយនឹងភិក្ខុទាំងឡាយក្នុងវត្ត ។

អធិប្បាយ: ភិក្ខុបានក្រាលកឋិនរួចហើយ គិតថា: "អញនឹងមិនត្រឡប់មកកាន់វត្តនេះវិញទេ" ហើយនាំយកចីវរដែលធ្វើស្រេចហើយ[1] ចៀសចេញទៅ គ្រាន់តែកន្លងផុតដែន ឧបចារសីមា កឋិនរបស់ភិក្ខុនោះដោះ ភិក្ខុនោះឈប់ខានបានអានិសង្សទាំង៥ប្រការតទៅ ។ ដំណើរកឋិនដោះ[2] បែបនេះឈ្មោះថា "បក្កមនន្តិក" ជាដំណើរកឋិនដោះតាមមាតិកាទី ១ ។

---

១-ចីវរដែលក្រាលកឋិនក្តី ដែលជាកឋិនានិសង្សក្តី ចីវរប្រក្រតីស្រាប់របស់ខ្លួនក្តីឱ្យតែធ្វើ ។

២-ហៅតាមពាក្យបាលីថា "កឋិនុទ្ធារ" ឬ "កឋិនុព្ភារ" ជួនណាលោកហៅថា "ឧទ្ធារ" ឬ "ឧព្ភារ" ដូច្នេះ ។

ភិក្ខុបានក្រាលកឋិនរួចហើយនាំយកចីវរជាចំណែកខ្លួន(១) ដែលមិនទាន់សម្រេចនៅឡើយ ចៀសចេញទៅកាន់វត្តដទៃជិតខាង លុះដល់ទៅវត្តជាខាងក្រៅឧបចារសីមា មានគំនិតកើតឡើងថា "អញនឹងឱ្យគេជួយធ្វើចីវរនេះក្នុងវត្តនេះ អញនឹងមិនត្រឡប់ទៅវត្តចាស់វិញទេ" ភិក្ខុនោះក៏ឱ្យគេជួយធ្វើចីវរតែខាងក្រៅឧបចារសីមាដែលនៅចាំវស្សានោះ គ្រាន់តែចីវរហើយស្រេច កឋិនរបស់ភិក្ខុនោះដោះ ។ ដំណើរកឋិនដោះបែបនេះឈ្មោះថា "និដ្ឋានន្តិក" ជាដំណើរកឋិនដោះតាមមាតិកាទី ២ ។

ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចៀសចេញទៅ លុះដល់ទៅវត្តជាខាងក្រៅឧបចារសីមា មានគំនិតកើតឡើងថា: "អញនឹងមិនឱ្យគេជួយធ្វើចីវរនេះទេ អញនឹងមិនត្រឡប់ទៅវត្តចាស់វិញទេ" គ្រាន់តែភិក្ខុនោះសន្និដ្ឋានចុះចិត្តព្រមដូច្នេះកឋិនដោះ ។ ដំណើរកឋិនដោះបែបនេះឈ្មោះថា "សន្និដ្ឋានន្តិក" ជាដំណើរកឋិនដោះតាមមាតិកាទី ៣ ។

ភិក្ខុបានក្រាលកឋិនរួចហើយ នាំយកចីវរដែលមិនទាន់ធ្វើចៀសចេញទៅ លុះដល់ទៅវត្តជាខាងក្រៅឧបចារសីមា មានគំនិតកើតឡើងថា "អញនឹងឱ្យគេជួយធ្វើចីវរក្នុងទីនេះ អញនឹងមិនត្រឡប់ទៅវត្តចាស់វិញទេ" ដល់កំពុងតែធ្វើ ទទួលចីវរនោះវិនាសដោយចោរលួចឬភ្លើងឆេះជា

១-ចីវរជាកឋិនានិសង្ស ដែលបានក្នុងថ្ងៃក្រាលកឋិនឬដែលកើតឡើងក្នុង ដែនកឋិនាវាសនោះតៗ មក (ទៅខាងចុងក៏ដូចគ្នា) ។



ដើម កឋិនរបស់ភិក្ខុនោះដោះ ។ ដំណើរកឋិនដោះបែបនេះឈ្មោះថា "នាសនន្តិក" ជាដំណើរកឋិនដោះតាមមាតិកាទី ៤ ។

ភិក្ខុបានក្រាលកឋិនរួចហើយគិតថា "អញគង់នឹងត្រឡប់មកកាន់វត្តនេះវិញ" ហើយនាំយកចីវរដែលមិនទាន់ធ្វើចៀសចេញទៅ លុះដល់ទៅវត្តជាខាងក្រៅឧបចារសីមា មានគំនិតកើតឡើងថា "អញនឹងឱ្យគេជួយធ្វើចីវរនេះក្នុងទីនេះ" ដល់ភិក្ខុនោះធ្វើចីវរហើយ ទទួលឮដំណឹងថា "ភិក្ខុសង្ឃក្នុងវត្តសូត្រដោះកឋិនទៅហើយ" គ្រាន់តែឮដំណឹងដូច្នេះ កឋិនរបស់ភិក្ខុនោះដោះ ។ ដំណើរកឋិននោះបែបនេះ ឈ្មោះថា "សវនន្តិក" ជាដំណើរកឋិនដោះតាមមាតិកាទី ៥ ។

ភិក្ខុបានក្រាលកឋិនរួចហើយ ចៀសចេញទៅបំណងនឹងស្វែងរកចីវរក្នុងទីដទៃ លុះទៅដល់ទីខាងក្រៅឧបចារសីមាមានគំនិតកើតឡើងថា "អញនឹងស្វែងរកចីវរតែក្នុងទីខាងក្រៅឧបចារសីមានេះ អញនឹងមិនត្រឡប់ទៅវត្តវិញទេ" ភិក្ខុនោះក៏ស្វែងរកចីវរតែក្នុងទីនោះទៅ ដល់ស្វែងរកមិនបានសេចក្ដីបំណងដែលនឹងស្វែងរកចីវរនោះដាច់ គ្រាន់តែដាច់សេចក្ដីបំណងនឹងស្វែងរកចីវរកឋិនរបស់ភិក្ខុនោះដោះ ។ ដំណើរកឋិនដោះបែបនេះ ឈ្មោះថា "អាសាវច្ឆេទិក" ជាដំណើរកឋិនដោះតាមមាតិកាទី ៦ ។

ភិក្ខុបានក្រាលកឋិនរួចហើយគិតថា "អញគង់នឹងត្រឡប់មកកាន់

វត្តនេះវិញ" ហើយនាំចីវរដែលមិនទាន់ធ្វើចេញសចេញទៅ លុះទៅដល់វត្តជាខាងក្រៅឧបចារសីមា ឱ្យគេជួយធ្វើចីវរនោះ ដល់ធ្វើចីវរហើយក៏នៅតែគិតថា "អញនឹងត្រឡប់ទៅវត្តវិញ" តែដម្កក់នៅខាងក្រៅ ឧបចារសីមាត្រាតែដល់កំណត់កាលដែលកឋិនដោះ គឺកន្លងហួសថ្ងៃ ១៥ កើតខែផល្គុណទៅ កឋិនរបស់ភិក្ខុនោះដោះ ។ ដំណើរកឋិននោះដោះបែបនេះឈ្មោះថា "សីមាតិក្កន្តិក" ជាដំណើរកឋិនដោះតាមមាតិកាទី ៧ ។

ភិក្ខុបានក្រាលកឋិនរួចហើយគិតថា "អញគង់នឹងត្រឡប់មកកាន់វត្តនេះវិញ" ហើយនាំយកចីវរដែលមិនទាន់ធ្វើចេញសចេញទៅ លុះបានឱ្យគេជួយធ្វើចីវរនោះហើយស្រេច គិតថា "អញនឹងត្រឡប់ទៅវត្តវិញ" ហើយត្រឡប់មកទាន់ដោះកឋិនក្នុងវត្ត កឋិនរបស់ភិក្ខុនោះដោះជាមួយនឹងភិក្ខុទាំងឡាយក្នុងវត្ត ។ កឋិនដោះតាមមាតិកាទី ៨ ។

មាតិកាទាំង ៨ នេះ តាមគម្ពីរមហាវគ្គ មានសេចក្តីពិស្តារឆ្ងាយទូលាយពន់ពេក ផុតវិស័យដែលនឹងអាចស្រង់យកមកអធិប្បាយក្នុងទីនេះឱ្យសព្វគ្រប់បាន ហេតុនោះសូមអធិប្បាយរួបរួមយ៉ាងខ្លីតែត្រឹមប៉ុណ្ណោះ សូមលោកអ្នកត្រូវការដោយសេចក្តីពិស្តារស្វែងរកមើលទៀតចុះ[១] ឯន័យដែលស្រង់យកមកអធិប្បាយនេះមានមកតាមគម្ពីរវិនយាលង្ការដីកា ដែលព្រះគន្ថរចនាចារ្យ លោកបានដកស្រង់យកមករៀបរៀងទុកជារបៀបបែប

១-មើលវិនយបិដកភាគ ៨ ពីត្រឹមទំព័រ ៨ ដល់ទំព័រ ៩១ ។



នេះស្រាប់ ។ ក្នុងគម្ពីរនោះលោកមានចងជាគាថាទុកដោយសេចក្តីបំព្រួញឱ្យងាយទន្ទេញចាំដូច្នេះ :

**បក្កមនញ្ច និដ្ឋានំ សន្និដ្ឋានញ្ច នាសនំ**
**សវនាសា ច សីមា ច សហុព្ភារភតិ អដ្ឋិមា ៨**

បក្កមន ១ និដ្ឋាន ១ សន្និដ្ឋាន ១ នាសន ១ សវន ១ អាសា ១ សីមា ១ សហុព្ភារា ១ ដូច្នេះនេះជាមាតិកាទាំង ៨ ។

## បលិពោធ

បន្ទាប់នេះនឹងពណ៌នាអំពីបលិពោធរបស់កឋិនតទៅ តាមលំអាននៃព្រះពុទ្ធដីកា ក្នុងគម្ពីរមហាវគ្គថា: ទ្វេមេ ភិក្ខវេ កឋិនស្ស បលិពោធា ។ ម្នាលភិក្ខុទាំងឡាយទាំងពីរនេះជាបលិពោធរបស់កឋិន ។

ក្នុងអធិការនេះ ត្រូវសំដែងអំពីបលិពោធ ដែលជាគ្រឿងចងទុកនូវកឋិនមិនឱ្យដោះ ក៏បលិពោធនោះពោលតាមលំអានព្រះពុទ្ធដីកា ខាងដើមនុះមាន ២ គឺ:

**១-អាវាសបលិពោធ** សេចក្តីកង្វល់ក្នុងអាវាស ។ (ចំពោះអាវាសដែលក្រាលកឋិន) ។

**២-ចីវរបលិពោធ** សេចក្តីកង្វល់ក្នុងចីវរ ។ (ចំពោះចីវរជាកឋិនាទិសង្ឃ) ។

អធិប្បាយៈ អាវាសបលិពោធ តាមព្រះពុទ្ធដីកាដើមក្នុងគម្ពីរមហាវគ្គថាៈ ឥធ ភិក្ខវេ ភិក្ខុ វសតិ តស្មឹ អាវាសេ វា សាបេក្ខោ វា បក្កមតិ បច្ចេស្សន្តិ ។ ឯវំ ខោ ភិក្ខវេ អាវាសបលិពោធោ ហោតិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះនៅក្នុងអាវាសនោះក្តី ចៀសចេញទៅតែនៅមានអាល័យថា "អញនឹងត្រឡប់វិញ" ក្តី ។ ម្នាលភិក្ខុទាំងឡាយយ៉ាងនេះឯង ហៅថា អាវាសបលិពោធ ។ ក្នុងគម្ពីរវិនយាលង្ការដីកាថាៈ យស្មឹ វិហារេ កឋិនំ អត្ថតំ ហោតិ តស្មឹ វសិស្សាមីតិ អញ្ញត្ថ គច្ឆន្តោបិ បុន តំ វិហារំ អាគច្ឆិស្សាមីតិ សាបេក្ខោ ហោតិ ។ អយំ អាវាសបលិពោធោ នាម ។ ភិក្ខុក្រាលកឋិនក្នុងវត្តឯណាតាំងចិត្តថា "អញនឹងនៅក្នុងវត្តនោះ" សូម្បីចេញទៅក្នុងទីដទៃតែនៅ មានអាល័យថា "អញនឹងត្រឡប់មកកាន់វត្តនោះវិញ" បែបនេះ ឈ្មោះថា អាវាសបលិពោធ ។

ចីវរបលិពោធ តាមព្រះពុទ្ធដីកាដើមក្នុងគម្ពីរមហាវគ្គថាៈ ឥធ ភិក្ខវេ ភិក្ខុនោ ចីវរំ អកតំ វា ហោតិ វិប្បកតំ វា ចីវរាសា វា អនុបច្ឆិន្នា ។ ឯវំ ខោ ភិក្ខវេ ចីវរបលិពោធោ ហោតិ ។ ម្នាលភិក្ខុទាំងឡាយ ចីវររបស់ភិក្ខុក្នុងសាសនានេះ មិនទាន់ធ្វើនៅឡើយក្តី ធ្វើមិនទាន់ហើយក្តី ពុំនោះសេចក្តីសង្ឃឹមក្នុងចីវរនៅមិនទាន់អស់ក្តី ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថាចីវរបលិពោធ ។ ក្នុងគម្ពីរវិនយាលង្ការដីកាថាៈ **តស្ស ភិក្ខុនោ**



**ចីវរំ អកតំ វា ហោតិ អបរិយោសិតំ វា អញ្ញតោ វា ចីវរំ លច្ឆាមីតិ អាសា អនុបច្ឆិន្នា ហោតិ ។ អយំ ចីវរបលិពោធោ នាម** ។ ចីវររបស់ភិក្ខុនោះមិន ទាន់ធ្វើនៅឡើយក្តី ធ្វើមិនទាន់ហើយស្រេចក្តី សេចក្តីសង្ឃឹមថា "អញមុខជានឹងបានចីវរអំពីទីដទៃ" នៅមិនទាន់អស់ក្តី បែបនេះ ឈ្មោះថា ចីវរបលិពោធ ៕

បលិពោធទាំង ២ នេះសម្រាប់ចងទុកនូវកឋិនមិនឱ្យដោះ បើទុកជាបលិពោធណា ១ ដាច់ឱ្យតែនៅសល់ ១ កឋិនក៏នៅមិនទាន់ដោះឡើយ ត្រាតែដាច់គ្រប់ទាំង ២ ទើបកឋិនដោះ ។

## ឧព្ភារ

បន្ទាប់នេះនឹងពណ៌នាអំពីដំណើរដែលកឋិនដោះតទៅ តាមន័យដែលមានមកក្នុងគម្ពីរវិនយាលង្ការដីកាថាៈ **ឧព្ភារោ ទុវិធោ អដ្ឋមាតិកា ឧព្ភារអន្តរុព្ភារវសេន** ។ ដំណើរដែលកឋិនដោះមាន ២ ដោយអំណាចនៃអដ្ឋមាតិកា ឧព្ភារ ១ អន្តរុព្ភារ ១ (បើញែកចេញរៀងតួមានដល់ ៩ គឺអដ្ឋមាតិកាឧព្ភារ ៨ អន្តរុព្ភារ ១) ។

អធិប្បាយៈ អដ្ឋមាតិកា ឧព្ភារ (ប្រែថា) ដំណើរកឋិនដោះ តាមមាតិកាទាំង៨លោកអធិប្បាយចេញទៅថាៈ **ពហិឧបចារសីមគតានំ ភិក្ខូនំ វសេន វុត្តា សត្ត កឋិនុព្ភារា ច ពហិឧបចារសីមំ**

**គន្ត្វា និវត្តេត្វា កថិនត្ថតវិហារេ អន្តរុព្ភារំវ បត្វា ភិក្ខូហិ សហ អន្តរុព្ភារស្ស កតត្តា សហុព្ភារសង្ខាតោ ឯកោ កថិនុព្ភារោ ចាតិ ឥមេ អដ្ឋ កថិនុព្ភារា អដ្ឋមាតិកាយ បរិដ្ឋត្តា អដ្ឋមាតិកាឧព្ភារោ នាម** ។ ដំណើរកឋិនដោះ ៧ លោកពោលទុកសម្រាប់ភិក្ខុដែលចេញទៅខាងក្រៅឧបចារសីមា ហើយធ្វើឱ្យកឋិនដោះក្នុងទីនោះតែម្តង ដំណើរកឋិនដោះ ១ គឺសហុព្ភារ សម្រាប់ភិក្ខុដែលចេញទៅកាន់ទីខាងក្រៅឧបចារសីមាដែរ តែត្រឡប់មកវិញ ទាន់ដោះកឋិនក្នុងរវាងពាក់កណ្តាលកាលកំណត់ ក្នុងវត្តដែលក្រាលកឋិនហើយបានចូលធ្វើការនោះជាមួយនឹងភិក្ខុទាំងឡាយច្រើនអង្គ រួមត្រូវជា ៨ ។ ដំណើរកឋិនដោះទាំង ៨ នេះ ហៅថាអដ្ឋមាតិកាឧព្ភារ ព្រោះចូលក្នុងមាតិកាទាំង ៨ ។

អន្តរុព្ភារ (ប្រែថា) ដំណើរកឋិនដោះក្នុងរវាងពាក់កណ្តាលកាលកំណត់ លោកអធិប្បាយចេញទៅថា: ពហិសីមំ អគន្ត្វា តស្មិំ យេវ វិហារេ និសីទិត្វា កឋិនុព្ភារញត្តិទុតិយកម្មវាចាយ កឋិនុព្ភារោ អដ្ឋមាតិកាយ អបរិដ្ឋោ ហុត្វា កាលបរិច្ឆេទំ អបត្វា អន្តរាយេវ កតត្តា អន្តរុព្ភារោ នាម ។ ដំណើរកឋិនដោះដោយញត្តិទុតិយកម្មវាចាដែលសម្រាប់សូត្រដោះកឋិនមិនចូលក្នុងមាតិកាទាំង ៨ ហៅថា អន្តរុព្ភារ ព្រោះជាដំណើរកឋិនដោះ



សម្រាប់ភិក្ខុទាំងឡាយ ដែលមិនបានចេញទៅខាងក្រៅឧបចារសីមាអង្គុយនៅតែក្នុងវត្តនោះនាំគ្នាធ្វើក្នុងរវាងពាក់កណ្តាលមិនទាន់ដល់កាលកំណត់ ។

ក្នុងគម្ពីរដដែលនោះ លោកអធិប្បាយបញ្ជាក់មកទៀតថា: **អន្តរុព្ភារសហុព្ភារា ញត្តិទុតិយកម្មវាចាយេវ កតា ឧ បក្កមនន្តិកាទយោ សត្ត កថិនុព្ភារា ន កម្មវាចាយ កតា** ។ អន្តរុព្ភារ ១ សហុព្ភារ ១ ភិក្ខុធ្វើ ដោយញត្តិទុតិយកម្មវាចា គឺសូត្រដោះដោយញត្តិទុតិយកម្មវាចាទើបកឋិនដោះ ឯកឋិនុព្ភារ៧មានបក្កមនន្តិកជាដើម ភិក្ខុមិនបាច់ធ្វើដោយកម្មវាចាទេ គឺថាបើមានទំនងគួរកឋិនដោះ កឋិនក៏ដោះឯងៗ មិនចាំបាច់សូត្រកម្ម-វាចាឡើយ ។

សួរថា: ដំណើរកឋិនដោះ២គឺ: អន្តរុព្ភារ ១ សហុព្ភារ ១ ប្លែកគ្នាដូចម្តេច ។

ឆ្លើយថា: តាមគម្ពីរវិនយាលង្ការដីកាដដែលនោះលោកកែថា: **អន្តរុព្ភារោ ពហិសីមំ អគន្ត្វា អន្តោសីមាយមេវ ឋិតេហិ ភិក្ខូហិ កតោ សហុព្ភារោ ពហិសីមគតេន ភិក្ខុនា បច្ឆាគន្ត្វា តំ អន្តរុព្ភារំ បត្វា តេហិ អន្តោសីមដ្ឋេហិ ភិក្ខូហិ សហ កតោតិ អយមេតេសំ វិសេសោ** ។ អន្តរុព្ភារ សម្រាប់ភិក្ខុទាំងឡាយច្រើនអង្គដែលមិនបានចេញទៅខាងក្រៅឧបចារសីមា ស្ថិតនៅតែ

ខាងក្នុងឧបចារសីមា ជួបជុំគ្នាធ្វើ ឯសហុព្ភារ សម្រាប់ភិក្ខុមួយអង្គដែលចេញទៅខាងក្រៅឧបចារសីមា ហើយត្រឡប់មកទាន់អន្តរុព្ភារនោះចូលធ្វើជាមួយនឹងភិក្ខុទាំងឡាយ ដែលស្ថិតនៅតែក្នុងឧបចារសីមានោះ នេះជាសេចក្តីប្លែកគ្នានៃដំណើរកឋិនដោះទាំង ២ នោះ ។

សួរថា: អន្តរុព្ភារ ហាក់ដូចជាដំណើរកឋិនដោះ ១ ផ្សេងក្រៅអំពីមាតិកាទាំង ៨ កាលបើដូច្នេះ មាតិកាដែលជាហេតុឱ្យកឋិនដោះមិនមានដល់៩ទៅហើយឬ ។

ឆ្លើយថា: មិនមែនដូច្នោះទេ រឿងនេះត្រូវដឹងតាមលំអានដែលលោករួបរួមទុកក្នុងគម្ពីរដែលនោះថា: ពហិសីមំ គន្ត្វា អាគតស្ស វសេន សហុព្ភារោ ពហិសីមំ អាគតានំ វសេន អន្តរុព្ភារោតិ ឯកោ យេវ ឧព្ភារោ ទ្វិធា វុត្តោ ។ ដំណើរកឋិនដោះតែ ១ ទេ តែលោកពោលបំបែកទៅជា ២ ដូច្នេះគឺ: ១ ហៅថា សហុព្ភារ សម្រាប់ភិក្ខុដែលចេញទៅខាងក្រៅឧបចារ-សីមា ហើយត្រឡប់មកវិញ, ១ ទៀត ហៅថា អន្តរុព្ភារ សម្រាប់ភិក្ខុច្រើនអង្គ ដែលមិនបានចេញទៅខាងក្រៅឧបចារសីមា ។ (ត្រូវដឹងថា វេលាដែលសង្ឃប្រជុំគ្នាសូត្រដោះកឋិនក្នុងរវាងពាក់កណ្តាលកាល បើមានភិក្ខុដែលចេញទៅខាងក្រៅត្រឡប់មកចូលធ្វើជាមួយផង ធ្វើតែមួយលើកក៏បានឈ្មោះទាំង ២ តែម្តង បើមិនមានទេ ក៏បានឈ្មោះតែអន្តរុព្ភារ ១



ប៉ុណ្ណោះ ហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់កំណត់មាតិកាទុកតែត្រឹម ៨ ដូចពោលមកហើយ) ។

សួរថា: ភិក្ខុសង្ឃត្រូវការសូត្រកម្មវាចាដោះកឋិនពីក្នុងរវាងពាក់កណ្តាលកាលដោយហេតុអ្វី ។

ឆ្លើយថា: តាមគម្ពីរដែលនោះលោកកែថា: មហាទានំ ទាតុកាមេហិ ឧបាសកេហិ អាគតាគតស្ស សង្ឃស្ស អកាលចីវរំ ទាតុកាមា ហុត្វា យាចិតត្តា ។ ភិក្ខុសង្ឃត្រូវការសូត្រកម្មវាចាដោះកឋិនពីក្នុងរវាងពាក់កណ្តាលកាលបែបនេះ ដោយហេតុតែឧបាសកទាំងឡាយដែលជាអ្នកពេញចិត្តនឹងធ្វើទានធំៗ គេអារាធនាឱ្យសូត្រដោះ ដើម្បីគេនឹងប្រគេនអកាលចីវរដល់ព្រះសង្ឃដែលនិមន្តមកហូហែរ[១] ។ រឿងនេះព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតក្នុងភិក្ខុនីវិភង្គ ដោយហេតុមានឧបាសកម្នាក់ទូលអារាធនា[២] ។

ក៏វិធីដែលព្រះដ៏មានព្រះភាគ ទ្រង់អនុញ្ញាតឱ្យសូត្រដោះកឋិននោះដូច្នេះ ត្រូវឱ្យភិក្ខុដែលឈ្លាសប្រតិពលញ៉ាំងសង្ឃឱ្យដឹងថា:

**សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ**

---

១-បើសង្ឃមិនបានសូត្រដោះកឋិនចេញទេ សង្ឃលាភដែលកើតឡើងក្នុងអាវាសនោះទាំងប៉ុន្មានត្រូវបានតែភិក្ខុដែលបានក្រាលកឋិនក្នុងអាវាសនោះប៉ុណ្ណោះភិក្ខុឯទៀតដែលមិនបានក្រាលកឋិនក្តីដែលនិមន្តមកពីក្រៅក្តី មិនត្រូវទាមចំណែកបានឡើយ ដល់សង្ឃសូត្រដោះកឋិនចេញទៅទើបសង្ឃ លាភនោះសាយភាយដល់ទៅភិក្ខុឯទៀត១ផង ។ ២-មើលវិនយបិដកភាគ ៥ ទំព័រ២៣១ ។

**សង្ឃោ កឋិនំ ឧទ្ធរេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ កឋិនំ ឧទ្ធរតិ ។ យស្សាយស្មតោ ខមតិ កឋិនស្ស ឧទ្ធារោ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ឧព្ភតំ សង្ឃេន កឋិនំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។**

បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ការនេះ) បើជាកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគួរដោះកឋិន ។ នេះជាពាក្យផ្សៀង។ បពិត្រព្រះតម្លៃងសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ (ឥឡូវ) សង្ឃដោះកឋិន ។ ការដោះកឋិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ កឋិនសង្ឃដោះហើយ ។ (ការនេះ) គួរដល់សង្ឃហើយ ព្រោះហេតុនោះបានជាសង្ឃ ស្ងៀមខ្ញុំចាំទុកនូវការនុ៎ះដោយភាពដែលសង្ឃស្ងៀមយ៉ាងនេះ ។

ក្នុងគម្ពីរវិនយាលង្ការដីកាលោកសំដែងថា: កេវលំ ទ្វិន្នំ បលិពោធានំ ឧបច្ឆេទេន បញ្ចហិ អានិសំសេហិ វិគតត្តា កឋិនុព្ភារា នាម ហោន្តិ ។ ធម្មតាកឋិនដែលបានឈ្មោះថាដោះ ព្រោះតែប្រាសចាកអានិសង្សទាំង ៥ ដោយដាច់បលិពោធទាំង ២ ប្រការប៉ុណ្ណោះ ។



ព្រោះហេតុនោះបើបលិពោធដាច់ព្រមទាំង ២ ហើយត្រូវដឹងថា កឋិនដោះហើយៗ ភិក្ខុនោះសោតក៏ឈប់លែងបានអានិសង្សទាំង៥តទៅទៀតដែរ បើបលិពោធ នៅគ្រប់ព្រមទាំង២ឬដាច់តែ ១ នៅសល់ ១ ត្រូវដឹងថា កឋិនមិនទាន់ដោះនៅឡើយទេ ភិក្ខុនោះក៏នៅបានអានិសង្សទាំង៥តទៅជាដរាប ។ តែដែលនឹងអាចកំណត់ដឹងបានថា បលិពោធណាដាច់ បលិពោធណាមិនទាន់ដាច់ ឬបលិពោធណាដាច់មុន បលិពោធណាដាច់ក្រោយ ឬដាច់ដំណាលគ្នានោះ លុះតែកំណត់តាមមាតិកាទាំង៨ដូចន័យដែលមានមកក្នុងគម្ពីរបរិវារ នឹងគម្ពីរតតិយសមន្តបាសាទិកាអដ្ឋកថាដូច្នេះ:

ក្នុងមាតិកាទី ១ គឺ: **បក្កមនន្តិកា** ចីវរបលិពោធដាច់មុនគឺដាច់តាំងពីនៅក្នុងអាវាស ព្រោះចីវរធ្វើស្រេចហើយ មិនមានកង្វល់នឹងធ្វើទៀត អាវាសបលិពោធដាច់ក្រោយគឺដាច់ដំណាលគ្នានឹងដំណើរដែលភិក្ខុនោះកន្លងផុតដែន ឧបចារសីមាចេញទៅខាងក្រៅ កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិការទី ២ គឺ: **និដ្ឋានន្តិកា** អាវាសបលិពោធដាច់មុនគឺដាច់ត្រង់ខណៈដែលភិក្ខុនោះតាំងចិត្តថា នឹងមិនត្រឡប់ទៅកាន់វត្តចាស់វិញ ចីវរបលិពោធដាច់ក្រោយ គឺដាច់ត្រង់ខណៈដែលធ្វើចីវរហើយស្រេច កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិកាទី ៣ គឺ: **សន្និដ្ឋានន្តិកា** បលិពោធទាំង ២ ដាច់ដំណាល

គ្នា មិនមុនមិនក្រោយ គឺដាច់ត្រង់ខណៈដែលភិក្ខុនោះសន្និដ្ឋានចុះចិត្តព្រមថា ចីវរក៏មិនឱ្យគេជួយធ្វើ វត្តចាស់ក៏មិនត្រឡប់ កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិកាទី ៤ គឺៈ **នាសនន្តិកា** អាវាសបលិពោធដាច់មុនគឺ ដាច់ត្រង់ខណៈដែលភិក្ខុនោះតាំងចិត្តថា នឹងមិនត្រឡប់ទៅកាន់វត្តចាស់វិញ ចីវរបលិពោធដាច់ក្រោយ គឺដាច់ត្រង់ខណៈដែលចីវរ វិនាស កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិកាទី ៥ គឺៈ **សវនន្តិកា** ចីវរបលិពោធដាច់មុន គឺដាច់ត្រង់ខណៈដែលធ្វើចីវរហើយ អាវាសបលិពោធដាច់ក្រោយគឺដាច់ដំណាលគ្នានឹងឮដំណឹងមកដល់ថា សង្ឃក្នុងវត្តសូត្រដោះកឋិនហើយ កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិកាទី៦ គឺៈ **អាសាវច្ឆេទិកា** អាវាសបលិពោធដាច់មុនគឺដាច់ត្រង់ខណៈដែលភិក្ខុនោះតាំងចិត្តថា នឹងមិនត្រឡប់ទៅវត្តចាស់វិញ ចីវរបលិពោធដាច់ក្រោយ គឺដាច់ត្រង់ខណៈដែលដាច់សេចក្ដីប្រាថ្នា ឬអស់សេចក្ដីសង្ឃឹមក្នុងចីវរ កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិកាទី ៧ គឺៈ **សីមាតិក្កន្តិកា** ចីវរបលិពោធដាច់មុនគឺដាច់ត្រង់ខណៈដែលធ្វើចីវរហើយ អាវាសបលិពោធដាច់ក្រោយ គឺដាច់ត្រង់



ខណៈដែលផុតដែនចីវរកាល កឋិនក៏ដោះក្នុងខណៈនោះ ។

ក្នុងមាតិកាទី ៨ គឺៈ សហុព្ភារា បលិពោធទាំង២ដាច់ដំណាលគ្នា មិនមុនមិនក្រោយ គឺដាច់ត្រង់ខណៈដែលសង្ឃសូត្រដោះចប់ញត្តិទុតិយកម្មវាចា កឋិនក៏ដោះក្នុងខណៈនោះ ។

សួរថាៈ ដំណើរកឋិនដោះក្នុងឧបចារសីមាមានប៉ុន្មាន ក្រៅឧបចារសីមាមានប៉ុន្មាន ជួនណាក្នុងឧបចារសីមា ជួនណាក្រៅឧបចារសីមា មានប៉ុន្មាន ។

ឆ្លើយថាៈ តាមគម្ពីរបរិវារលោកកែថាៈ **ទ្វេ កឋិនុទ្ធារា អន្តោសីមាយ ឧទ្ធរិយន្តិ អន្តរុព្ភារោ សហុព្ភារោ ។ តយោ កឋិនុទ្ធារា ពហិសីមា ឧទ្ធរិយន្តិ បក្កមនន្តិកោ សវនន្តិកោ សីមាតិក្កន្តិកោ ។ ចត្តារោ កឋិនុទ្ធារា សិយា អន្តោសីមាយ ឧទ្ធរិយន្តិ សិយា ពហិសីមាយ ឧទ្ធរិយន្តិ និដ្ឋានន្តិកោ សន្និដ្ឋានន្តិកោ នាសនន្តិកោ អាសាវច្ឆេទិកា** ។ ដំណើរកឋិនដោះក្នុង ឧបចារសីមាមាន ២ គឺៈ អន្តរុព្ភារ ១ សហុព្ភារ ១ ។ ដំណើរកឋិនដោះ ក្រៅឧបចារសីមាមាន ៣ គឺៈ បក្កមនន្តិក ១ សវនន្តិក ១ សីមាតិក្កន្តិក ១ ។ ដំណើរកឋិនដោះ ជួនណាក្នុងឧបចារសីមា ជួនណាក្រៅឧបចារសីមាមាន ៤ គឺៈ និដ្ឋានន្តិក ១ សន្និដ្ឋានន្តិក ១ នាសនន្តិក ១ អាសាវច្ឆេទិក ១ ។

អធិប្បាយៈ អន្តរុព្ភារ ១ សហុព្ភារ ១ កឋិនដោះក្នុងខណៈជាមួយ

គ្នា គឺដោះដោយអំណាចសង្ឃប្រជុំគ្នាសូត្រដោះក្នុងឧបចារសីមាដែលក្រាលកឋិននោះ ចាត់ជាដំណើរកឋិនដោះក្នុងឧបចារសីមា ។ បក្កមនន្តិក ១ សវនន្តិក ១ សីមាតិក្កន្តិក ១ ទាំង ៣ នេះ កឋិនដោះចំពោះភិក្ខុ ១ រូបៗ ដែលចេញទៅធ្វើឱ្យកឋិនដោះខាងក្រៅឧបចារសីមាដែលក្រាលកឋិននោះ ចាត់ជាដំណើរកឋិន ដោះខាងក្រៅឧបចារសីមា ។ និដ្ឋានន្តិក ១ សន្និដ្ឋានន្តិក ១ នាសនន្តិក ១ អាសាវច្ឆេទិក ១ ទាំង ៤ នេះ កឋិនដោះចំពោះភិក្ខុ ១ រូបៗ ដែរ តែបើភិក្ខុនោះកាលដើមឡើយឥតត្រូវការខ្វល់ខ្វាយដោយចំណែកចីវរដែលខ្លួនត្រូវបាន ហើយចៀសចេញទៅកាន់ទិសខាងក្រៅឧបចារសីមា ដាច់អាល័យថាលែងត្រឡប់វិញ ទទួលដល់ទៅខាងក្រៅ មានភិក្ខុឯទៀតដាស់តឿនបង្ខំឱ្យទៅទាមយកចំណែកចីវរនោះវិញ ក៏ត្រឡប់មកធ្វើឱ្យកឋិនដោះក្នុងឧបចារសីមា ដែលក្រាលកឋិននោះដដែលវិញព្រោះតែរឿង ចំណែកចីវរដែលខ្លួនត្រូវបាននោះ ចាត់ថាជាដំណើរកឋិនដោះក្នុងឧបចារសីមា បើភិក្ខុនោះនាំយកចំណែកចីវរដែលខ្លួនត្រូវបានចៀសចេញទៅខាងក្រៅ ហើយធ្វើឱ្យកឋិនដោះក្នុងទីនោះ តែម្តងទៅចាត់ថាជាដំណើរកឋិនដោះ ខាងក្រៅឧបចារសីមា[១] ។

ពណ៌នាមកអំពីដំណើរដែលកឋិនដោះ ជាប់ទាក់ទងដោយមាតិកា ៨

---

១-ចង់ច្បាស់រឿងនេះចូរមើលវិនយបិដកភាគ ៨ ពីត្រឹមទំព័រ៤២ដល់៤៨ ។



បលិពោធ ២ ឧព្ភារ ២ នឹងសេចក្តីវាយរងផ្សេងៗ ខ្លះក៏អស់សេចក្តីតែប៉ុណ្ណោះ ។

ឧព្ភតកឋិនកថា ចប់

## **បកិណ្ណកកថា**

ទីបំផុតនេះ នឹងស្រង់យកសេចក្តីដោយដុំៗ អំពីកឋិនភេទក្នុងគម្ពីរបរិវារ មកពណ៌នាជាសេចក្តីរោយរាយតាមការគួរតទៅ ។

សួរថា: ធម៌ប៉ុន្មាន កើតដំណាលគ្នានឹងក្រាលកឋិន ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: **សហ កឋិនស្ស អត្ថារា បណ្ណរសធម្មា ជាយន្តិ អដ្ឋ មាតិកា ទ្វេ បលិពោធា បញ្ច អានិសំសា** ។ ធម៌ កើតដំណាលគ្នានឹងក្រាលកឋិនមាន ១៥ គឺ: មាតិកា ៨ បលិពោធ ២ អានិសង្ស ៥ ។

អធិប្បាយ: ធម៌ទាំង ១៥ នុ៎ះហៅថា សហជាតធម៌ប្រែថា ធម៌កើតដំណាលគ្នា មិនមុនមិនក្រោយពីកាលដែលក្រាលកឋិន បើកឋិនភិក្ខុមិនទាន់ក្រាលធម៌ទាំង ១៥ នុ៎ះក៏មិនទាន់កើត កឋិនភិក្ខុក្រាលហើយវេលាណា ធម៌ទាំង ១៥ នុ៎ះក៏កើតឡើងវេលានោះ ។ ភិក្ខុអ្នកក្រាល អ្នកអនុមោទនា ត្រាតែបានក្រាលបានអនុមោទនាកឋិនហើយស្រេចទើបបាន

ឈ្មោះថា មានមាតិកា ៨ បលិពោធ ២ អានិសង្ស៥បើមិនទាន់បានក្រាលទេ មិនទាន់បានឈ្មោះថាមានធម៌ទាំងនោះទេ បើទុកជាថាមានក៏គង់តែមិនមានដែរ ។

សួរថា: មូលរបស់កឋិនមានប៉ុន្មាន វត្ថុមានប៉ុន្មាន ភូមិមានប៉ុន្មាន ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: **កឋិនស្ស ឯកំ មូលំ សង្ឃោ។ តីណិ វត្ថូនិ សង្ឃាដិ ឧត្តរាសង្គោ អន្តរវាសកោ ឆ ភូមិយោ ខោមំ កប្បាសិកំ កោសេយ្យំ កម្ពលំ សាណំ ភង្គំ ឞ** មូលរបស់កឋិនមាន ១ គឺ: ជំនុំសង្ឃ ។ វត្ថុមាន ៣ គឺ: សង្ឃាដិ ១ ឧត្តរាសង្គ ១ អន្តរវាសក ១ ។ ភូមិមាន ៦ គឺ: សំពត់ដែលធ្វើមកពីសរសៃឈើ ១ សំពត់ដែលធ្វើមកពីកប្បាស ១ សំពត់ដែលធ្វើមកពីសូត្រ ១ សំពត់ដែលធ្វើមកពីរោមសត្វ ១ សំពត់ដែលធ្វើមកពីសម្បកឆ្មៃ ១ សំពត់ដែលធ្វើមកពីរបស់ទាំង ៥ ខាងដើមចម្រុះគ្នា ១ ។

អធិប្បាយ: ជំនុំសង្ឃតាំងពី៥អង្គឡើងទៅចាត់ជាមូលរបស់កឋិន។ ចីវរទាំង៣គឺ: សង្ឃាដិ ១ ឧត្តរាសង្គ: ១ អន្តរវាសក ១ ចាត់ជាវត្ថុរបស់កឋិន ។ កំណើតសំពត់៦ប្រការដូចរាប់មក ចាត់ជាភូមិរបស់កឋិន ។ មែនពិតកឋិននេះ លុះតែប្រកបព្រមដោយមូល វត្ថុ ភូមិ ដូចពោលមកហើយនុ៎ះទើបក្រាលឡើងជាកឋិនបើខ្វះតែណា ១ ដូចភិក្ខុមានចំនួនតិចជាង៥អង្គ



ចុះមកក្តី ក្រាលដោយសំពត់ឯទៀត ខុសពីចីវរទាំង ៣ នោះទៅក្តី ក្រាលដោយចីវរទាំង៣នោះណា ១ ហើយតែចីវរនោះគេធ្វើមកពីវត្ថុឯទៀតខុសពីកំណើតសំពត់៦យ៉ាងនោះក្តីមិនបានឡើងជាកឋិនឡើយ ។

សួរថា: ធម៌អ្វីចាត់ជាខាងដើមកឋិន ធម៌អ្វីចាត់ជាកណ្តាល ធម៌អ្វីចាត់ជាខាងចុង ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: កឋិនស្ស បុព្វករណំ អាទិ កិរិយា មជ្ឈេ អត្ថារោ បរិយោសានំ ។ បុព្វករណ(១) ចាត់ជាខាងដើមកឋិន កិរិយាគឺកិច្ចដែលត្រូវបច្ចុទ្ធរ័ដកចីវរចាស់អធិដ្ឋានចីវរថ្មីចាត់ជាកណ្តាល ការក្រាលនឹងអនុមោទនា ចាត់ជាខាងចុង ។

អធិប្បាយ: ក្នុងកឋិនត្ថារកិច្ចគឺកិច្ចដែលត្រូវក្រាលកឋិននេះចែកចេញជា៣សង្កាត់គឺ: សង្កាត់ដើមត្រូវចាត់ចែងធ្វើបុព្វករណ មានបោកគក់សំពត់កឋិនជាដើម បើទាយកគេមិនទាន់ធ្វើមកនៅឡើយទេ សង្កាត់កណ្តាលត្រូវបច្ចុទ្ធរ័ដកចីវរប្រក្រតីរបស់ខ្លួនចេញ ហើយអធិដ្ឋានចីវរថ្មីដែលត្រូវក្រាលកឋិននោះឡើង សង្កាត់ចុងត្រូវក្រាលដោយបញ្ចេញវចីភេទឱ្យជំនុំសង្ឃបានឮ ច្បាស់រួចហើយត្រូវញុំាងសង្ឃគណៈឬបុគ្គលដែលត្រូវអនុមោទនានោះឱ្យអនុមោទនាឡើង តែប៉ុណ្ណោះកឋិនត្ថារកិច្ច ក៏ទុកថាជាហើយស្រេច ។ សួរថា: បុគ្គលប្រកបដោយអង្គប៉ុន្មានមិនគួរក្រាលកឋិន

បាន ប្រកបដោយអង្គប៉ុន្មានទើបគួរក្រាលកឋិនបាន ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: អដ្ឋហង្គេហិ សមន្នាគតោ បុគ្គលោ អភព្វោ កឋិនំ អត្ថរិតុំ ។ បុព្វករណំ ន ជានាតិ បច្ចុទ្ធារំ ន ជានាតិ អធិដ្ឋានំ ន ជានាតិ អត្ថារំ ន ជានាតិ មាតិកំ ន ជានាតិ បលិពោធំ ន ជានាតិ ឧទ្ធារំ ន ជានាតិ អានិសំសំ ន ជានាតិ ។ អដ្ឋហង្គេហិ សមន្នាគតោ បុគ្គលោ ភព្វោ កឋិនំ អត្ថរិតុំ ។ បុព្វករណំ ជានាតិ ។ល។ អានិសំសំ ជានាតិ ។ បុគ្គលប្រកបដោយអង្គ៨មិនគួរក្រាលកឋិនបានឡើយគឺ: បុគ្គលមិនចេះបុព្វករណ (កិច្ចដែលត្រូវធ្វើមុនក្រាលកឋិន) ១ មិនចេះបច្ចុទ្ធារ (បច្ចុទ្ធរ័ដកចីវរចាស់) ១ មិនចេះអធិដ្ឋាន (អធិដ្ឋានចីវរថ្មី) ១ មិនចេះអត្ថារ (ការក្រាលកឋិន) ១ មិនចេះមាតិកា (ហេតុដែលកឋិនដោះ) ១ មិនចេះបលិពោធ (កង្វល់ជាគ្រឿងចងកឋិនទុកមិនឱ្យដោះ) ១ មិនចេះឧទ្ធារ[1] (ដំណើរកឋិនដោះតាមមាតិកាទាំង៨) ១ មិនចេះអានិសង្ស (ហេតុដែលមិនមានអាបត្តិ) ១ រូបត្រូវជា ៨ ។ បុគ្គលប្រកបដោយអង្គ ៨ (ខុសពីនេះ) ទើបគួរក្រាលកឋិនបានគឺ: បុគ្គលចេះបុព្វករណ ១ ចេះបច្ចុទ្ធារ ១ ចេះអធិដ្ឋាន ១ ចេះអត្ថារ ១ ចេះមាតិកា ១ ចេះបលិពោធ ១ ចេះឧទ្ធារ[1] ១ ចេះអានិសង្ស ១ រូមត្រូវជា ៨ ។

អធិប្បាយ: ធម៌៨ពួកគឺ: បុព្វករណពួក ១ បច្ចុទ្ធារពួក ១ អធិដ្ឋានពួក ១ អត្ថារពួក១ មាតិកាពួក ១ បលិពោធពួក ១ ឧទ្ធារពួក ១ អានិសង្សពួក ១ ត្រូវឱ្យភិក្ខុអ្នកក្រាលកឋិនចេះចាំឱ្យប្រាកដទើបគួរក្រាលកឋិនបាន ព្រោះថាភិក្ខុដែលចេះចាំធម៌ទាំងនេះប្រាកដ ទើបអង់អាចនឹងញុំាងកឋិនត្ថារកិច្ចឱ្យសម្រេចបានគឺត្រូវចេះបុព្វករណ បង្ការក្រែងសំពត់កឋិននោះទាយកគេមិនទាន់ធ្វើឱ្យសម្រេចមកនៅឡើយ ដោយគេមិនប្រសប់ ឬគេធ្វើមិនទាន់ គ្រាន់ខ្លួនធ្វើឱ្យសម្រេចឡើង ត្រូវចេះបច្ចុទ្ធារដើម្បីនឹងបច្ចុទ្ធរ័ដកចីវរចាស់របស់ខ្លួនចេញ ត្រូវចេះអធិដ្ឋាន ដើម្បីនឹងអធិដ្ឋានចីវរកឋិនដែលប្រុងនឹងក្រាលនោះឡើង ត្រូវចេះអត្ថារដើម្បីនឹងក្រាលកឋិនឱ្យបានត្រឹមត្រូវតាមធម៌ ត្រូវចេះមាតិកាបលិពោធនឹងឧទ្ធារដើម្បីនឹងដឹងរយៈដែលកឋិនដោះត្រូវចេះអានិសង្ស ដើម្បីឱ្យដឹងនូវអំណាចរបស់កឋិន បើមិនចេះចាំធម៌ទាំងនេះប្រាកដទេ មិនគួរក្រាលកឋិនបានឡើយ វៀរលែងតែភិក្ខុដែលជាមហាថេរ ហើយជំនុំសង្ឃអះអាងនឹងចាត់ចែងជំនួស ។

សួរថា: បុព្វករណ (កិច្ចដែលត្រូវធ្វើមុន) លោកសង្គ្រោះដោយធម៌ប៉ុន្មាន ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: **បុព្វករណំ សត្តហិ ធម្មេហិ សង្គហិតំ ធោវនេន វិចារណេន ឆេទនេន ពន្ធនេន**

---
១-សំដៅយកឧទ្ធារ ឬ ឧព្ភារ ២ យ៉ាងដូចសំដែងក្នុង (មើលទំព័រ )

**សិព្វនេន រជនេន កប្បករណេន**។ បុព្វករណលោកសង្គ្រោះដោយធម៌៧គឺ: ធោវន (បោកគក់) ១ វិចារណ (ចាត់ចែងវាស់) ១ ឆេទន (កាត់) ១ ពន្ធន (ដានភ្ជាប់) ១ សិព្វន (ដេរសម្រេច) ១ រជនៈ (ជ្រលក់) ១ កប្បករណ (ធ្វើកប្បពិន្ទុ) ១ រួមត្រូវជា ៧ ។

អធិប្បាយ: កិច្ចទាំង ៧ ប្រការនេះ បើនៅសល់ទំនេរត្រូវឱ្យភិក្ខុធ្វើឱ្យហើយស្រេចក្នុងវេលាមុនក្រាលកឋិន មិនត្រូវក្រាលហើយទើបធ្វើជាខាងក្រោយឡើយ ។ កិច្ចទី ១ បើសំពត់កឋិននោះថ្មីសុទ្ធ (សំពត់លាត) ដែលនៅជាប់ដោយបាយដម្បាញក្តី សំពត់ជិនំ ឬសំពត់ចាស់ដែលប្រឡាក់ដោយមន្ទិលផ្សេងៗ ក្តី ត្រូវបោកគក់ចេញ ។ កិច្ចទី២ត្រូវលែលកវាស់ឱ្យត្រឹមត្រូវតាមរបៀបចីវរបញ្ចខណ្ឌជាដើម ។ កិច្ចទី ៣ ត្រូវកាត់ឱ្យដាច់ដោយមុខកាំបិត ឬមុខកន្ត្រៃគ្រប់មហាមណ្ឌលនឹងអឌ្ឍមណ្ឌលជាដើម ។ កិច្ចទី ៤ ត្រូវដានផ្គុំតាមសំណាមដែលកាត់នោះ ។ កិច្ចទី ៥ ត្រូវដេរសម្រេចតាមលំអានដែលដាននោះ ។ កិច្ចទី ៦ ត្រូវជ្រលក់ដោយទឹកជ្រលក់ទាំង ៦ ប្រការ[១] ណា ១ ដែលព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យបានពណ៌

១-ទឹកជ្រលក់កើតអំពីមើមលើកលែងមើមរមៀត ១ ទឹកជ្រលក់កើតអំពីដើមឬខ្លឹមលើកលែងខ្លឹមស្បែងនឹងឃ្លេ ១ ទឹកជ្រលក់កើតអំពីសម្បក លើកលែងសម្បកលោទនិងសម្បកព្រហ៊ូត ១ ទឹកជ្រលក់កើតអំពីស្លឹក លើងលែងស្លឹកត្រុមនឹងស្លឹកឃ្លញ ១ ទឹកជ្រលក់កើតអំពីផ្កាលើកលែងផ្កាចារនិងផ្កាដក់គាំ ១ ទឹកជ្រលក់កើតអំពីផ្លែឈើគ្រប់ជំពូកដែលមានពណ៌គួរ ១ ។



ល្អមជាសមណសារូប ។ កិច្ចទី ៧ ត្រូវធ្វើកប្បពិន្ទុឱ្យខូចពណ៌ដោយវត្ថុ៣យ៉ាងណា ១ ។ កិច្ចទាំង៧នេះ ត្រូវឱ្យភិក្ខុធ្វើឱ្យរៀងតាមលំដាប់តាំងពីទី ១, ទី ២ ដរាបទៅមិនត្រូវធ្វើមុនក្រោយឆ្លាស់គ្នាឡើយ តែបើគេធ្វើរួចស្រេចមកហើយក៏ស្រាប់ទៅ បើនៅមានសល់កិច្ចណា ១ នឹងខានពុំបានត្រូវតែភិក្ខុធ្វើបង្ហើយទើបបាន (សម័យឥឡូវ ច្រើននៅសល់តែកិច្ចទី ៧ ភិក្ខុអ្នកក្រាលក៏ច្រើនបានធ្វើតែប៉ុណ្ណោះ) ។

សួរថា: បច្ចុទ្ធារ លោកសង្គ្រោះដោយធម៌ប៉ុន្មាន អធិដ្ឋានសង្គ្រោះដោយធម៌ប៉ុន្មាន ។

ឆ្លើយថា: ប្រស្នានេះ លោកកែថា: **បច្ចុទ្ធារោ តីហិ ធម្មេហិ សង្គហិ តោ សង្ឃាដិកា ឧត្តរាសង្គេន អន្តរវាសកេន ច អធិដ្ឋានំ តីហិ ធម្មេហិ សង្គហិតំ សង្ឃាដិយា ឧត្តរាសង្គេន អន្តរវាសកេន** ។ បច្ចុទ្ធារលោក សង្គ្រោះដោយធម៌៣គឺ: សង្ឃាដិ ១ ឧត្តរាសង្គ ១ អន្តរវាសក ១ ។ អធិដ្ឋានក៏លោកសង្គ្រោះដោយធម៌៣គឺ: សង្ឃដិ ១ ឧត្តរាសង្គ ១ អន្តរវាសក ១ ដូចគ្នា ។

អធិប្បាយ: បានពោលមកហើយអំពីខាងដើមថា កឋិននេះត្រូវក្រាលបានតែសង្ឃាដិ ឬឧត្តរាសង្គ ឬអន្តរវាសកប៉ុណ្ណោះ មិនត្រូវក្រាលដោយសំពត់ឯទៀតក្រៅពីនេះឡើយ ព្រោះហេតុនោះទើបក្នុងទីនេះលោក

សំដែងថា: បច្ចុទ្ធារនឹងអធិដ្ឋាន លោកសង្គ្រោះតែដោយធម៌ទាំង ៣ នោះជាមួយគ្នា តែបើនិយាយឱ្យអស់ជើងទៅ បច្ចុទ្ធានឹងអធិដ្ឋានទាំង ២ នេះក៏គង់ឃើញថាលោកសង្គ្រោះដោយធម៌ប្លែកគ្នា គឺបច្ចុទ្ធាសង្គ្រោះដោយសង្ឃាដិ ឧត្តរាសង្គ អន្តរវាសក ជាប្រក្រតី គឺត្រូវបច្ចុទ្ធរ័ដកសង្ឃាដិ ឧត្តរាសង្គ អន្តរវាសក ចាស់ដែលខ្លួនធ្លាប់ប្រើប្រាស់មក ឯអធិដ្ឋានសង្គ្រោះដោយសង្ឃាដិ ឧត្តរាសង្គ អន្តរវាសកថ្មី គឺត្រូវអធិដ្ឋាន សង្ឃាដិ ឧត្តរាសង្គ អន្តរវាសក ដែលជាចីវរកឋិននោះ បើប្រុងនឹងក្រាលដោយសង្ឃាដិត្រូវបច្ចុទ្ធរ័ដក សង្ឃាដិចាស់ អធិដ្ឋាន សង្ឃាដិថ្មីឡើង បើប្រុងនឹងក្រាលដោយឧត្តរាសង្គ ឬអន្តរវាសកក៏ត្រូវបច្ចុទ្ធរ័ដក ឧត្តរាសង្គ ឬអន្តរវាសកចាស់ចេញ ហើយអធិដ្ឋាន ឧត្តរាសង្គ ឬអន្តរវាសកថ្មីឡើងដូចគ្នាដែរ ។

សួរថា: អត្ថារ ( ការក្រាល) លោកសង្គ្រោះដោយធម៌ប៉ុន្មាន ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: **អត្ថារោ ឯកេន ធម្មេន សង្គហិតោ វចីភេទេន** ។ អត្ថា ( ការក្រាល) លោកសង្គ្រោះដោយធម៌តែ ១ គឺវចីភេទ ។

អធិប្បាយ: ការក្រាលកឋិនសម្រេចតែដោយវចីភេទ គឺត្រូវភិក្ខុអ្នកក្រាលបញ្ចេញវាចា ឱ្យជំនុំសង្ឃស្តាប់ឮច្បាស់ ទើបបានឡើងជាកឋិន បើ



ក្រាលខ្សឹបៗ តែម្នាក់ឯង ជំនុំសង្ឃស្តាប់មិនបានឮផងទេ មិនបានឡើងជាកឋិនឡើយ ។ ឯវិធីដែលនឹងត្រូវក្រាលជាយ៉ាងដូចម្តេចនោះ បានពោលមកអំពីខាងដើមរួចសព្វគ្រប់ហើយ ។

សួរថា: ការក្រាលកឋិន[១] របស់បុគ្គលប៉ុន្មានពួកដែលមិនបានឡើងជាកឋិន ប៉ុន្មានពួកដែលបានឡើងជាកឋិន ។

ឆ្លើយថា: ប្រស្នានេះលោកកែថា: **តិណ្ណំ បុគ្គលានំ កឋិនត្ថារោ ន រូហតិ និស្សីមដ្ឋោ អនុមោទតិ អនុមោទន្តោ ន វាចំ ភិន្ទតិ វាចំ ភិន្ទន្តោ ន បរំ វិញ្ញាបេតិ ។ តិណ្ណំ បុគ្គលានំ កឋិនត្ថារោ រូហតិ: សីមដ្ឋោ អនុមោទតិ អនុមោទន្តោ វាចំ ភិន្ទតិ វាចំ ភិន្ទន្តោ បរំ វិញ្ញាបេតិ** ។ ការក្រាលកឋិនរបស់បុគ្គល៣ពួកមិនបានឡើងជាកឋិនឡើយ គឺ: បុគ្គលស្ថិតនៅខាងក្រៅឧបចារសីមាក្រាលអនុមោទនាកឋិន ១ បុគ្គលក្រាល-អនុមោទនាកឋិនមិនបានបញ្ចេញវាចា ១ បុគ្គលបញ្ចេញវាចាមិនបានឱ្យអ្នកដទៃស្តាប់ដឹងសេចក្តីច្បាស់ ១ ។ ការក្រាលកឋិនរបស់បុគ្គល៣ពួកក្រៅពីនេះ ទើបបានឡើងកឋិនគឺ: បុគ្គលស្ថិតនៅក្នុងឧបចារសីមាក្រាល-

---

១-ក្នុងគម្ពីរវិនយាលង្ការដីកាលោកសំដែងថា: ញត្តិតោ បដ្ឋាយ យាវ អនុមោទនា សព្វា វិធី កឋិនត្ថារកិរិយាយំ បរិសតិ ។ វិធីទាំងពួងតាំងអំពីសូត្រញត្តិដរាបដល់អនុមោទនាជាទីបំផុតរាប់ចូលក្នុងកិច្ចក្រាលកឋិនទាំងអស់ ។

អនុមោទនាកឋិន ១ បុគ្គលក្រាល-អនុមោទនាកឋិនបានបញ្ចេញវាចា ១ បុគ្គលបញ្ចេញវាចា បានឱ្យអ្នកដទៃស្តាប់ដឹងសេចក្តីច្បាស់ ១ ។

អធិប្បាយៈ ការក្រាល-អនុមោទនាកឋិននេះត្រូវតែភិក្ខុប្រជុំគ្នាក្រាល-អនុមោទនាក្នុងដែនឧបចារសីមា ដែលនៅចាំវស្សានោះ មិនត្រូវលើកយកចីវរកឋិនចេញទៅក្រាល-អនុមោទនាខាងក្រៅដែនឧបចារសីមាដែលនៅចាំវស្សានោះទេ ហើយក្នុងវេលាដែលក្រាល-អនុមោទនានោះទៀតសោត ក៏ត្រូវបញ្ចេញវាចាទើបបាន មិនត្រូវក្រាល-អនុមោទនាដោយកាយឬនឹកៗ តែដោយចិត្តនោះទេ បើទុកជាបញ្ចេញវាចាក្រាលអនុមោទនាហើយ តែបញ្ចេញខ្សឹបៗ តែម្នាក់ឯង ក៏មិនបានដែរ ត្រូវតែបញ្ចេញឱ្យល្មមអ្នកដទៃស្តាប់ដឹងសេចក្តីច្បាស់ផងទើបបាន ។

សួរថាៈ ការក្រាលកឋិនប៉ុន្មានយ៉ាងដែលមិនឡើង ជាកឋិនប៉ុន្មានយ៉ាងដែលឡើងជាកឋិន ។

ឆ្លើយថាៈ ប្រស្នានេះលោកកែថាៈ **តយោ កឋិនត្ថារា ន រូហន្តិ ៖ វត្ថុវិបន្នញ្ចេវ ហោតិ កាលវិបន្នញ្ច ករណវិបន្នញ្ច ៖ តយោ កឋិនត្ថារា រូហន្តិ ៖ វត្ថុសម្បន្នញ្ចេវ ហោតិ កាលសម្បន្នញ្ច ករណសម្បន្នញ្ច** ។ ការក្រាលកឋិន ៣ យ៉ាងមិនបានឡើងជាកឋិនឡើយគឺៈ វត្ថុវិបន្នៈ ១ កាលវិបន្នៈ ១



ករណវិបន្នៈ ១ ។ ការក្រាលកឋិន៣យ៉ាង ក្រៅពីនេះទើបបានឡើងជាកឋិនគឺៈ វត្ថុសម្បន្ន ១ កាលសម្បន្ន ១ ករណសម្បន្ន ១ ។

អធិប្បាយៈ ពាក្យថា "វត្ថុវិបន្ន" ប្រែថា "វត្ថុខុស" សំដៅយកសំពត់កឋិនដែលជាអកប្បិយ គឺចីវរដែលមិនត្រឹមត្រូវ ។ ពាក្យថា "កាលវិបន្ន" ប្រែថា "កាលខុស" សំដៅយកកាលដែលទាយកគេប្រគេនសំពត់មកក្នុងថ្ងៃនេះ សង្ឃប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលដល់ទៅថ្ងៃស្អែក ។ ពាក្យថា "ករណវិបន្ន" ប្រែថា "ធ្វើខុស" សំដៅយកការធ្វើសំពត់ដែលទាយកគេមិនទាន់សម្រេចមកនៅឡើយ ហើយភិក្ខុមិនបានកាត់ធ្វើឱ្យហើយស្រេចក្នុងថ្ងៃនោះ ។ ពាក្យថា "វត្ថុសម្បន្ន" ប្រែថា "វត្ថុត្រូវ" សំដៅយកសំពត់កឋិនដែលជាកប្បិយ គឺចីវរដែលត្រឹមត្រូវ ។ ពាក្យថា "កាលសម្បន្ន" ប្រែថា "កាលត្រូវ" សំដៅយកកាលដែលទាយកគេប្រគេនសំពត់មកក្នុងថ្ងៃណាសង្ឃបានប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ ។ ពាក្យថា "ករណ-សម្បន្ន" ប្រែថា "ធ្វើត្រូវ" សំដៅយកការធ្វើសំពត់ដែលទាយកគេធ្វើត្រឹមត្រូវមកស្រាប់ ឬគេមិនទាន់ធ្វើមកនៅឡើយទេ តែសង្ឃប្រគល់ឱ្យមកក្នុងថ្ងៃណាភិក្ខុអ្នកក្រាលបានកាត់ធ្វើឱ្យត្រឹមត្រូវរួចជាស្រេចតែក្នុងថ្ងៃនោះ មិនឱ្យហួសដល់ទៅក្នុងថ្ងៃស្អែក ។

សេចក្តីបំព្រួញៈ ភិក្ខុក្រាលកឋិនដោយសំពត់ជាអកប្បិយដូចសេចក្តី

ដែលមានផ្កាភ្ញី មានពណ៌ខុស ជាដើមក្ដី ទាយកគេប្រគេនសំពត់កឋិនមកក្នុងថ្ងៃនេះ សង្ឃប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលដល់ទៅថ្ងៃស្អែកក្ដី សង្ឃប្រគល់ឱ្យមកក្នុងថ្ងៃនេះ ភិក្ខុអ្នកក្រាលធ្វើមិនទាន់ ទុកដល់ទៅថ្ងៃស្អែកក្ដី ក្រាលបែបនេះមិនបានឡើងជាកឋិនឡើយ ត្រាតែសំពត់កឋិនក៏ជាកប្បិយ សង្ឃក៏បានប្រគល់ឱ្យទៅភិក្ខុអ្នកក្រាលក្នុងថ្ងៃនោះ ភិក្ខុអ្នកក្រាលក៏បានចាត់ចែងធ្វើឱ្យត្រឹមត្រូវ បានក្រាលទាន់ក្នុងថ្ងៃនោះដែរ ក្រាលបែបនេះទើបបានឡើងជាកឋិន ។

សួរថា៖ ខែដែលគួរក្រាលកឋិនបានសំដៅយកខែណា ។

ឆ្លើយថា៖ ប្រស្នានេះលោកកែថា៖ **វស្សានស្ស បច្ឆិមោ មាសោ**។ ខែដែលគួរក្រាលកឋិនបានសំដៅយកខែ ១ ជាខាងចុងនៃវស្សានរដូវ ។

អធិប្បាយ៖ ការក្រាលកឋិននេះព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឱ្យក្រាលបានតែក្នុងរវាងខែ១ជាខាងចុងនៃវស្សានរដូវ គឺតាំងពីថ្ងៃ ១ រោជខែអស្សុជ ទៅទល់ត្រឹមថ្ងៃ ១៥ កើតខែកត្ដិកក្នុងរវាង ២៩ ថ្ងៃនេះ តាមតែថ្ងៃណាក៏ក្រាលបានទាំងអស់ក្រៅពីរវាងនេះទៅក្រាលមិនបានឡើយ បើទុកជាក្រាលក៏មិនបានឡើងជាកឋិនដែរ ។

សួរថា៖ ការក្រាលកឋិនដែលជាអត្ថារវិបត្តិ (ក្រាលខុស) ឬ អត្ថារសម្បត្តិ (ក្រាលត្រូវ) ត្រូវដឹងដោយអ្វី ?



ឆ្លើយថា៖ ការក្រាលកឋិនដែលជា..ត្ថារវិបត្តិ ឬ អត្ថារសម្បត្តិ ត្រូវដឹងដោយអនត្ថតាការ ២៤ នឹងអត្ថតាការ ១៧ ដូចបានអធិប្បាយរួចមកហើយអំពីខាងដើម ។

តាមន័យដែលមានមកក្នុងកឋិនភេទ នៃគម្ពីរបរិវារៈ មានសេចក្ដីពិស្ដារជាអធិក តែបានស្រង់យកដោយដុំៗ មកប្រកប់ក្នុងវិធី[...]៧ ខាងដើមខ្លះ មកពណ៌នាជាសេចក្ដីរាយរាយក្នុងកថានេះខ្លះ ក៏ឃើញថាហាក់ដូចជានៅសល់តិច ហើយមិនជាការធំប៉ុន្មានផង ព្រោះ[...]តុនោះ សូមបញ្ជាក់តែត្រឹមប៉ុណ្ណោះ ។

បកិណ្ណកកថា ចប់

ពណ៌នាមកក្នុងកឋិនក្ខន្ធកទី ៧ នៃគម្ពីរមហាវគ្គក៏សន្មតថាអស់សេចក្ដីជាយ៉ាងមធ្យមតែត្រឹមប៉ុណ្ណេះ ។

កឋិនក្ខន្ធក ចប់

**ខេមំ បប្បោន្តុ ញាណិនោ**

*សត្វទាំងឡាយ ចូរដល់នូវ[...]*

ព.ស. ២៤៧២ គ.ស

មានលក់ដុំ និង លក់រាយ

សៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ "បណ្ណាគារៈរ៉ត្នរតន៍"

# 136$E_0$ វិថីខេមរភូមិន្ទ

ទូរស័ព្ទលេខ 012 706 581

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។